# សកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Royal University of Law and Economic

## សារណាបញ្ចប់ការសិក្សា

# បណ្តឹង និងចំណាត់ការក្នុងរឿងក្តីព្រហ្មទណ្ឌ នៅសាលាដំបូងរាជធានី -ខេត្ត

ស្រាវជ្រាវពីថ្ងៃទី ខែ ឆ្នាំ២០២០ ដល់ថ្ងៃទី ខែ ឆ្នាំ២០២០


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **សាន្ត សុធារី**

**វ៉ែន ស្រីសរ**

សាស្ត្រាចារ្យណែនាំ

**លោក ហ៊ាង ឡេង**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២០

ឆ្នាំចូលសិក្សា ២០១៦

ឆ្នាំសរសេរសារណា ២០២០

# សេចក្ដីថ្លែងអំណរគុណ

យើងខ្ញុំជានិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានបញ្ចប់ថ្នាក់ បរិញ្ញាបត្រផ្នែកនីតិសាស្ត្រជំនាន់ទី២០ របស់ខ្លួនដោយការសរសេរសារណាជាថ្នូរនៃការបញ្ចប់ការសិក្សា និងជាការបង្ហាញពីសមត្ថភាពដែលបានសិក្សាក្នុងរយៈពេលបួនឆ្នាំកន្លងមកនេះ។

**និស្សិត សាន្ត សុធារី**

**និស្សិត វ៉ែនស្រីសរ**

នាងខ្ញុំទាំងពីរសូមធ្វើការសម្ដែងនូវទឹកចិត្ត និងការថ្លែងអំណរគុណដល់៖

លោកអ្នកមានគុណទាំងទ្វេដែលបានផ្ដល់កំណើតដល់យើងខ្ញុំ មើលថែរ អប់រំ ទូន្មានប្រៀនប្រដៅ ឧបត្ថម្ភរូបកូន នូវសម្ភារៈ លុយកាក់ សំលៀកបំពាក់ គ្រប់សព្វបែបយ៉ាង តាំងពីកូននៅតូចរហូតដល់កូនធំ ទាំងកម្លាំងកាយទាំងកម្លាំងចិត្តមិនគិតពីការនឿយហត់របស់លោកទាំងពីរនោះឡើយ និង បានឲ្យកូនបានរៀនសូត្រមានចំណេះដឹងតាំងពីថ្នាក់តូច រហូតដល់បញ្ចប់ថ្នាក់បរិញ្ញាប័ត្ររហូតដល់ជោគជ័យ។ គុណធំអនេក និងវិសេសវិសាលថ្លៃថ្លាបំផុត ដែលមិនអាចកាត់ថ្លៃបានរបស់លោកអ្នកមានគុណទាំងពីរ ដែលជាម្លប់ដ៏ប្រពៃត្រជាក់ត្រជុំសម្រាប់កូនគ្រប់ៗរូប មានទំហំធំធេង រកអ្វីប្រៀបផ្ទឹមពុំបានឡើយ។ ទង្វើរបស់លោកទាំងពីរធ្វើឲ្យកូនៗចងចាំជា និច្ចគ្មានថ្ងៃបំភ្លេចបានហើយនឹងស្ថិតក្នុងដួងព្រលឹងរបស់កូនៗជារៀងដរាបគ្មានថ្ងៃសាបសូន្យនោះឡើយ។

ថ្នាក់ដឹកនាំ លោក-លោកស្រីសាស្ត្រាចារ្យទាំងអស់នៃ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំបង្ហាត់បង្រៀន ផ្ដល់នូវដំបូន្មាន និងបទពិសោធន៍យ៉ាងច្រើនដល់យើងខ្ញុំ ដោយមិនខ្វល់ពីការនឿយហត់ ក្នុងគោលបំណងផ្ដល់នូវចំណេះដឹងដ៏ច្បាស់លាស់ និងដើម្បីជាប្រទីបក្នុងការបំភ្លឺផ្លូវជីវិតរហូតដល់ថ្ងៃអនាគត់។

ជាពិសេសយើងខ្ញុំសូមថ្លែងអំណរគុណ ចំពោះលោកសាស្ត្រាចារ្យ ហ៊ាង ឡេង ដែលជាសាស្ត្រាចារ្យណែនាំដើម្បីធ្វើឲ្យមាននូវដំណើរការនៃការតាក់តែងសារណានេះឡើង ប្រកបដោយជោគជ័យ។ ជាពិសេសលោកបានចំណាយនូវកម្លាំងកាយ កម្លាំងចិត្ត និងពេលវេលាដ៏មានតម្លៃក្នុងការប្រឹងប្រែងពន្យល់ តម្រង់ទិសណែនាំឯកសារដែលពាក់ពន្ធ័និងសារណា ផ្ដល់អនុសាសន៍ល្អៗ និងជួយកែលំអរចំណុចខ្វះខាតទាំងឡាយ ដើម្បីធ្វើយ៉ាងណាឲ្យសារណាយើងខ្ញុំបានទទួលនូវលទ្ធផលល្អ និងត្រឹមត្រូវ។

ជាចុងបញ្ចប់ យើងខ្ញុំទាំងពីរ សូមគោរពជូនពរដល់លោកអ្នកមានគុណទាំងទ្វេ និងលោក-លោកស្រីសាស្ត្រាចារ្យ ឲ្យទទួលបាននូវពុទ្ធិពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

នៅកម្ពុជាអំណាចបែងចែកជាបី អំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ អំណាចតុលាការ ដោយអំណាចទាំងបីនេះត្រូវបែងចែងដាច់ពីគ្នា។ បើនិយាយពីអំណាចតុលាការជាអំណាចឯករាជ្យ ដែលមិនចំនុះនឹងអំណាចណាមួយឡើយ ដោយសារកម្ពុជាធ្លាប់ឆ្លងកាត់សង្គ្រាម ធ្វើអោយបាត់បញ្ញវន្ត នឹងអ្នកមានចំណេះដឹងជាច្រើនដែលធ្វើអោយកម្ពុជាមានភាពកម្សោយទៅលើគ្រប់វិស័យទាំងអស់ រួមទាំងវិស័យតុលាការដែលបន្ទាប់ឆ្នាំ១៩៧៩ កម្ពុជាក៏មិនមានភាពនឹងនៅឡើយទេ ដោយខណៈពេលប្រទេសនៅមានភាពទន់ខ្សោយ បទល្មើសជាច្រើនដែលបានបង្កឡើងដោយ ជនបង្កប្រព្រឹត្តឡើងដោយអាណាធិបតេយ្យ ដូចនេះដើម្បីបង្ការកុំអោយភាពអស្ថេរភាពនៅតែកើតឡើង កម្ពុជាបានបង្កើតតុលាការឡើងវិញ ហើយបង្កើតច្បាប់ព្រហ្មទណ្ឌអន្តរកាលដើម្បី ធ្វើចំណាត់ការទៅលើជនណាដែលប្រព្រឹត្តអំពើដែលផ្ទុយពីច្បាប់។ ដើម្បីបង្កើតអោយមានភាពងាយស្រួលក្នុងការរកយុត្តិធម៌អោយប្រជាជន គេបានបង្កើតតុលាកានៅគ្រប់រាជធានី ខេត្ត។ រហូតមកឆ្នាំ២០០៧ក្រមនីតិវិធីព្រហ្មទណ្ឌនៃកម្ពុជាបានប្រកាសអោយប្រើ និងក្រមព្រហ្មទណ្ឌបានប្រកាសអោយប្រើ ឆ្នាំ២០០៩។ សព្វថ្ងៃនេះកម្ពុជាមានសាលាដំបូងគ្រប់រាជធានីខេត្ត សាលាឧទ្ធរណ៍មានទាំងឧទ្ធរណ៍ផងដែល ហើយមានតុលាការកំពូលមានតែមួយគត់នៅរាជធានីភ្នំពេញ។

បើយើងសិក្សាទៅលើការចំណាត់ការរបស់តុលាការ ដើម្បីស្វែងរកភាពយុត្តិធម៌ជូនប្រជាជនដែលរងភាពអយុត្តិធម៌គឺមានស្មុគស្មាញណាស់ ក្នុងដោះស្រាយវិវាទមួយជូនប្រជាជនដែលទទួលរងព្យសនកម្មពីជនបង្ក។ ដូចនេះមុនការសម្រេចរបស់ចៅក្រមណាម្នាក់ គាត់ត្រូវឆ្លងកាត់ដំណាក់ការជាច្រើនដែលឈានអោយគាត់ក្នុងចេញសេចក្តីសម្រេច។ព្រោះសេចក្តីសម្រេចរបស់គាត់គឺជា ការកំណត់ជោគវាសនារបស់ជនម្នាក់ៗដែលគាត់សម្រេចទៅលើ។

ដោយនាងខ្ញុំទាំងពីរយល់ឃើញថាការសិក្សាទៅផ្នែកច្បាប់មានសារៈសំខាន់ណាស់ដែលធ្វើអោយយើងដឹងពីច្បាប់ចែងក្នុងក្រមនីតិវីធីព្រហ្មទណ្ឌ ក្រមព្រមទណ្ឌ និងច្បាប់ផ្សេងទៀងដែលមានគោលបំណងការពារប្រជាជន នឹងដាក់ទណ្ឌកម្មដល់ជនបង្កដែលធ្វើអោយប៉ះពាល់ដល់អ្នកដ៏ទៃ។ ម៉្យាងទៀតនាងខ្ញុំទាំងពីរមានគោលបំណងចង់ស្រាជ្រាវបន្ថែម ទៅការអនុវត្តចំណាត់ការលើរឿងព្រហ្មទណ្ឌគ្រប់ដំណាក់ទាំងអស់ដូចនេះនាងខ្ញុំទាំងពីរ បានសំរេចជ្រើសរើសប្រធានបទមួយស្តីពី(បណ្តឹង និងចំណាត់ការលើរឿងក្តីព្រហ្មទណ្ឌនៅសាលាដំបូងរាជធានីខេត្ត)ព្រោះវាជាអ្វីមួយដែលធ្វើនាងខ្ញុំទាំងពីរអ្នកយល់ដឹងកាន់តែ ច្បាស់ទៅការអនុវត្តរបស់ស្ថាប័នតុលាការនេះ។

ទន្ទឹមនឹងនេះនាងខ្ញុំមានការរីករាយខ្លាំងណាស់ ដែលនាងខ្ញុំទាំងពីរបានមានឱកាសក្នុងបានសរសេរសារណាកើតឡើងពីការស្រលាញ់ពេញចិត្ត ពិសេសមានលោកសាស្ត្រចារ្យណែនាំលោក **ហ៊ាង ឡេង** ដែលលោកបានខិតខំណែនាំផ្តល់យោបល់ណែនាំ ជួយពន្យល់យ៉ាងក្បោះក្បាយ ណែនាំឯកសារសំខាន់ៗ អោយនាងខ្ញុំទាំងពីរអ្នក ឈានទៅការសរសេរសារណាមួយនេះបានដោយរលូន។ នាងខ្ញុំទាំងពីរសង្ឃឹមថាសារណានេះ នឹងក្លាយជាជំនួយជាឯកសារស្រាវជ្រាវដល់ និស្សិតជំនាន់ក្រោយដើម្បីស្រាវជ្រាវទៅ ប្រភេទបណ្តឹង និងចំណាត់ការលើរឿងក្តីព្រហ្មទណ្ឌនៅសាលាដំបូងរាជធានី ខេត្ត។

ទោះបីជាមានការខិតខំសិក្សាស្រាវជ្រាវ និងការត្រួតពិនិត្យយ៉ាងហ្មត់ចត់យ៉ាងណាក៏ដោយក៏ការសរសេរសារណាមួយនេះ ពិតជាមានភាពខ្វះចន្លោះជាមិនខាន ដូចនេះយើងខ្ញុំទាំងពីរអ្នករងចាំទទួលការរិះគន់ពីសំណាក់សាស្ត្រចារ្យ សិស្សនិស្សិតផ្សេងៗទៀតដើម្បីកែសម្រួលសារណានេះអោយមានភាពល្អប្រសើរ។

# មាតិកា

**ទំព័រ**


**សេចក្តីផ្តើម** ...... ១

**ជំពូកទី១**

**គោលការណ៍នៃការធ្វើពាក្យបណ្តឹង**

**ផ្នែកទី១៖ លក្ខខណ្ឌនៃការធ្វើពាក្យបណ្តឹង** ...... ៣

**កថាខណ្ឌទី១៖ បណ្តឹងអាជ្ញា** ...... ៣

ក. និយមន័យ ...... ៣

ខ. ទម្រង់នៃពាក្យបណ្តឹង និង លក្ខខណ្ឌនៃបណ្តឹង ...... ៣

គ. ការរលត់បណ្តឹង ...... ៤

ឃ. អាជ្ញាយុកាល ...... ៥

**កថាខណ្ឌទី២៖ បណ្តឹងរដ្ឋប្បវេណី** ...... ៦

**ផ្នែកទី២៖ ដំណើរការបណ្តឹងក្នុងរឿងព្រហ្មទណ្ឌ** ...... ៩

**កថាខណ្ឌទី១៖ អ្នកធ្វើពាក្យបណ្តឹងក្នុងរឿងព្រហ្មទណ្ឌអោយមានចលនា** ...... ៩

ក. ជនរងគ្រោះ ...... ៩

ខ. ដើមបណ្តឹងរដ្ឋប្បវេណី ...... ១០

គ. មន្ត្រីនគរបាលយុត្តិធម៌ ...... ១០

ឃ. អង្គការអយ្យការ ...... ១១

កថាខណ្ឌទី២៖ ស្ថាប័នដែលទទួលពាក្យបណ្តឹង ...... ១១

ក. អង្គភាពនគរបាលយុត្តិធម៌ ...... ១១

ខ. ស្ថាប័នអយ្យការ ...... ១១

**កថាខណ្ឌទី៣៖ បណ្តឹងក្នុងរឿងព្រហ្មទណ្ឌ** ...... ១២

ក. បណ្តឹងបរិហារ ...... ១២

ខ. បណ្តឹងទាមទារ ...... ១២

## ជំពូកទី២

## ចំណាត់ការលើពាក្យបណ្តឹងក្នុងរឿងព្រហ្មទណ្ឌ


**ផ្នែកទី១៖ ការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌** ..... ១៤

**កថាខណ្ឌទី១៖ គោលការណ៍ទូទៅរបស់នគរបាលយុត្តិធម៌** ..... ១៤

ក. លក្ខណៈសម្បត្តិរបស់មន្ត្រីនគរបាលយុត្តិធម៌ ..... ១៤

ខ. សមត្ថកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ ..... ១៥

**កថាខណ្ឌទី២៖ បេសកកម្មរបស់មន្ត្រីនគរបាលយុត្តិធម៌** ..... ១៦

ក. ការទទួលពាក្យបណ្តឹង ..... ១៧

ខ. ការត្រួតពិនិត្យបទល្មើស ..... ១៧

គ. ការស៊ើបអង្កេតលើពាក្យបណ្តឹង ..... ១៧

គ.១ នីតិវិធីការស៊ើបអង្កេតបទល្មើសជាក់ស្តែង ..... ១៧

គ.១.១ ការរាយការណ៍ទៅព្រះរាជអាជ្ញា ..... ១៨

គ.១.២ ការចុះឆែកឆេរ ..... ១៩

គ.១.៣ ការស្វែងរកភស្តុតាង ..... ២០

គ.១.៤ ការអនុវត្តការឃាត់ខ្លួន ..... ២១

គ.២ នីតិវិធីការស៊ើបអង្កេតបទល្មើសបឋម ..... ២៣

គ.២.១ ការបើកវិធានការស្រាវជ្រាវ ..... ២៣

គ.២.២ ការអនុវត្តការឃាត់ខ្លួន ..... ២៤

**ផ្នែកទី២៖ ស្ថាប័នអយ្យការ** ..... ២៥

**កថាខណ្ឌទី១៖ ការទទួលពាក្យបណ្តឹងក្នុងរឿងព្រហ្មទណ្ឌ** ..... ២៦

ក. តាមរយៈមន្ត្រីនគរបាលយុត្តិធម៌ ..... ២៧

ខ. ដើមបណ្តឹងរដ្ឋប្បវេណី ឬជនរងគ្រោះ ..... ២៧

**កថាខណ្ឌទី២៖ គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញា** ..... ២៨

ក. ការចោទប្រកាន់ក្នុងរឿងព្រហ្មទណ្ឌ ..... ២៨

ក.១ ការបើកការស៊ើបសួរ ........ ២៨
ក.២ ការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ ........ ២៩
ក.៣ ការបង្ហាញខ្លួនភ្លាម ........ ៣០
ខ. ការតម្កល់រឿងទុកឥតចាត់ការ ........ ៣១
ខ.១ ភាគីដែលអាចធ្វើបណ្តឹង ........ ៣២
ខ.២ រយៈពេលនៃការតវ៉ា ........ ៣២
ខ.៣ ការអនុវត្ត ........ ៣២
**ផ្នែកទី៣៖ យុត្តាធិការស៊ើបសួរ** ........ ៣៣
**កថាខណ្ឌទី១៖ ការស៊ើបសួររបស់ចៅក្រមស៊ើបសួរ** ........ ៣៣
ក. ការបើកការស៊ើបសួរ ........ ៣៣
ក.១ ការអនុវត្តតាមដីការសន្និដ្ឋានបញ្ជូនរឿងស៊ើបសួររបស់ព្រះរាជអាជ្ញា ........ ៣៤
ក.២ ការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ ........ ៣៤
ក.៣ ដីកាចេញដោយចៅក្រមស៊ើបសួរ ........ ៣៨
ខ. ការបិទការស៊ើបសួរ ........ ៤៥
ខ.១ តាមរយៈព្រះរាជអាជ្ញា ........ ៤៥
ខ.២ តាមរយៈដីកាដំណោះស្រាយ ........ ៤៥
**កថាខណ្ឌទី២៖ បណ្តឹងឧទ្ធរណ៍ ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ** ........ ៤៦
ក. និយមន័យ ........ ៤៦
ខ. សិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍ ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ ........ ៤៦
គ. រយៈពេលនៃការធ្វើបណ្តឹងឧទ្ធរណ៍ទៅលើសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរ ........ ៥០
ឃ. ការអនុវត្តពាក្យបណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ ........ ៥១

## ជំពូកទី៣

## ដំណាក់កាលសវនាការ

**ផ្នែកទី១៖ ការជំនុំជម្រះក្នុងរឿងក្តីព្រហ្មទណ្ឌ** ........ ៥៣
**កថាខណ្ឌទី១៖ នីតិវិធីមុនការជំនុំជម្រះ** ........ ៥៣

ក. រចនាសម្ព័ន្ធរបស់តុលាការ ............................................................ ៥៣
ខ. សមត្ថកិច្ចរបស់សាលាដំបូង ............................................................ ៥៦
គ. ការទទួលពាក្យបណ្តឹងរបស់តុលាការ ............................................................ ៥៧
ឃ. ការកោះហៅភាគីអោយចូលសវនាការ ............................................................ ៥៧
**កថាខណ្ឌទី២៖ កិច្ចនីតិវិធីនៃការជំនុំជម្រះ** ............................................................ ៥៨
ក. មុនពេលប្រកាសបើកសវនាការ ............................................................ ៥៨
ខ. ការប្រកាសបើកសវនាការ ............................................................ ៥៩
គ. កិច្ចពិភាក្សាដេញដោល ............................................................ ៥៩
គ.១ ការសួរចម្លើយជនជាប់ចោទ ............................................................ ៦០
គ.២ ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ និងសាក្សី ............................................................ ៦១
គ.៣ កំណត់ហេតុក្នុងពេលសវនាការ ............................................................ ៦២
ឃ. ការប្រកាសថយទៅពិភាក្សា ............................................................ ៦៥
**ផ្នែកទី២៖ សេចក្តីសម្រេចរបស់តុលាការជាន់ដំបូង** ............................................................ ៦៥
**កថាខណ្ឌទី១ ៖ ប្រភេទនៃសាលក្រម** ............................................................ ៦៥
ក. សាលក្រមចំពោះមុខ ............................................................ ៦៥
ខ. សាលក្រមដែលត្រូវចាត់ទុកថាចំពោះមុខ ............................................................ ៦៦
គ. សាលក្រមកំបាំងមុខ ............................................................ ៦៧
គ.១ បណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ ............................................................ ៦៨
គ.២ បុគ្គលដែលមានសិទ្ធិធ្វើបណ្តឹងទាស់ ............................................................ ៦៨
គ.៣ ទម្រង់ ............................................................ ៦៨
គ.៤ រយៈពេលធ្វើបណ្តឹងទាស់ ............................................................ ៦៩
គ.៥ អានុភាព ............................................................ ៦៩
ឃ. សាលក្រមចាត់រៀប ............................................................ ៦៩
**កថាខណ្ឌទី២៖ ការប្តឹងទៅសាលាឧទ្ធរណ៍** ............................................................ ៧២
**សេចក្តីសន្និដ្ឋាន** ............................................................ ៧៣
**អនុសាសន៍** ............................................................ ៧៤

ឯកសារយោង

ឧបសម្ព័ន្ធ

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១.លំនាំបញ្ហា

គ្រប់ប្រទេសទាំងអស់នៅលើពិភពលោកយើងនេះ ថ្វីត្បិតតែច្បាប់ជា មូលដ្ឋាននៃការកាត់បន្ថយនូវសិទ្ធិ និងសេរីភាពរបស់មនុស្សក៏ដោយ តែច្បាប់ក៏ជាមូលដ្ឋានដ៏សំខាន់ដើម្បីធានាតាមផ្លូវច្បាប់ថា ជននោះមិនត្រូវបាន បំពានលើសិទ្ធិ និងសេរីភាពដោយខុសច្បាប់នោះទេ។ គ្មានជនណាមួយត្រូវបានគេដកហូតសិទ្ធិ និងសេរីភាព របស់ខ្លួនដោយយោងតាមមូលហេតុនៃភាពត្រឹមត្រូវនៃជននោះបានឡើយ តែអស្តេរភាពនៃអំពើរបស់ជនណា មួយចំពោះសង្គមជា មូលហេតុតែមួយគត់នៃការដកហូតសិទ្ធិសេរីភាពតាមផ្លូវច្បាប់។

## ២.ចំណោទបញ្ហានៃការស្រាវជ្រាវ

ដោយយោងតាមលក្ខខណ្ឌនេះ បណ្ដឹង នឹងចំណាត់ការក្នុងរឿងក្ដីព្រហ្មទណ្ឌ និងបង្ហាញអំពើថា តើអ្វីទៅ ជាបណ្ដឹងព្រហ្មទណ្ឌ? តើអ្នកណាខ្លះជាអ្នកមានសិទ្ធិធ្វើបណ្ដឹង? តើនៅពេលពេលមានបណ្ដឹងក្នុងរឿងព្រហ្ម ទណ្ឌកើតឡើង តើស្ថាប័នតុលាការមានចំណាត់ការបែបណាទៅលើពាក្យបណ្ដឹងដែលបានទទួល?

## ៣.គោលបំណងនៃការស្រាវជ្រាវ

ការដែលជ្រើសរើសយកប្រធានបទដែលស្ដីអំពី (**បណ្ដឹង និងចំណាត់ក្នុងរឿងក្ដីព្រហ្មទណ្ឌនៅសាលាដំបូង រាជធានីខេត្ត**) មកតាក់តែងជាសារណា គឺមានគោលបំណងចង់យល់ដឹងអោយច្បាស់ទៅលើបណ្ដឹងដែលគេប្រើ ក្នុងរឿងព្រហ្មទណ្ឌនិង ចង់សិក្សាលម្អិតទៅលើការធ្វើចំណាត់ការរបស់តុលាការទៅរឿងក្ដីព្រហ្មទណ្ឌ។ ហើយចង់ អោយយល់ច្បាស់ការប្រើពាក្យបណ្ដឹងនៅ ក្នុងមួយដំណាក់កាលទៅមួយដំណាក់កាលនៃការធ្វើចំណាត់ការ របស់តុលាការ។

## ៤.ដែនកំណត់នៃការស្រាវជ្រាវ និងវិធីសាស្ត្រនៃការស្វែងរកឯកសារ

ដែនកំណត់នៃការស្រាវជ្រាវអំពីប្រធាននៃសារណានេះគឺ យើងខ្ញុំសិក្សាទៅចំណាត់ការទាំងបួនដែលអនុ វត្តក្នុងរឿងព្រហ្មទណ្ឌគឺដំណាក់កាលមន្រ្តីនគរបាលយុត្តិធម៌ដែលអនុវត្តទៅលើពាក្យបណ្ដឹង និងការអនុវត្ត បេសកម្ម។ដំណាក់កាលព្រះរជអាជ្ញា ដំណាក់កាលចៅក្រមស៊ើបសួរ និងដំណាក់ចុងក្រោយគេគឺដំណាក់កាល ជំនុំជម្រះយើងនិយាយហូតដល់ចេញសាលក្រម តែយើងបានបន្ថែមបន្តិចទៅលើការបណ្ដឹងឧទ្ធរណ៍ពីព្រោះការ ដែលចេញសាលក្រមហើយបើមានភាគីណាមិនពេញចិត្តនឹង សេចក្ដីសម្រេចអាចធ្វើការប្ដឹងទៅសាលាឧទ្ធរណ៍ បាន។

ក្នុងការស្រាវជ្រាវដើម្បីចងក្រងសារណានេះឡើង នាងខ្ញុំផ្អែកសំខាន់លើក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ជាមូលដ្ឋានបន្ថែម ជាងនេះទៅទៀតនាងខ្ញុំបានប្រមូល ពត៌មានដែលទាក់ទងតាមរយៈ អត្ថបទច្បាប់អត្ថបទ

មេរៀននានា សៀវភៅ ឯកសារផ្សេងៗ និងការសាកសួរសាស្ត្រាចារ្យណែនាំ។

## ៥.សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ការសរសេរសារណាមួយនេះ ទាមទារអោយយើងខ្ញុំប្រើពេលជាច្រើនក្នុងស្រាវជ្រាវទៅលើប្រធានបទនេះ ពីព្រោះនៅពេលដែលយើងចាប់ផ្តើមក្នុងការសរសេរ វាទាមទារអោយយើងខ្ញុំអាន សិក្សា ស្រាវជ្រាវ កត់ត្រានូវឯកសារជាច្រើនក្នុងការជំនួយដែលអោយយើងតាក់តែងសារណាមួយដោយជោគជ័យ។ ម៉្យាងទៀតប្រធានបទនេះមានសារៈសំខាន់ណាស់សំរាប់យើងខ្ញុំ ពីព្រោះប្រធានបទនេះ អាចអោយយើងដឹងកាន់តែច្បាស់ទៅលើការអនុវត្តច្បាប់នៅក្នុងសាលាដំបូងរាជធានី ខេត្ត។

## ៦.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីធ្វើការឆ្លើយតបទៅនឹងចំណោទបញ្ហាគតិយុត្តិខាងលើយើងបានធ្វើការបែងចែក និងរៀបរាប់អំពីដំណាក់កាលនីមួយអោយបានច្បាស់លាស់ ជំពូកទី១ គោលការណ៍នៃការធ្វើពាក្យបណ្តឹង ជំពូកទី២ ការអនុវត្តចំណាត់ការលើពាក្យបណ្តឹងក្នុងរឿងព្រហ្មទណ្ឌ ជំពូកទី៣ ដំណាក់កាលជំនុំជម្រះ ។

# ជំពូកទី១

# គោលការនៃការធ្វើពាក្យបណ្តឹង

## ផ្នែកទី ១៖ លក្ខខណ្ឌនៃការធ្វើពាក្យបណ្តឹង

### កថាខណ្ឌទី១៖ បណ្តឹងអាជ្ញា

#### ក. និយមន័យ

បណ្តឹងអាជ្ញា ជាបណ្តឹងសុំឲ្យផ្តន្ទាទោសពិន័យជាប្រាក់ ឬដាក់ពន្ធនាគារតាមការកំណត់ឬដាក់ពន្ធធនាគារអស់មួយជីវិត ដែលប្រព្រឹត្តអំពើដែលនាំឲ្យគ្រោះថ្នាក់ដល់សង្គម ឬ ប្រឆាំងនឹងច្បាប់ព្រហ្មទណ្ឌ។ អ្នកដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញាគឺ មានតែអង្គការអយ្យការតែប៉ុណ្ណោះ។[1]បណ្តឹងអាជ្ញាមានគោលបំណងពិនិត្យអត្ថិភាពនៃបទល្មើសបង្ហាញឲ្យឃើញពិរុទ្ធភាពនៃជនល្មើស និងផ្តន្ទាទោសជននេះតាមច្បាប់កំណត់។[2]

បណ្តឹងអាជ្ញា អនុវត្តទៅលើបុគ្គលគ្រប់រូបទាំងរូបវន្តបុគ្គល ទាំងនីតិបុគ្គល ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិឡើយ។[3]

#### ខ. ទម្រង់នៃពាក្យបណ្តឹង និង លក្ខណ្ឌនៃពាក្យបណ្តឹង

ពាក្យបណ្តឹងជាច្រើនដែលបានដាក់ទៅ ក្នុងស្ថាប័នដែលទទួលពាក្យបណ្តឹងហើយមិនមានការឆ្លើយតបវិញពីស្ថាប័នទាំងនោះដោយសារពាក្យបណ្តឹងរបស់យើងមិនត្រឹមត្រូវតាមទម្រង់ដែលបានកំណត់។ តើយើងត្រូវសរសេរពាក្យបណ្តឹងតាមទម្រង់យ៉ាង ដូចម្តេចដើម្បីអោយមានលក្ខណៈត្រឹមត្រូវតាមផ្លូវច្បាប់? ដើម្បីសេរសរពាក្យបណ្តឹងអោយមានលក្ខណៈត្រឹមត្រូវតាមផ្លូវច្បាប់យើង ត្រូវសរសេរតាមទម្រង់ខាងក្រោមនេះពាក្យបណ្តឹងក្នុងរឿងព្រហ្មទណ្ឌ។ ត្រូវសរសេរដោយទម្រង់មួយ ដែលត្រូវមាន ៖

- ឈ្មោះ អត្តសញ្ញាណ មុខរបរ លំនៅរបស់ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណី
- ស្ថាប័ន ឬអង្គភាព ដែលជនរងគ្រោះ ឬដើមបណ្តឹងត្រូវដាក់បណ្តឹងទៅ
- កម្មវត្ថុនៃបណ្តឹងដែលជនរងគ្រោះ ឬដើមបណ្តឹងស្នើសុំពីបទល្មើសដែល ជនសង្ស័យប្រព្រឹត្តមក លើខ្លួន ញាតិ ឬក្រុមគ្រួសារ
- អង្គហេតុដែលកើតឡើងតាំងពីដើមរហូតដល់កើតបទល្មើស ដែលត្រូវសរសេរបញ្ជាក់ឲ្យបានច្បាស់លាស់ដើម្បីសមត្ថកិច្ចងាយកំណត់នូវបទល្មើសដែលបានប្រព្រឹត្ត
- សំណូមពរគឺត្រូវស្នើសុំនូវចំណុចពាក់ពន្ធ័ គោលបំណងនៃការធ្វើបណ្តឹងដែលអាចប្តឹងទាំងបណ្តឹងអាជ្ញា និង

[1] មាត្រា១៣១ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

[2] មាត្រា ២ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

[3] មាត្រា ៣ ក្រមនីតិវិធីព្រហ្មទណ្ឌ

បណ្តឹងរដ្ឋប្បវេណីពីការទាមទារ ពាក់ពន្ធ័បទល្មើស។

- ជនរងគ្រោះ ឬដើមបណ្តឹងត្រូវផ្តិតមេដៃស្តាំលើពាក្យបណ្តឹងរបស់ខ្លួន។

បណ្តឹងក្នុងរឿងព្រហ្មទណ្ឌត្រូវ អនុវត្តតាមទម្រង់ខាងលើ ដើម្បីមានលក្ខណៈពេញលេញតាមផ្លូវច្បាប់។ ក៏ប៉ុន្តែក្នុងករណីមានបទល្មើសណាមួយកើតឡើង ជនរងគ្រោះឬដើមបណ្តឹងរដ្ឋប្បវេណីក៏អាចស្នើសុំឲ្យសមត្ថកិច្ចជួយសរសេរពាក្យបណ្តឹង ឬអាចពឹងមេធាវីឲ្យរៀបចំធ្វើពាក្យបណ្តឹង ដើម្បីការពារផលប្រយោជន៍ខ្លួនបានដែរ ។

**គ. ការរំលត់បណ្តឹងអាជ្ញា**

ការរំលត់នៃបណ្តឹងអាជ្ញា គឺជាការបញ្ចប់នូវការចោទប្រកាន់ពីបទព្រហ្មទណ្ឌ។ តើលក្ខណ្ឌណាខ្លះដែលបណ្តឹងអាជ្ញាត្រូវបានរំលត់ ហើយការចោទប្រកាន់ខាងបទព្រហ្មទណ្ឌមិនអាចចាប់ផ្តើមបានទៀត។ មូលហេតុនៃការរំលត់នៃបណ្តឹងអាជ្ញាមានដូចតទៅ ៖

- **មរណៈភាពនៃជនល្មើសៈ** មានន័យថាប្រសិនបើជនជាប់ចោទទទួលមរណភាពមុនពេលមានសេក្តីសម្រេចស្ថាពរផ្តន្ទាទោសជនល្មើស បណ្តឹងអាជ្ញាត្រូវរលត់។ ប៉ុន្តែបណ្តឹងរដ្ឋប្បវេណីនៅតែអាចបន្តទៀតបាន ជាមួយនឹងសន្តតិជនរបស់ជនល្មើស។

- **ការផុតអាជ្ញាយុកាលៈ** នៅពេលមានបទល្មើសកើតឡើងណាមួយកើតឡើង ចិរវេលានៃអាជ្ញាយុកាលត្រូវចាប់ផ្តើមគិតពីពេលដែលប្រព្រឹត្តបទល្មើស ហើយអាជ្ញាត្រូវផ្តាច់ទៅវិញ នៅគ្រប់កិច្ចចោទប្រកាន់ និងកិច្ចស៊ើបសួរតែនៅពេលបញ្ចប់កិច្ចស៊ើបសួរ ឬកិច្ចចោទប្រកាន់នីមួយៗនាំអោយចាប់ផ្តើមគិតចិរវេលាថ្មីនៃអាជ្ញាយុកាល។ប៉ុន្តែចំពោះបទល្មើស ឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាម **មិនអាចផុតអាជ្ញាយុកាលបានទេ**។

- **ការលើកលែងទោសជាទូទៅៈ** ការលើកលែងទោសទូទៅ គឺជាវិធានការនីតិកម្មដែលមានគោលដៅលុបចោលនូវលក្ខណៈជាបទល្មើសរបស់អំពើមួយចំនួន។ ហើយការលើលែងទោសទូទៅវាអាចពាក់ពន្ធទៅនិងទណ្ឌកម្មក្រមព្រហ្មទណ្ឌ ជាក់ស្តែង ការលើកលែងទោសជាទូទៅមានគោលបំណង ចង់បន្ថយទណ្ឌិតកុំអោយមានច្រើនពេកនៅក្នុងពន្ធនាគារ។ នៅក្នុងច្បាប់លើកលែងទោសជាទូទៅអាចពាក់ពន្ធ័ទាំងទណ្ឌកម្មព្រហ្មទណ្ឌនិងទណ្ឌកម្មរដ្ឋបាល។ ច្បាប់លើកលែងទោសជាទូទៅកំណត់ច្បាស់លាស់ពី កាលបរិច្ឆេទដែលក្នុងនោះប្រព្រឹត្តបទល្មើសត្រូវលើកលែង ឬ ពីប្រភេទនៃបទល្មើសដែលត្រូវលើកលែង ឬ ពីទោសប្រកាសដែលត្រូវលើកលែង ឬពីគុណសម្បត្តិរបស់ចារីបទល្មើសដែលត្រូវលើកលែងទោស។

- **និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌៈ** ប្រសិនបើច្បាប់ព្រហ្មទណ្ឌចាស់ ដែលកំណត់បទល្មើសណាមួយត្រូវបាននិ

រាយករណ៍ ដោយច្បាប់ថ្មីដែលលុបចោលបទល្មើសនោះបណ្ដឹងអាជ្ញាទាក់ទិននិងបទល្មើសដែលបានប្រព្រឹត្តក្នុងអំឡុងពេលដែលច្បាប់ចាស់នៅជាធរមានត្រូវរលត់។[4]

- **អាជ្ញាអស់ជំនុំ:** ប្រសិនបើក្នុងរឿងព្រហ្មទណ្ឌ តុលាការបានសម្រេចសេចក្ដីដាក់ទោសជនជាប់ចោទ នោះគឺបានសេចក្ដីថាជនជាប់ចោទមានកំហុស ហេតុដូច្នេះបណ្ដឹងរដ្ឋប្បវេណីនឹងទទួលបានជោគជ័យដោយស្វ័យប្រវត្តិ ផ្ទុយទៅវិញប្រសិនបើតុលាការសម្រេចឲ្យ ជនជាប់ចោទរួចផុតពីបទចោទប្រកាន់ ជនរងគ្រោះក៏ពុំអាចទទួលបាននូវសំណងការខូចខាតពីជនជាប់ចោទដែរ។ ប៉ុន្តែក្នុងករណីខ្លះ ទោះជាតុលាការឲ្យជនជាប់ចោទរួចផុតពីបទចោទប្រកាន់ក៏ដោយក៏ជនរងគ្រោះនៅតែអាចទទួលសំណងបានដែរ ព្រោះថាអំពើរបស់ជនជាប់ចោទពុំមែនជាបទល្មើស តែជាអំពើល្មើសផ្នែករដ្ឋប្បវេណី។

គោលការណ៍មិនអាច ជំនុំជម្រះពីរដងលើរឿងតែមួយនាំឲ្យមានផលវិបាកដូចតទៅៈ បណ្ដឹងអាជ្ញាពុំអាចធ្វើទៀតទេប្រសិនបើមានសាលក្រមតុលាការសម្រេចដោះលែង ជនជាប់ចោទចំពោះអំពើដដែលនេះ ទោះបីជាក្រោយពេលមានសាលក្រមស្ថាពរហើយ គេរកឃើញភស្តុតាងដាក់បន្ទុកថ្មីក៏ដោយ។ [5]ដោយអនុវត្តតាមគោលការណ៍អាជ្ញាអស់ជំនុំ ជនណាដែលត្រូវបានតុលាការសម្រេចឲ្យរួចខ្លួន ជននោះមិនអាចត្រូវចោទប្រកាន់ទៀតទេចំពោះអំពើដដែល ទោះបីជាក្រោមការកំណត់ឈ្មោះបទល្មើសថ្មីផ្សេងក៏ដោយ។[6]

កាលណាបណ្ដឹងអាជ្ញាត្រូវផុតរលត់ហើយ ការចោទប្រកាន់ខាងបទព្រហ្មទណ្ឌមិនអាចចាប់ផ្ដើមបានទៀតទេ ឬត្រូវតែបញ្ឈប់។[7] លើសពីនេះទៅទៀតកាលណាមានច្បាប់ដោយឡែក បានចែងដោយជាក់លាក់នោះបណ្ដឹងអាជ្ញាក៏អាចផុតរលត់បានដោយៈ

- ដោយការសម្របសម្រួលជាមួយរដ្ឋ
- ដោយការដកពាក្យបណ្ដឹង នៅក្នុងករណីដែលពាក្យបណ្ដឹងនេះជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់ជាបទព្រហ្មទណ្ឌ។
- ដោយការបង់ប្រាក់ពិន័យសរុប ឬប្រាក់ពិន័យសម្របសម្រួល។[8]

**ឃ. អាជ្ញាយុកាល**

អាជ្ញាយុកាល សំដៅលើពេលវេលាមួយជាកំណត់ដែលត្រូវបាន ទទួលស្គាល់ដោយច្បាប់ជាធរមាន។ កាលណារយៈពេលដែលច្បាប់បានកំណត់នេះផុតរលត់ នោះបុគ្គលដែលមានផលប្រយោជន៍ពាក់ពន្ធ័ នឹងបាត់បង់

[4] មាត្រា៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧
[5] សៀវភៅនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០១៣-៣០១៤ ទំព័រ៤ របស់សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត
[6] មាត្រា ១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧
[7] មាត្រា ៧ នៃក្រមនិតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧
[8] មាត្រា ៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នំ២០០៧

សិទ្ធិណាមួយរបស់ខ្លួន។ អាជ្ញាយុកាលនៃបទល្មើស ឬអាជ្ញាយុកាលនៃបណ្តឹងអាជ្ញា គឺជារយៈពេលកំណត់មួយដើម្បីអោយព្រះរាជអាជ្ញាមានសិទ្ធិក្នុងការប្តឹងចោទប្រកាន់។ កាលណារយៈពេលកំណត់នេះ បានផុតរលត់ហើយព្រះរាជអាជ្ញាពុំអាចធ្វើការប្តឹងចោទប្រកាន់ទេ។ ហើយកាលណាព្រះរាជអាជ្ញានូវតែធ្វើការប្តឹងចោទប្រកាន់ ទោះបីដឹងថា អាជ្ញាយុកាលបានរលត់ នោះបណ្តឹងអាជ្ញានឹងត្រូវបានលើកចោលដោយ ចៅក្រមស៊ើបសួរឬតុលាការជំនុំជម្រះ ហើយព្រះរាជអាជ្ញានោះនឹ ងអាចទទួលទណ្ឌកម្មវិន័យដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមតាមកម្រិតនៃទោសវិន័យ។ អាជ្ញាយុកាលនៃបទល្មើសមានចិរវេលា៖

- ១៥ ឆ្នាំចំពោះបទឧក្រិដ្ឋ
- ៥ ឆ្នាំចំពោះបទមជ្ឈឹម
- ១ ឆ្នាំចំពោះបទលហុ[9]

លើកលែងតែបទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាមមិនអាចផុតអាជ្ញាយុកាលបានទេ ព្រោះថាបទឧក្រិដ្ឋនេះគ្មានអាជ្ញាយុកាលកំណត់ឡើយ។[10]

### កថាខណ្ឌទី២៖ បណ្តឹងរដ្ឋប្បវេណី

ជនរងគ្រោះអាចដាក់ពាក្យបណ្តឹងសាមញ្ញរបស់ខ្លួន ដែលគ្មានអនុភាពនាំអោយមានការចោទប្រកាន់ជាបទល្មើសព្រហ្មទណ្ឌ។ ហើយក្នុងករណីដែលពាក្យបណ្តឹងស្ថិតនៅដោយគ្មានចម្លើយ ឬត្រូវបានតម្កល់ទុកឥតចាត់ការដោយព្រះរាជអាជ្ញាតាមរយៈការជូនដំណឹង ក្នុងកំឡុងពេលយ៉ាងយូរ ២(ពីរ)ខែគិតចាប់ពីថ្ងៃដែលបានចុះបញ្ជីពាក្យបណ្តឹង ជនរងគ្រោះអាចដាក់ពាក្យបណ្តឹងទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដែលធ្វើឡើងក្នុងកំឡុងពេល ២(ពីរ)ខែគិតចាប់ពីថ្ងៃដែលទទួលដំណឹងអំពីសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការ។ ការតវ៉ានេះត្រូវធ្វើតាមបណ្តឹងសាមញ្ញ នៅអង្គការអយ្យការដែលពាក់ព័ន្ធ។

នៅក្នុងនោះដែរជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់នៃបទល្មើសឧក្រិដ្ឋ ឬមជ្ឈិមអាចដាក់ពាក្យបណ្តឹងដោយការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខចៅក្រមស៊ើបសួរ ដោយចោទប្តឹងលើបុគ្គលបុគ្គលម្នាក់ឬច្រើន ឬប្រឆាំងនឹងអញ្ញាតជន។ ហើយបណ្តឹងនេះមានអានុភាពប្តឹងអំពីបទល្មើសព្រហ្មទណ្ឌ ឬបណ្តឹងអាជ្ញាដែលនៅក្រមស៊ើបសួរត្រូវបញ្ជូនបណ្តឹងនេះទៅព្រះរាជអាជ្ញា។បណ្តឹងរដ្ឋប្បវេណីត្រូវអនុវត្តដោយ ជនរងគ្រោះនៃបទល្មើស។ ដើម្បីទទួលការជួសជុលបានព្យសនកម្មត្រូវតែៈ

- ជាផលវិបាកផ្ទាល់នៃបទល្មើស

---

[9] មាត្រា១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[10] មាត្រា៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

- ជាព្យសនកម្មផ្ទាល់ខ្លួន
- បានកើតឡើង និងនៅក្នុងពេលបច្ចុប្បន្ន។

ព្យសនកម្មអាចជា ព្យសនកម្មខាងសម្ភារៈខាងរូបកាយ ឬខាងផ្លូវចិត្ត។[11]ព្យសនកម្មអាចត្រូវបានជួសជុលដោយការបង់ជម្ងឺចិត្ត ដោយការសងទៅជនរងគ្រោះវិញ នូវទ្រព្យសម្បត្តិដែលបានបាត់បង់ ឬដោយការធ្វើអោយដូចសភាពដើមវិញនូវទ្រព្យដែលគេបានបំផ្លិតបំផ្លាញ ឬធ្វើអោយខូចខាត។

សំណងជម្ងឺចិត្តត្រូវតែមានលក្ខណៈ ធួនល្មមជាមួយនឹងព្យសនកម្មដែលទទួលរង។ **ឧទាហរណ៍**:សុផន ត្រូវបានជនល្មើសឈ្មោះ ផានិត បានយកដំបងវាយឲ្យបែកក្បាល។ សុផនបានធ្វើការព្យាបាលអស់ប្រាក់ចំនួន ២.០០០.០០០ (ពីរលាន) រៀល ហើយគាត់ត្រូវបានឈប់សម្រាកមួយរយៈ។ ក្នុងកំឡុងពេលដែល សុផន សម្រាកនោះធ្វើអោយគាត់បានខាតបង់ពេលវេលានិងប្រាក់កាក់ក្នុងការរកស៊ីរបស់គាត់។ សុផន បានដាក់ពាក្យបណ្តឹងប្តឹងទៅឈ្មោះ ផានិត ហើយត្រូវបានព្រះរាជអាជ្ញាធ្វើបណ្តឹងអាជ្ញា និងបានចេញដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរទៅចៅក្រមស៊ើបសួរ។ បន្ទាប់មកទៀតចៅក្រមស៊ើបសួរបានធ្វើដីកាដំណោះស្រាយបញ្ជូនឈ្មោះ ផានិត ទៅជំនុំជម្រះ។ នៅដំណាក់កាលជំនុំជម្រះ សុផនដែលបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី បានប្តឹងសុំទាមទារសំណងជំងឺចិត្តថ្លៃខាតបង់ពេលវេលារកស៊ីចំនួន ២.០០០.០០០ (ពីរលាន) រៀល ហើយនិងទាមទារថ្លៃព្យាបាលចំនួន ២.០០០.០០០ (ពីរលាន) រៀល។

ដូចនេះមានន័យថា សុផន បានធ្វើបណ្តឹងរដ្ឋប្បវេណី ដែលកើតចេញពីព្យសនកម្មនៃអំពើល្មើសច្បាប់ (ហឹង្សាដោយចេតនាមានស្ថានទំងន់ទោស) របស់ជនជាប់ចោទឈ្មោះ ផានិត។[12]

ជនរងគ្រោះនៃអំពើល្មើសច្បាប់ អាចត្រូវបានធ្វើឡើងដោយអ្នកតំណាងស្របច្បាប់របស់ខ្លួនដើម្បីធ្វើបណ្តឹងរដ្ឋប្បវេណី កាលណាជនរងគ្រោះជាអនីតិជន ឬជនដែលស្ថិតនៅក្រោមរបបដែលច្បាប់បានការពារ (ជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅ និងជនដែលស្ថិតនៅក្រោមហិតូបត្ថម)។ ក្នុងករណីដែលជនរងគ្រោះបានទទួលមរណៈភាព បណ្តឹងរដ្ឋប្បវេណីអាចត្រូវបានផ្តើមធ្វើដោយសិទ្ធិវ័ន្ត។

ក្រៅពីបុគ្គលដែលបានកំណត់ខាងលើនេះ បុគ្គលខាងក្រោមត្រូវបានច្បាប់អនុញ្ញាតឲ្យធ្វើសកម្មភាពបណ្តឹងរដ្ឋប្បវេណីជំនួសជនរងគ្រោះផងនូវបុគ្គលដូចខាងក្រោមនេះ ៖

➢ សមាគមប្រយុទ្ធប្រឆាំងនឹងអំពើហឹង្សាខាងផ្លូវភេទ អំពើហឹង្សាក្នុងគ្រួសារ ឬ អំពើហឹង្សាប្រឆាំងនឹងកុមារ តែត្រូវបានគោរពនូវល័ក្ខខណ្ឌមួយគឺគ្រប់សមាគមដែលបានប្រកាសដោយត្រឹមត្រូវយ៉ាងតិចបំផុតតាំងពី ០៣(បី)

[11] មាត្រា១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[12] មាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៧

ឆ្នាំមុនពេលបរិច្ឆេទនៃបទល្មើសហើយដែលកម្មវត្ថុនៃលក្ខន្តិកៈរបស់ ខ្លួនរួមមានការតស៊ូប្រឆាំងនឹងអំពើហឹង្សាខាងផ្លូវភេទ ឬ អំពើហឹង្សាក្នុងគ្រួសារ ឬ អំពើហឹង្សាប្រឆាំងនិងកុមារនោះ អាចប្រើប្រាសសិទ្ធិដែលទទួលស្គាល់ដល់ដើមបណ្តឹងរដ្ឋប្បវេណី ចំពោះប្រភេទបទល្មើសៈ

១.ការបៀតបៀនដោយចេតនាដល់អាយុជីវិត

២.ការបៀតបៀនដល់បូរណភាពនៃបុគ្គល

៣.ការបៀតបៀនខាងផ្លូវភេទ

➢ សមាគមប្រយុទ្ធប្រឆាំងនឹងការចាប់ពង្រាត់ ការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទសមាគមដែលមានលក្ខណៈបែបនេះត្រូវបានប្រកាសដោយត្រឹមត្រូវ យ៉ាងតិចតាំងពី ០៣ (បី)ឆ្នាំមុនពេលបរិច្ឆេទនៃបទល្មើស ហើយកម្មវត្ថុនៃលក្ខន្តិកៈរួមមានការតស៊ូប្រឆាំងនឹងការចាប់ពង្រាត់ ឬ ការជួញដូរមនុស្ស និងការធ្វើអាជីវកម្មខាងផ្លូវភេទ អាចប្រើប្រាស់សិទ្ធិដែលបានទទួលស្គាល់ដោយដើមបណ្តឹងរដ្ឋប្បវេណី ចំពោះបទល្មើសដែលបញ្ញត្តិដោយច្បាប់ដែលពាក់ព័ន្ធនិងការប្រឆាំងការចាប់ពង្រាត់ ការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ។

➢ សមាគមប្រយុទ្ធប្រឆាំងនឹងការប្រកាន់ពូជសាសន៍ និងការរើសអើង ត្រូវបានប្រកាសត្រឹមត្រូវយ៉ាងតិច ០៣ (បី)ឆ្នាំមុនពេលបរិច្ឆេទនៃបទល្មើស ហើយកម្មវត្ថុនៃលក្ខន្តិកៈរួមមានការតស៊ូប្រឆាំងនឹងការប្រកាន់ពូជសាសន៍ និងការឧបត្ថមដល់ដល់ជនរងគ្រោះនៃការរើសស្តីពីដើមកំណើត ជាតិពិន្ទុ ពូជសាសន៍ សាសនា អាចប្រើប្រាស់សិទ្ធិដែលទទួលស្គាល់ដល់ដើមបណ្តឹងរដ្ឋប្បវេណី ចំពោះបទល្មើសដូចបានកំណត់ កាលណាបទល្មើសនេះ ត្រូវបានប្រព្រឹត្តដោយមូលហេតុ ដើមកំណើតជាតិនៃបុគ្គលម្នាក់ ឬដោយមូលហេតុថា បុគ្គលនោះជាសមាជិកប្រាកដ ឬដោយស្មាននៃជាតិពន្ធុ ពូជសាសន៍ ឬសាសនាណាមួយជាកំណត់ នូវការរើសអើង ការបៀតបៀនដោយចេតនាដល់អាយុជីវិត ឬដល់បូរណភាពបុគ្គល ការបំផ្លាញ ឬការធ្វើអោយខូចខាត។

ចុងចម្លើយនៃបណ្តឹងរដ្ឋប្បវេណីអាចធ្វើប្រឆាំងនឹង បុគ្គលដែលត្រូវជួសជុលព្យសនកម្មបណ្តាលមកពីបទល្មើសរួមមានៈ

- **ចារី សហចារីនៃបទល្មើសៈ** ចារី គឺជាបុគ្គលណាដែលប្រព្រឹត្តបទល្មើសដែលត្រូវចោទប្រកាន់ ហើយត្រូវចាត់ទុកថាជាចារីផងដែរ ចំពោះបុគ្គលណាដែលប៉ុនប៉ងប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ឬ ក្នុងករណីដែលច្បាប់បានចែងទុក ចំពោះបទមជ្ឈឹម។ សហចារីកាលណាបុគ្គលច្រើននាក់ បានព្រមព្រមព្រៀងគ្នាប្រព្រឹត្តបទល្មើស រួមគ្នាដោយផ្ទាល់។ ហើយត្រូវចាត់ទុកជាសហចារីផងដែរ កាលណាមានបុគ្គលច្រើននាក់បានព្រមព្រៀងប៉ុនប៉ងប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ឬ មជ្ឈឹមដោយផ្ទាល់ក្នុងករណីដែលច្បាប់បានចែងទុក។
- **អ្នកផ្តើមគំនិត អ្នកសមគំនិតៈ** ត្រូវចាត់ទុកថាជា អ្នកផ្តើមគំនិតក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈឹមចំពោះបុគ្គលណា

ដែលជំរុញឲ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមតាមការណែនាំ ឬការបញ្ជាបានបង្កឲ្យមានបទឧក្រិដ្ឋឬបទមជ្ឈិមនោះ ដោយផ្តល់អំណោយ ដោយការសន្យា ឬការគំរាមកំហែង ការញុះញង់ ការលួងលោម ឬដោយការរំលោភអាជ្ញា ឬ អំណាចរបស់ខ្លួន។ ដោយឡែកអ្នកសមគំនិត ចំពោះបុគ្គលណាដែលជួយសម្រួលដោយចេតនា ដល់ការប៉ុនប៉ង ឬ ការសម្រេចបទឧក្រិដ្ឋ ឬ បទមជ្ឈិមនោះដោយផ្តល់ជំនួយ ឬ ការឧបត្ថម្ភរបស់ខ្លួន។

- **អ្នកទទួលខុសត្រូវរដ្ឋប្បវេណីៈ** ដើមបណ្តឹងរដ្ឋប្បវេណី អាចសុំអោយមានការជួសជុលព្យសនកម្មពីសិទ្ធិវ័ន្តនៃជនជាប់ចោទបាន ប្រសិនបើជនជាប់ចោទនេះ ទទួលមរណភាពនៅក្នុងពេលដំណើរការរឿងក្តីព្រហ្មទណ្ឌ។ ហើយក្នុងករណីដែលជនជាប់ចោទជាអ្នកនីតិជន ឬ ជនដែលត្រូវបានកម្រិតនៅក្នុងសមត្ថភាព បុគ្គលដែលមានសិទ្ធិអំណាចមេបា ឬ អ្នកដែលគ្រប់គ្រង ត្រូវទទួលរួមគ្នាជាមួយនិងជនជាប់ចោទដើម្បីធ្វើការជួសជុលព្យសនកម្មដែលកើតចេញពីអំពើល្មើសនោះ។

## ផ្នែកទី២ ដំណើរការបណ្តឹងក្នុងរឿងព្រហ្មទណ្ឌ

### កថាខណ្ឌទី១ អ្នកធ្វើពាក្យបណ្តឹងក្នុងរឿងព្រហ្មទណ្ឌអោយមានចលនា

#### ក.ជនរងគ្រោះ

ដោយប្រជាពលរដ្ឋជាកោសិកានៃសង្គម នោះកោសិកាមួយនេះត្រូវបានការពារ និងបង្ក្រាប់ដោយច្បាប់នៃសង្គម តែផ្ទុយទៅវិញប្រសិនបើកោសិការបស់សង្គមមួយនេះរងនូវការបំពាន់លើសិទ្ធិ និងសេរីភាពរបស់ពួកគេពីសំណាក់នៃតតីជន តើគាត់នឹងត្រូវធ្វើយ៉ាងដូចម្តេចដើម្បីដាក់ឲ្យអំពើមួយនោះស្ថិតនៅក្រោមវិធាននៃច្បាប់? នៅក្នុងរឿងក្តីព្រហ្មទណ្ឌ ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណីមិនចាំបាច់ត្រៀមរៀបចំនួនសុំនៅឯកសារផ្សេងៗដូចក្នុងរឿងក្តីរដ្ឋប្បវេណីដែលតម្រូវឲ្យភាគីនីមួយៗស្វែងរក និងដាក់បង្ហាញនូវភស្តុតាងណាដែលបង្ហាញពីភាពត្រឹមត្រូវរបស់ខ្លួន តែក្នុងករណីព្រហ្មទណ្ឌ គាត់គាប់គួរយល់ដឹងអំពីមូលហេតុមួយចំនួន ដើម្បីឲ្យការរៀបចំនៃសំណុំរឿងរបស់ខ្លួនក្នុងការដាក់ពាក្យប្តឹងអំពីបទល្មើសមួយ ងាយស្រួលដល់ទៅមន្ត្រីមានសមត្ថកិច្ចក្នុងនោះប្រជាពលរដ្ឋ ឬអ្នករងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណីត្រូវយល់ដឹង៖

- មានការយល់ដឹងផ្នែកច្បាប់ (តើអំពើនោះជាបទល្មើសមែនឬទេ)
- ដឹងផងដែរនៃដែនសមត្ថកិច្ច និងសមត្ថកិច្ចនៃមន្ត្រីទទួលបន្ទុកចាត់ការ
- រក្សាការពារនូវវត្ថុតាងទាំងឡាយដែលបន្សល់ពីបទល្មើសដើម្បីជាការបកស្រាយអំពីបទល្មើស
- កុំប៉ះពាល់ ឬកែប្រែរាល់វត្ថុដែលពាក់ពន្ធ័នឹងបទល្មើស
- ពេលមានបទល្មើសភ្លាម ត្រូវមករាយការណ៍ភ្លាម
- ត្រូវត្រៀមខ្លួនក្នុងការចូលរួមគ្រប់នីតិវិធីតុលាការឲ្យបានសកម្ម

មូលហេតុដែលបានកំណត់ខាងលើគ្រាន់តែជាសារមួយ ដើម្បីកាត់បន្ថយនូវភាពមិនប្រក្រតីដែលកើតពីមូលហេតុនៃភាពភ័យខ្លាចនៃបទល្មើស និងបង្ករអោយមាន ការចូលរួមយ៉ាងសកម្មពីប្រជាពលរដ្ឋក្នុងការគ្រប់គ្រង បង្កកាត់បន្ថយ និងការមិនអោយបទល្មើសកើនឡើងក៏ដូចជា ការចូលរួមក្នុងការរក្សានូវតុល្យភាពសង្គមពីសំណាក់ មូលដ្ឋានផងដែរ។

**ខ. ដើមបណ្តឹងរដ្ឋប្បវេណី**

ក្នុងករណីនេះដើមបណ្តឹងរដ្ឋប្បវេណីអាចដាក់ពាក្យបណ្តឹង ទៅសមត្ថកិច្ចដើម្បីធ្វើការស៊ើបអង្កេតស្រាវជ្រាវ។ ដើមបណ្តឹងរដ្ឋប្បវេណី គឺជាបុគ្គលដែលតំណាងដោយស្របច្បាប់ឲ្យជនរងគ្រោះ។ ដើមបណ្តឹងរដ្ឋប្បវេណី មានក្នុងរឿងក្តីព្រហ្មទណ្ឌនៅពេលដែលជនរងគ្រោះនៃរឿងក្តីនោះ ជាអនីតិជន ឬជនស្ថិតនៅក្រោមរបបអាណាព្យាបាលទូទៅ ឬជនស្ថិតនៅក្រោមហិតូបត្ថម្ភ ដែលតម្រូវឲ្យអ្នកមានសិទ្ធិគ្រប់គ្រងលើជនរងគ្រោះដែលជាអនីតិជន ជនស្ថិតនៅក្រោមអាណាព្យាបាលទូទៅ ឬជនស្ថិតនៅក្រោមហិតូបត្ថម្ភ ឬសិទ្ធិវន្តរបស់ជនរងគ្រោះ អាចតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីទាមទារសំណងរដ្ឋប្បវេណីពីជនល្មើស។ ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវធ្វើឡើងក្នុងនាមផលប្រយោជន៍របស់ជនរងគ្រោះ និងអាចធ្វើនៅពេលណាក៏បាន ដរាបណាចៅក្រមមិនទាន់សម្រេចលើអង្គសេចក្តី។

**គ. មន្ត្រីនគរបាលយុត្តិធម៌**

ដោយមូលហេតុមន្ត្រីនគរបាលយុត្តិធម៌ គឺជាមន្ត្រីនៃអំណាចខាងអង្គការនីតិប្រតិបត្តិការផ្ទេរសិទ្ធិអំណាចខ្លះៗពីអង្គការនៃអំណាចតុលាការបានកំណត់ អោយមន្ត្រីនគបាលយុត្តិធម៌មានឋានៈជាជំនួយនៃស្ថាប័នតុលាការដោយផ្ទាល់ហើយក៏បានកំណត់ពី សមត្ថកិច្ចតួនាទីមួយចំនួនក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាផងដែរ។ ម្យ៉ាងទៀតមន្ត្រីនគរបាលយុត្តិធម៌ក៏ជាអ្នកដែលបាននៅជិតដិតទៅនិងប្រជាពលរដ្ឋច្រើនជាងគេ។ ស្ថាប័ននៃការរក្សាសណ្តាប់ធ្នាប់ថ្នាក់មូលដ្ឋាននៃសង្គមមួយនេះក៏មាននាទីក្នុងការទទួល បណ្តឹងដោយផ្ទាល់ដៃពីប្រជាជន។

នៅពេលដែលមន្ត្រីនគរបាលយុត្តិធម៌បានទទួលពាក្យប្តឹងពីតតីយជនឬពីជនរងគ្រោះឬដើមបណ្តឹងរដ្ឋប្បវេណីពីករណីព្រហ្មទណ្ឌណាមួយ នោះគាត់ត្រូវចាប់ផ្តើមការងាររបស់គាត់ភ្លាមដោយៈ

- បើកការស៊ើបអង្កេតលំអិតភ្លាម (បញ្ជាក់ថាតើមានអាញ្ញត្រកម្មមួយកើតមានដូចការប្តឹងដែរទេ)
- ចុះទៅកន្លែងកើតហេតុ (ដើម្បីពិនិត្យ និង ប្រមូលភស្តុតាង)
- ធ្វើកំណត់ហេតុ (តាមរយៈការសាកសួរសាក្សី ឬ ជនរងគ្រោះ និង អ្នកដែលនៅនិងកន្លែងកើតហេតុជាដើម)
- ធ្វើការកំណត់អត្តសញ្ញាណកម្មជនល្មើស
- ធ្វើការកំណត់អត្តសញ្ញាណកម្មនៃបទល្មើស

▪ ធ្វើសេចក្តីសន្និដ្ឋានបញ្ជូនទៅការិយាល័យអយ្យការដើម្បីត្រៀមធ្វើការចោទប្រកាន់

នាទីរៀបចំបណ្តឹងពី សំណាក់មន្ត្រីនគរបាលយុត្តិធម៌ វាជារឿងសំខាន់ណាស់ក្នុងការបញ្ជូនសារអំពីអស្ថេរភាពនៃសង្គមរបស់ខ្លួនដើម្បីដាក់ជូនស្ថាប័ននៃការពិនិត្យ និងចោទប្រកាន់រួមមានស្ថាប័នអយ្យការ និងស្ថាប័នតុលាការដែលជាស្ថាប័ននៃការជំនុំជម្រះវិនិច្ឆ័យស្វែងរកការពិត ដាក់ទោសចំពោះអំពើជាបទល្មើសនោះ។

### ឃ. អង្គការអយ្យការ

អង្គការអយ្យការ គឺជាស្ថាប័នតែមួយគត់ក្នុងការរក្សានូវតុល្យភាពក្នុងសង្គមដែលបណ្តាលមកពីបទល្មើស ហើយក៏ជាស្ថាប័ននៃការចោទប្រកាន់ និងអនុវត្តច្បាប់ដែលជាផ្នែកមួយតំណាងអង្គការនៃនីតិប្រតិបត្តិផងដែរ។ ម្យ៉ាងទៀតចៅក្រមនៃអង្គការដែលមានព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញារងមួយនេះ និងចៅក្រមជម្រះត្រូវបានរៀបចំដាក់នៅដាច់ដោយឡែកពីគ្នាតែប្រតិបត្តិការណ៍នៃស្ថាប័នទាំងពីរនេះ ត្រូវការបំពេញបន្ថែមឲ្យគ្នាទៅវិញទៅមកដោយមិនអាចខ្វះមួយណាបានឡើយ។

## កថាខណ្ឌ២ ស្ថាប័នដែលទទួលពាក្យបណ្តឹង

### ក. អង្គភាពនគរបាលយុត្តិធម៌

ស្ថាប័ននៃការរក្សាសណ្តាប់ធ្នាប់ថ្នាក់មូលដ្ឋាននៃសង្គមមួយនេះក៏មាន តួនាទីក្នុងការទទួលបណ្តឹងដោយផ្ទាល់ដៃពីសំណាក់មហាជនផងដែរ។ នៅពេលដែលមន្ត្រីនគរបាលយុត្តិធម៌បាន ទទួលពាក្យប្តឹងពីតតីជន ឬពីជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណីពីករណីព្រហ្មទណ្ឌណាមួយ នោះគាត់ត្រូវចាប់ផ្តើមការងាររបស់គាត់ភ្លាមដោយ៖

- បើកការស៊ើបអង្កេតលំអិតភ្លាម (បញ្ជាក់ថាតើមានអញ្ញត្រកម្មមួយកើតមានដូចការប្តឹងដែរទេ)
- ចុះទៅកន្លែងកើតហេតុ (តាមរយៈការសួរសាក្សី ឬ ជនរងគ្រោះ ។ល។)
- ធ្វើការកំណត់អត្តសញ្ញាណកម្មជនល្មើស
- ធ្វើការកំណត់អត្តសញ្ញាណបទល្មើស
- ធ្វើសេចក្តីសន្និដ្ឋានបញ្ជូនទៅការិយាល័យអយ្យការដើម្បីត្រៀមធ្វើការចោទប្រកាន់

នាទីក្នុងការរៀបចំបណ្តឹង ពីសំណាក់មន្ត្រីនគរបាលយុត្តិធម៌វាជារឿងសំខាន់ណាស់ក្នុងការបញ្ជូនឯកសារអំពីអស្ថេរភាពនៃសង្គមរបស់ខ្លួន ដើម្បីដាក់ជូនស្ថាប័ននៃការត្រួតពិនិត្យ និងចោទប្រកាន់រួមមានស្ថាប័នអយ្យការ និងស្ថាប័នតុលាការដែលជាស្ថាប័ន នៃការជម្រះវិនិច្ឆ័យស្វែងរកការពិត ដាក់ទោសចំពោះអំពើជាបទល្មើសនោះ។

### ខ. ស្ថាប័នអយ្យការ

នៅក្នុងរឿងព្រហ្មទណ្ឌ ស្ថាប័នអយ្យការក៏មាន តួនាទីទទួលពាក្យបណ្តឹងដោយផ្ទាល់ឬមិនផ្ទាល់សំណាក់

មហាជនផងដែរ។នៅពេលដែលអយ្យការបានទទួលពាក្យប្តឹងដោយផ្ទាល់ ឬមិនផ្ទាល់ពីសំណាក់តតីជន ឬពីជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណី ព្រះរាជអាជ្ញាត្រូវពិនិត្យផងដែរនូវ៖

- ពិនិត្យលើអត្ថិភាពនៃបណ្តឹង(ថាជាករណីព្រហ្មទណ្ឌដែរឬទេបើជាករណីព្រហ្មទណ្ឌមែនតើព្រះរាជអាជ្ញាគួរនឹងធ្វើការចោទប្រកាន់ ឬតំកល់រឿងទុកឥតចាត់ការ)
- ពិចារណាលើភស្តុតាងដែលមាន(ភស្តុតាងនោះមានជាប់ពាក់ពន្ធ័យ៉ាង ជិតស្និតដែរទេទៅនឹងករណីដែលប្តឹងមក)
- ធ្វើមូលវិចារក្នុងការចោទប្រកាន់
- ធ្វើដីការសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរទៅចៅក្រមស៊ើប
- រងចាំពិនិត្យ ចំពោះសេចក្តីសន្និដ្ឋានបញ្ជូនរឿងឲ្យពិនិត្យផ្ទាល់ពីចៅក្រមស៊ើប
- ធ្វើសេចក្តីសន្និដ្ឋានពិនិត្យស្ថាពរបញ្ជូនទៅចៅក្រមស៊ើប។

**បញ្ជាក់ផងដែរថា៖** បើរឿងក្តីនោះមានជាប់ពាក់ពន្ធ័ទៅនឹង មន្ត្រីក្នុងក្របខណ្ឌ ឬនៃរាជរដ្ឋាភិបាលព្រះរាជអាជ្ញាមិនអាចផ្តើមចោទប្រកាន់តាមតែចិត្តខ្លួនឯងតែម្តងទេ គឺត្រូវស្នើសុំយោបល់យល់ព្រមពីស្ថាប័នមានអំណាចនោះ ឬម្យ៉ាងទៀត ព្រះរាជអាជ្ញាអាចធ្វើសេចក្តីស្នើទៅគណៈរដ្ឋមន្ត្រីតាមរយៈ ក្រសួងយុត្តិធម៌ដើម្បីស្វែងរកការចោទប្រកាន់ផ្នែកព្រហ្មទណ្ឌ។

## កថាខណ្ឌទី៣៖ បណ្តឹងក្នុងរឿងព្រហ្មទណ្ឌ

### ក. បណ្តឹងបរិហារ

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចប្តឹងបរិហារទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬ ព្រះរាជអាជ្ញាអមសាលាដំបូងអំពីបទល្មើសដែលខ្លួនបានដឹង អាចធ្វើអធិបញ្ជាតាមការណែនាំជាលាយលក្ខណ៍អក្សរដែលត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿង ឲ្យអគ្គព្រះរាជអាជ្ញា ឬ ព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ឬធ្វើសេចក្តីសន្និដ្ឋានយ៉ាងណាតាមការដែលរដ្ឋមន្ត្រីយល់ឃើញថាជាការគួរ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មិនអាចធ្វើអធិបញ្ជាដល់អគ្គព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញាឲ្យ ធ្វើការតម្កល់ទុកឥតចាត់ការនូវរឿងក្តីព្រហ្មទណ្ឌណាមួយបានឡើយ។

### ខ.បណ្តឹងទាមទារ

បណ្តឹងទាមទារ គឺសំដៅទៅលើបណ្តឹងរបស់ប្រជាពលរដ្ឋឬជាជនរងគ្រោះនៅក្នុងបទល្មើសណាមួយនោះគាត់ប្តឹងទៅនគរបាលយុត្តិធម៌ ដើម្បីទាមទារនូវសំណងនៃការខូចខាតឬសំណងជំងឺចិត្តឬផ្តន្ទាទោសដល់ជនល្មើសដែលបានប្រព្រឹត្តបទល្មើសមកលើគាត់។ ជនរងគ្រោះឬសិទ្ធិវន្តនៃជនរងគ្រោះ ឬអង្គការសមាគមន៍ដែលច្បាប់ទទួលស្គាល់ហើយបានប្រកាសដោយត្រឹមត្រូវយ៉ាងតិចបំផុតបី(៣)ឆ្នាំនៅមិនពេលកាលបរិច្ឆេទនៃការកើត

បទល្មើសអាចដាក់ពាក្យបណ្តឹងទាមទារ ក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី ចូលមកមន្ត្រីមគរបាលយុត្តិធម៌ ដែលមានសមត្ថកិច្ចត្រួតពិត្យអត្ថិភាពនៃបទល្មើស។ ពាក្យបណ្តឹងទាមទារត្រូវមានបញ្ជាក់អំពីអង្គហេតុ នឹងកម្មវត្ថុនៃការទាមទារឲ្យបានច្បាស់លាស់។

បណ្តឹងទាមទារដែលធ្វើឡើងដោយបុគ្គលជាដើមបណ្តឹងរដ្ឋប្បវេណីនេះគឺ ជាបណ្តឹងសាមញ្ញប៉ុណ្ណោះគ្មានអានុភាពនាំអោយមាន ការចោទប្រកាន់ខាងបទល្មើសព្រហ្មទណ្ឌឡើយ។[13]មន្ត្រីនគរបាលយុត្តិធម៌ដែលទទួលបានពាក្យបណ្តឹងទាមទារត្រូវតែ ធ្វើកំណត់ហេតុស្តីពីការដាក់ពាក្យបណ្តឹងនេះ។ បន្ទាប់ពីធ្វើកំណត់ហេតុបណ្តឹង មន្ត្រីនគរបាលយុត្តិធម៌ចាប់ផ្តើម ធ្វើការស៊ើបអង្កេតបឋមដោយឯកឯងឬសុំការអនុញ្ញាតពីព្រះរាជអាជ្ញាដើមបើកការស៊ើបអង្កេតបឋម។ ក្នុងករណីខ្លះ មន្ត្រីនគរបាលយុត្តិធម៌មិនបើកការស៊ើបអង្កេតដោយខ្លួនឯងទេ។

មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែបញ្ជូនកំណត់ហេតុស្តីពីការដាក់ពាក្យបណ្តឹងនោះ ទៅឲ្យព្រះរាជអាជ្ញាដើម្បីចាត់ការបន្ត។ ក្នុងករណីមន្ត្រីនគរបាលយុត្តិធម៌ ដែលទទួលបន្ទុកចាត់ការពាក្យបណ្តឹងបានពិនិត្យឃើញថា អង្គហេតុដែលគេប្តឹងនោះ ជាបទល្មើសព្រហ្មទណ្ឌមន្ត្រីនគរបាលយុត្តិធម៌ត្រូវតែ កសាងសំណុំរឿងហើយបញ្ជូនមកអយ្យការអមសាលាដំបូង នាទីកន្លែងដែលមន្ត្រីនគរបាលយុត្តិធម៌នោះស្ថិតនៅ មន្ត្រីនគរបាលយុត្តិធម៌មិនអាចតម្កល់រឿងព្រហ្មទណ្ឌទុកឥតចាត់ការបានទេ ទោះបីជាមានការសម្រុះសម្រួលគ្នារវាងជនល្មើស នឹងជនរងគ្រោះក៏ដោយ។[14]

[13] មាត្រា ៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[14] មាត្រា ៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

# ជំពូកទី២

# ចំណាត់ការលើពាក្យបណ្តឹងក្នុងរឿងព្រហ្មទណ្ឌ

## ផ្នែកទី១៖ ការស៊ើបអង្កេតរបស់នគរបាលយុត្តិធម៌

### កថាខណ្ឌទី១៖ គោលការណ៍ទូទៅរបស់នគរបាលយុត្តិធម៌

ជាទូទៅមន្ត្រីនគរបាលយុត្តិធម៌ជាអ្នកទទួលរាល់គ្រប់បណ្តឹង ដែលប្តឹងមកស្ថាប័នខ្លួនហើយមន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើចំណាត់ការលើបណ្តឹងនោះ។ ដំណាក់កាលដំបូលនៃនគរបាលយុត្តិធម៌ គឺត្រូវធ្វើការស៊ើបអង្កេត ហើយដំណាក់កាលនេះត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យ និងការទទួលខុសត្រូវដោយព្រះរាជអាជ្ញា។

**ក.លក្ខណៈសម្បត្តិរបស់នគរបាលយុត្តធម៌**

លក្ខណៈសម្បត្តិនគរបាលយុត្តិធម៌រួមមានៈ

**១. មន្ត្រីនគរបាលយុត្តិធម៌**

- មន្ត្រីនគរបាលជាតិ មានឋានន្តរសក្តិចាប់ពីអនុសេនីយ៍ត្រីឡើងទៅ ដែលបានបំពេីការងារយ៉ាងតិចបំផុត២(ពីរ) ឆ្នាំ ក្នុងនគរបាលជាតិរួចហើយ បន្ទាប់ទទួលបានសញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌។
- នាយទាហាននៃកងរាជអាវុធហត្ថ ដែលបំពេីការងារយ៉ាងតិច២ឆ្នាំ ក្នុងកងរាជអាកងរាជអាវុធហត្ថរួចហើយ ហើយបន្ទាប់ពីបានទទួលសញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តធម៌។
- អ្នកដែលមានឋានន្តរស័ក្តិ និង មុខងារដែលមានចែងក្នុងចំនុច៣ មាត្រា៦០នៃក្រមនីតិវិធីព្រហ្មទណ្ឌ។[15]

**២. ភ្នាក់ងារនគរបាលយុត្តិធម៌**

- នាយនគរបាល និងនាយនគរបាលរង ដែមមិនមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌។
- ភ្នាក់ងារនគរបាលជាតិផ្សេងទៀត។
- នាយទាហាននៃកងរាជអាវុធហត្ថ ដែលមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌។
- យោធិនផ្សេងទៀតនៃកងរាជអាវុធហត្ថ។

ភ្នាក់ងារនគរបាលយុត្តិធម៌អាចពិនិត្យបទលហុ និងជួយដល់មន្ត្រីនគរបាលយុត្តិធម៌ ក្នុងការបំពេញមុខងាររបស់ខ្លួន។ ចំនុចនេះមិនមែនមានន័យថាឲ្យតែជានគរបាលជាតិ ឬ យោធិននៃកងរាជអាវុធហត្ថទាំងអស់សុទ្ធតែជាភ្នាក់ងារនគរបាលយុត្តិធម៌ទេ គឺអាស្រ័យទៅតាមមុខងារដែលក្រសួងសាមីផ្តល់បញ្ជីឈ្មោះអោយ។[16]

[15] មាត្រា៦០ នៃក្រមនីតីវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[16] មាត្រា៧៦ នៃក្រមនីតីវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

### ៣. មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត

ដែលច្បាប់ដោយឡែកប្រគល់អោយអំណាចឲ្យធ្វើការត្រួតពិនិត្យបទល្មើសខ្លះៗក្នុងវង្វង់សមត្ថកិច្ចរបស់ខ្លួន។ ការត្រួតពិនិត្យបទល្មើសរបស់មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដែលច្បាប់ដោយឡែកប្រគល់អំណាចឲ្យពិនិត្យបទល្មើសត្រូវដាក់អោយស្ថិតនៅ ក្រោមអំណាចព្រះរាជអាជ្ញាក្នុងពេលបំពេញមុខងារនេះ។ បែបបទនៃនីតិវីធីនៃការផ្តល់នីតិសម្បទា ត្រូវកំណត់ដោយប្រកាសរួមរវាងក្រសួងយុត្តិធម៌ និងក្រសួងពាក់ព័ន្ធ។ ចំពោះការពិនិត្យបទល្មើសមន្ត្រីរាជការ និងភ្នាក់ងារទាំងនេះធ្វើរបាយការណ៍ ហើយរបាយការណ៍នេះមានតម្លៃត្រឹមតែព័ត៌មានធម្មតាតែប៉ុណ្ណោះ។ នៅពេលបំពេញការងារមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតបានប្រព្រឹត្តកំហុសនោះត្រូវអោយដំណឹងដល់ព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរ ជូនចំពោះអគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ បន្ទាប់មកអគ្គព្រះរាជអាជ្ញាប្រកាសប្រាប់រដ្ឋមន្ត្រីដែលមានមន្ត្រី ឬភ្នាក់ងារនោះនៅក្រោមឱ វាទ ដើម្បីចាប់ផ្តើមនីតិវីធីខាងវិន័យ។ ទណ្ឌកម្មខាងវិន័យមិនមែនជាឧបសគ្គដល់ការធ្វើបណ្តឹងអាជ្ញាទេ ប្រសិនបើមានបទល្មើសត្រូវបានប្រព្រឹត្ត។[17]

### ខ.សមត្ថកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌

ព្រះរាជអាជ្ញាដឹកនាំ និងសម្របសម្រួលសកម្មភាពការងាររបស់មន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន ហើយមានអំណាចលើមន្ត្រីរាជការ និងភ្នាក់ងារដទៃទៀត កាលណា មន្ត្រីនេះបំពេញមុខងាររបស់ខ្លួនជា នគរបាលយុត្តិធម៌។ក្រៅពីនេះនគរបាលយុត្តិធម៌ក៏ត្រូវស្ថិតនៅក្រោមការឃ្លាំមើល និងការត្រួតពិនិត្យរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ផងដែរដោយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ មានសិទ្ធិអនុវត្តអំណាចខាងវិន័យទៅលើនគរបាយុត្តិធម៌ បន្ទាប់ពីមានការរាយការណ៍ពីព្រះរាជអាជ្ញាឬចៅក្រមស៊ើបសួរដោយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ប្រកាសជូនដំណឹង ដល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬក្រសួងការពារជាតិ ដើម្បីផ្តើមដំណើរការនីតិវីធីវិន័យ។

- **សមត្ថកិច្ចដែនដី**

មន្ត្រីនគរបាលយុត្តិធម៌មានសមត្ថកិច្ចនៅក្នុងព្រំដែនដី អង្គភាពដែលខ្លួនត្រូវបានចាត់តាំងឲ្យទៅបម្រើការងារ។ ការកំណត់ពី មណ្ឌលរដ្ឋបាលដែលជាដែនដីសមត្ថកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌មានបញ្ជាក់នៅក្នុងសេចក្តីសម្រេចតែងតាំងមន្ត្រីនគរបាលយុត្តិធម៌នោះហើយ សេចក្តីសម្រេចនេះត្រូវផ្តល់ដំណឹងដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។[18] ហេតុនេះហើយមន្ត្រីនគរបាលយុត្តិធម៌ ដែលត្រូវបានចាត់តាំងអោយបម្រើការងារ

[17] មាត្រា៨២ នៃក្រមនីតិវីធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[18] មាត្រា៦៧ នៃក្រមនីតិវីធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

នៅក្នុងស្រុកណាមួយនៃខេត្តណាមួយ មានសមត្ថកិច្ចដែនដីនៅនោះប៉ុណ្ណោះ។

**លើកលែងតែករណីដូចខាងក្រោមៈ**

នៅរាជធានីភ្នំពេញមន្ត្រីនគរបាលយុត្តិធម៌មានសមត្ថកិច្ចនៅ លើវិសាលភាពនៃរាជធានីភ្នំពេញទាំងមូល ទោះបីជាអង្គភាពដែលខ្លួនផ្លាស់ប្តូរទៅកាន់នោះ នៅកន្លែងណាក៏ដោយ។

**ឧទាហរណ៍ៈ** បទល្មើសបានកើតឡើងនៅខណ្ឌច្បារអំពៅ ហើយជនល្មើសនោះបានរត់ទៅខណ្ឌចំការមននោះ មន្ត្រីនគរបាលយុត្តិធម៌នៅខណ្ឌច្បារអំពៅនិងមន្ត្រីនគរបាលយុត្តិធម៌នៅខណ្ឌចំការមនអាចចាប់ជននោះបាន ដូចគ្នា។

- ការអនុញ្ញាតអោយបំពេញ ប្រតិបត្តិការនៅលើវិសាលភាពនៃ ដែនដីជាទាំងមូលដោយព្រះរាជអាជ្ញាជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ក្នុងករណី បទឧក្រិដ្ឋឬមជ្ឈិមជាក់ស្តែងប្រសិនមានការបន្ទាន់ប៉ុន្តែ ការអនុញ្ញាតនេះត្រូវតែចុះនិទ្ទេសក្នុងលិខិតស៊ើបអង្កេត របស់មន្ត្រីនគរបាលយុត្តិធម៌ នោះតែម្តង។
- ការអនុញ្ញាតអោយមន្ត្រីនគរបាលយុត្តិធម៌ បំពេញប្រតិបត្តិការនៅលើវិសាលភាពនៃ ដែនដីជាតិទាំងមូល ដោយក្នុងករណីបន្ទាន់ចៅក្រមស៊ើបសួរនិង ចេញដីការចាត់អោយស៊ើបសួរជំនួសទៅអោយមន្ត្រីនគរយុត្តិធម៌។ កាលណាមានការ ប្រតិបត្តិការនៅក្រៅមណ្ឌលរបស់ខ្លួន(ការពន្លាតសមត្ថកិច្ច)មន្ត្រីនគរបាលយុត្តិធម៌ត្រូវសុំជំនួយពីមន្ត្រីនគរបាលយុត្តិធម៌ដែលមានសមត្ថកិច្ចខាងដែនដី។ រីឯចៅក្រមដែលបានអនុញ្ញាតអោយបានពន្លាតសម្ថតកិច្ច ត្រូវជូនព័ត៌មានតាមគ្រប់មធ្យោបាយដល់ព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចខាងដែនដី។

ក្នុងករណីមានការ បំពានលើវិធានសមត្ថកិច្ចនេះកិច្ចទាំងឡាយដែល បំពេញដោយមន្ត្រីនគរបាលយុត្តិធម៌ត្រូវទុកជាមោឃៈ។[19]

- **ការកំណត់សមត្ថកិច្ច**

បទមជ្ឈិម បទលហុ កំណត់អត្តសញ្ញាណ និងចាប់ជនល្មើស ព្រមទាំងប្រមូលភស្តុតាង។ ក្នុងក្រមនីតិវិធីព្រហ្មនគរបាលយុត្តិធម៌មានសមត្ថកិច្ចធ្វើការត្រួតពិនិត្យបទឧក្រិដ្ឋកម្ម កងរាជអាវុធហត្ថក៏ជានគរបាលយុត្តិធម៌ដែរ ហេតុនេះកងរាជអាវុធហត្ថអាចបំពេញមុខងារជា នគរបាលយុត្តិធម៌នៅក្នុងគ្រប់បទល្មើសព្រហ្មទណ្ឌគ្រប់ប្រភេទ។ ប៉ុន្តែ ចំពោះបទល្មើសយោធាមានតែកងរាជអាវុធហត្ថមានគុណសម្បត្តិជានគរបាលយុត្តិធម៌។

**កថាខណ្ឌ២ បេសកម្មរបស់នគរបាលយុត្តិធម៌**

នគរបាលយុត្តិធម៌ ជាជំនួយរបស់អំណាចតុលាការនៅគ្រប់នីតិវិធីក្នុងរឿងក្តីព្រហ្មទណ្ឌដែលមានចែងនៅក្នុងក្រមនីតីវិធីព្រហ្មទណ្ឌ។ ចំណែកឯបេសកម្មរបស់មន្ត្រីនគរបាលយុត្តិធម៌សំខាន់ៗមានដូចខាងក្រោមៈ

[19] មាត្រា៦៨ នៃក្រមនីតីវីធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

**ក.ការទទួលពាក្យបណ្តឹង**

មន្ត្រីនគរបាលយុត្តិធម៌ ជាអ្នកទទួលពាក្យបណ្តឹងក្នុងរឿងក្តីព្រហ្មទណ្ឌទាំងបណ្តឹងទាមទារនិងបណ្តឹងបរិហារ។[20] ករណីអ្នកប្តឹងមិនចេះភាសាខ្មែរ មន្ត្រីនគរបាលយុត្តិត្រូវរកអ្នកបកប្រែ ដែលមិនមែនជាមន្ត្រីនគរបាល ឬកងរាជអាវុធហត្ថដែលជាកងកម្លាំងចូលរួមប្រតិបត្តិការណ៍នោះបានឡើយ។ នៅពេលទទួលពាក្យបណ្តឹង មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុទទួលពាក្យបណ្តឹង ដែលមានបញ្ជាក់អត្តសញ្ញាណរបស់អ្នកប្តឹង កាលបរិច្ឆេទនៃការទទួលពាក្យបណ្តឹង អង្គភាពរបស់មន្ត្រីនគរបាលយុត្តិធម៌ ហើយកំណត់ហេតុនៅទំព័រនីមួយៗ ត្រូវចុះហត្ថលេខាដោយមន្ត្រីនគរបាលយុត្តិធម៌ និងដោយអ្នកប្តឹង។ ហើយអ្នកប្តឹងមុននឹងចុះហត្ថលេខាឬផ្តិតម្រាមដៃរាល់គ្រប់កំណត់ហេតុត្រូវអានកំណត់ហេតុឡើងវិញ ក្នុងករណីអ្នកប្តឹងមិនចេះអក្សរ មន្ត្រីនគរបាលយុត្តិធម៌ត្រូវអាននូវខ្លឹមសារកំណត់ហេតុដោយសម្លេងខ្លាំងៗ។ នៅពេលដែលមានការឆូត ការថែម និងការយោងត្រូវតែមានការបញ្ជាក់ដោយមានការចុះហត្ថលេខារបស់មន្ត្រីនគរបាលយុត្តិធម៌ និងអ្នកប្តឹងនៅរឹមទំព័រ។ [21]

**ខ.ការពិនិត្យបទល្មើស**

ការពិនិត្យបទល្មើស មានន័យថានៅពេលដែលមន្ត្រីនគរបាលយុត្តិឃើញបទល្មើសព្រហ្មទណ្ឌណាមួយកើតឡើង គាត់មានសិទ្ធិធ្វើកិច្ចការនេះដោយខ្លួនឯង ទោះបីគ្មានអ្នកប្តឹងក៏ដោយ លើកលែងតែមានបទល្មើសមួយចំនួនប៉ុណ្ណោះ ដូចជាបទបរិហាកេរ្តិ៍ជាសាធារណៈ បទជេរប្រមាថជាសាធារណៈ បទហិង្សាក្នុងគ្រួសារ.......។

**គ.ការស៊ើបអង្កេត**

ក្រោយពីការទទួលពាក្យបណ្តឹង ហើយមន្ត្រីនគរបាលយុត្តិធម៌ត្រូវតែរាយការណ៍ទៅព្រះរាជអាជ្ញាឬសុំសេចក្តីការណែនាំពីព្រះរាជាអាជ្ញាដើម្បីធ្វើចំណាត់លើពាក្យបណ្តឹង មន្ត្រីនគរបាលយុត្តិធម៌គ្មានសិទ្ធតម្កល់រឿងទុកឥតចាត់ការបានទេ ទោះបីមានសម្រុះសម្រួលគ្នារវាងជនល្មើស ឬជនរងគ្រោះ ឬក៏មានការដកពាក្យបណ្តឹងរបស់ជនរងគ្រោះក៏ដោយ។ នៅបំពេញបេសកម្មស៊ើបអង្កេត អំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ខុសគ្នា ទៅតាមពេលដែលមន្ត្រីនោះបំពីការ ក្នុងក្របខណ្ឌនៃការស៊ើបអង្កេតជាក់ស្តែង ឬក្នុងការស៊ើបអង្កេតបឋម។[22]

**គ.១ នីតិវិធីការស៊ើបអង្កេតបទល្មើសជាក់ស្តែង**

ការស៊ើបអង្កេតករណីជាក់ស្តងត្រូវបើក ក្នុងករណីមានបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង។ មានន័យថាបទឧក្រិដ្ឋ និងមជ្ឈិមជាក់ស្តែងគឺ ជាបទល្មើសដែលកំពុងប្រព្រឹត្ត បទល្មើសដែលទើបប្រព្រឹត្តរួចភ្លាម។ ត្រូវចាត់ទុកថា

[20] មាត្រា៧១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[21] មាត្រា៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[22] មាត្រា៨៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងដែរ កាលណានៅក្រោយពេលមានបទល្មើសរួចបន្តិចមក ជនសង្ស័យត្រូវបានសាធារណៈជនស្រែកដេញប្រដាប់ចាប់ប្រភីង ឬក៏បុគ្គលនោះរកឃើញមានវត្ថុ ឬមានស្លាកស្នាម ឬក៏មានតម្រុយច្បាស់លាស់ហើយស៊ីសង្វាក់ផ្សេងទៀត ដែលនាំអោយគេសន្និដ្ឋានបានថា បុគ្គលនោះបានប្រព្រឹត្ត ឬបានចូលរួមប្រព្រឹត្តបទល្មើស។ ត្រូវបានចាត់ទុកដូចជាបទឧក្រិដ្ឋ ឬមជ្ឈិមជាក់ស្តែង គ្រប់បទឧក្រិដ្ឋ ឬមជ្ឈិមជាក់ស្តែងទាំងឡាយណាដែលត្រូវបានប្រព្រឹត្តនៅក្នុងកន្លែងដែលអ្នកកាន់កាប់នៅទីកន្លែងនោះ សុំអោយព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ចូលមកពិនិត្យ ឬភ្នាក់ងារនគរបាលយុត្តិធម៌ ក្នុងករណីគ្មានវត្តមានមន្ត្រីនគរបាលនៅទីកន្លែងនោះ តែនៅពេលបញ្ចប់ភារៈកិច្ចភ្នាក់ងារនគរបាលយុត្តិធម៌ ត្រូវរាយការណ៍បន្ទាន់ទៅមន្ត្រីនគរបាលយុត្តិធម៌។[23] ហើយថិរវេលានៃការស៊ើបអង្កេតបទល្មើសជាក់ស្តែង ទៅលើបទល្មើសដែលមានថិរវេលាមិនលើសរយៈពេល៧(ប្រាំពីរ)ថ្ងៃគិតពីថ្ងៃដែលបទល្មើសបានកើតឡើង។ កិច្ចនៃការស៊ើបអង្កេតត្រូវប្រព្រឹត្តទៅជាប់ជានិច្ចក្នុងថេរវេលានេះប្រសិនមិនបញ្ចប់ក្នុងថិរវេលា៧(ប្រាំពីរ)ថ្ងៃនេះទេ នោះមន្ត្រីនគរបាលត្រូវស្នើសុំយោបល់ទៅព្រះរាជអាជ្ញាដើម្បីបើកការស៊ើបអង្កេតបឋម។

**គ.១.១ការរាយការណ៍ទៅព្រះរាជអាជ្ញា**

ក្នុងករណីបទឧក្រិដ្ឋ ឬមជ្ឈិមជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ភ្លាមទៅជូនព្រះរាជអាជ្ញា និងចុះទៅកកាន់ទីន្លែងកើតហេតុ ដើម្បីធ្វើការពិនិត្យបទល្មើស និងធានារក្សាទុកតម្រុយនៃភស្តុតាងទាំងឡាយណាដែលអាចងាយបាត់បង់ និងអាចចាប់យកវត្ថុតាង។ មន្ត្រីគរបាលយុត្តិធម៌អាចហាមឃាត់បុគ្គលគ្រប់រូបកុំអោយទៅទីកន្លែងណាឆ្ងាយ ពីកន្លែងកើតហេតុដែលខ្លួនយល់ឃើញថាបុគ្គលនោះអាចផ្តល់តម្រុយអោយខ្លួនក្នុងការស្វែងរកការពិតបាន រហូតដល់ពេលបញ្ចប់ប្រតិបត្តិការរបស់ខ្លួន។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុស្តីពីការស្រាវជ្រាវ និងការពិនិត្យរបស់ខ្លួន។[24]គ្រប់បុគ្គលដែល សង្ស័យថាបានចូលរួមក្នុងប្រព្រឹត្តបទល្មើសមន្ត្រីនគរបាលយុត្តិធម៌ អាចហៅ និងនាំខ្លួនមមកាន់អង្គភាពខ្លួនបាន ហើយមន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការស្តាប់ចម្លើយជនទាំងនោះ ការស្តាប់ចម្លើយនេះមន្ត្រីនគរបាលយុត្តិត្រូវធ្វើកំណត់ហេតុ ក្នុងករណីចាំបាច់មន្ត្រីនគរបាលយុត្តិធម៌អាចរកអ្នកបកប្រែភាសា ដែលត្រូវស្បថថានិយាយតែការពិតស្របតាមជំនឿ ឬសាសនារបស់ខ្លួន មិនតែប៉ុណ្ណោះអ្នកបកប្រែមិនត្រូវជ្រើសរើសចេញពីនគរបាល ឬកងរាជអាវុធហត្ថ ឬបុគ្គលដែលទាក់ទិនរឿងជាមួយគ្នាបានទេ។ នៅលើទំព័រនីមួយៗនៃកំណត់ហេតុត្រូវចុះហត្ថលេខា ឬផ្តិតម្រាមដៃរបស់បុគ្គលដែលផ្តល់ចម្លើយ តែបើ

[23] មាត្រា៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[24] មាត្រា៨៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

បុគ្គលនោះមិនព្រមចុះហត្ថលេខា ឬផ្តិតស្រាមដៃទេមន្ត្រីនគរត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុ។[25]ក្នុងករណីការបញ្ជាអោយចូលខ្លួនមន្ត្រីនគរបាលយុត្តិធម៌អាចកោះហៅ និងស្តាប់ចម្លើយបុគ្គលគ្រប់រូបដែលអាចផ្តល់ព័ត៌មានស្តីអំពីរឿងហេតុ។ បុគ្គលដែលកោះហៅត្រូវតែចូលបង្ហាញខ្លួន ក្នុងករណីរឹងទទឹងមន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា ដែលអាចចេញបញ្ជាអោយចូលខ្លួនបាន ហើយបញ្ជានេះត្រូវមានអត្តសញ្ញាណរបស់បុគ្គលដែលពាក់ព័ន្ធ មានការចុះការបរិច្ឆេទ និងហត្ថលេខាដោយព្រះរាជអាជ្ញា និងបោះត្រា។ ការបញ្ជាអោយខ្លួននេះ អនុញ្ញាតអោយមន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់កម្លាំងសាធារណៈដើម្បីបង្ខំបុគ្គលនោះអោយចូលខ្លួន។

**គ.១.២ ការចុះឆែកឆេរ**

មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរបានដោយត្រូវទទួលជាបឋមនូវការអនុញ្ញាតពី ព្រះរាជអាជ្ញាដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ទោះបីជាការអនុញ្ញាតនោះធ្វើដោយផ្ទាល់មាត់ក៏ដោយ។ **ឧទាហរណ៍:** មន្ត្រីនគរបាលយុត្តិធម៌នៅខេត្តកំពង់ចាមបានចុះឆែកឆេរ ក្នុងករណីបទល្មើសជាក់ស្តែង ដូចនេះមន្ត្រីនគរបាលយុត្តិធម៌ត្រូវសុំការអនុញ្ញាតជាបឋមពី ព្រះរាជអាជ្ញានៅខេត្តកំពង់ចាមដោយផ្ទាល់មាត់ក្នុងការឆែកឆេរ។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការឆែកឆេរត្រូវធ្វើ ចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ទីកន្លែងត្រូវធ្វើនៅចំពោះមុខសាក្សីពីររូប ដែលតែងតាំងដោយមន្ត្រីនគរបាលយុត្តិធម៌ ចំណែកឯសាក្សីនោះមិនអាចជានគរបាល ឬក៏ជាកងរាជអាវុធហត្ថ ដែលជាកម្លាំងរួមប្រតិបត្តិការក្នុងឆែកឆេរនោះបានឡើយ។ ការអនុវត្តការឆែកឆេររបស់មន្ត្រីនគរបាលយុត្តិធម៌មិនអាចធ្វើការឆែកឆេរមុនម៉ោង(ប្រាំមួយ)ព្រឹក និងក្រោយម៉ោង១៨(ដប់ប្រាំបី)ល្ងាច។ តែការអនុវត្តចិរវេលានេះក៏មានករណីលើកលែងដែរមានដូចខាងក្រោម:

- ករណីបទឧក្រិដ្ឋ ឬមជ្ឈិមជាក់ស្តែង និងករណីចាត់ទុកដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង
- ករណីមានសម្រែកស្រែកអោយជួយពីក្នុងទីកន្លែង
- ករណីឆែកឆេរនៅទីកន្លែងក្នុងពេលម៉ោងដែលបើកចំហដល់សាធារណៈជន
- ករណីឆែកឆេរនៅគ្រប់ទីកន្លែងដែលផលិត រក្សាទុក ជួយដូរ ចែកចាយ ប្រើប្រាស់គ្រឿងញៀន។

រាល់ប្រតិបត្តិនៃការឆែកឆេរ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុស្តីពីការឆែកឆេរ ដែលក្នុងនោះមានចុះការអនុញ្ញាតរបស់ព្រះរាជអាជ្ញាដោយប្រាប់ថ្ងៃ និងម៉ោងនៃការអនុញ្ញាត ព្រមទាំងមានអត្តសញ្ញាណរបស់អ្នកកាន់កាប់ទីកន្លែង ឬរបស់សាក្សីនីមួយៗ។ មន្ត្រីនគរបាលយុត្តិធម៌ មិនអាចធ្វើការឆែកឆេរនៅក្នុងការិយាល័យមេធាវីបានទេ មានតែព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរតែប៉ុណ្ណោះ ដែលអាចធ្វើការឆែកឆេរនេះបាន នៅចំពោះមុខប្រធានគណៈមេធាវី ឬប្រតិភូរបស់ប្រគណៈមេធាវី ឬមេធាវីសាមី។

[25] មាត្រា៩៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ចំណែកឯ ការឆែកឆេរនៅក្នុងអគារសារព័ត៌មាន សហគ្រាសនៃសារព័ត៌មានសរសេរ ឬ សហគ្រាសសារព័ត៌មានសោតទស្សន៍បាន មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើ តែចំពោះមុខព្រះរាជអាជ្ញាឬចៅក្រមស៊ើបសួរម្នាក់ដែលធានារ៉ាប់រងកុំអោយការឆែកឆេរនេះ ប៉ះពាល់ការប្រកបដោយសេរីនូវមុខរបរអ្នកសារព័ត៌មាន និងធ្វើអោយ មានយឺតយ៉ាវដល់ការផ្សព្វផ្សាយព័ត៌មាននេះដោយមិនត្រឹមត្រូវ។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែ គោរពវិធានការណ៍ក្នុងការឆែកឆេរខាងលើជាដាច់ខាតបើមិនដូចច្នេះទេនីតិវិធីដែលមន្ត្រីនគរបាលយុត្តិធម៌អនុវត្តក្នុងការឆែកឆេរខាងលើត្រូវទុកជាមោឃៈ។[26]

**គ.១.៣ ការស្វែងរកភស្តុតាង**

ក្នុងការស្វែងរកភស្តុតាងវាចំណែកមួយយ៉ាងសំខាន់ក្នុងការស្វែងរក យុត្តិធម៌អោយជនរងគ្រោះ ឬក៏ស្វែងរកភាពបរិសុទ្ធអោយជនដែល គ្មានកំហុសកត្តានេះហើយ បានជានៅដែលមានពាក្យបណ្តឹងដែលប្តឹងមកមន្ត្រីនគរបាលយុត្តិធម៌ មន្ត្រីដែលទទួលពាក្យបណ្តឹងត្រូវធ្វើចំណាត់ការភ្លាមៗ ទៅលើពាក្យបណ្តឹងនោះដោយមន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ទៅព្រះរាជអាជ្ញា បន្ទាប់មកត្រូវធ្វើការឆែកឆេរ នៅពេលដែលការឆែកឆេរស្របតាមច្បាប់មន្ត្រីនគរបាលយុត្តិធម៌ អាចចាប់វត្ថុតាងដែលមានប្រយោជន៍ក្នុងសំនុំរឿង ដោយការចាប់យកនោះត្រូវបិទស្លាកបោះត្រានៅលើវត្ថុតាង។ ក្រោយមកមន្ត្រីនគរបាលយុត្តិធម៌ត្រូវបង្ហាញវត្ថុដែលបានចាប់យកទៅ អ្នកកាន់កាប់ទីកន្លែងឬ ដល់សាក្សីពីររូបមើលរួច មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុស្តីពីការចាប់យកដែលរួមមាន បញ្ជីសារពើភ័ណ្ឌនៃ វត្ថុតាងដែលចាប់យក។ កំណត់ហេតុស្តីពីការចាប់យកត្រូវចុះហត្ថលេខា ឬផ្តិតម្រាមដៃដោយអ្នកកាន់កាប់ទីកន្លែង ឬដោយសាក្សីពីរនាក់។[27]

ក្នុងករណីនេះ ព្រះរាជអាជ្ញាមានសមត្ថកិច្ចអាចបង្គាប់អោយប្រគល់វត្ថុចាប់បាន ទៅម្ចាស់ដើមវិញប្រសិនវត្ថុនោះពុំមានប្រយោជន៍សម្រាប់សម្តែងការពិតទេនោះ ហើយប្រសិនបើកម្មសិទ្ធិលើវត្ថុនោះ គ្មានការជំទាស់អ្វីប្រាកដប្រជាទេ ហើយវត្ថុនោះពុំមែនជាវត្ថុដែលមានគ្រោះថ្នាក់ចំពោះមនុស្ស ឬទ្រព្យសម្បត្តិទេប្រសិនបើព្រះរាជាអាជ្ញាពុំព្រមប្រគល់អោយវិញទេ ម្ចាស់វត្ថុអាចប្តឹងសុំអោយប្រគល់វត្ថុចាប់បាន អាចប្តឹងតវ៉ាទៅអគ្គព្រះរាជាអាជ្ញាបាន។ ប៉ុន្តែបើ វត្ថុដែលចាប់យកនោះជាវត្ថុដែលគ្រោះថ្នាក់ចំពោះមនុស្ស ឬចំពោះទ្រព្យសម្បត្តិខុសច្បាប់ដូចជាអាវុធ ឬក៏ជាតិផ្ទុះ មិនត្រូវប្រគល់អោយវិញបានទេ តែវត្ថុទាំងត្រូវរឹបអូសជាសម្បត្តិរដ្ឋ ឬត្រូវបំផ្លាញចោល។ មន្ត្រីនគរបាលយុត្តិធម៌ធានារ៉ាប់រងរក្សាទុកនូវតម្រុយនៃភស្តុតាងទាំងឡាយដែលអាចបាត់បង់។ ក្រៅពីវត្ថុក៏មានការបំភ្លឺដោយសម្តីដែលមានតម្លៃអាចចាត់ជាភស្តុតាងបានដែល ដូចជាការបំភ្លឺរបស់សាក្សីភាគីដែលពាក់ពន្ធ័។ ការ

[26] មាត្រា៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[27] មាត្រា៩២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ស្វែងករភស្តុតាងរបស់មន្ត្រីនគរបាលយុត្តិធម៌ក៏ត្រូវបានហាមឃាត់ក្នុងការ បង្គាប់មិនអោយស្តាប់ និងថតសម្លេងការសន្ទនាតាមទូរស័ព្ទ។ មន្ត្រីនគរបាលយុត្តិធម៌ ពុំមានអំណាចបង្គាប់អោយចាប់ និងថតសម្លេងតាមការឆ្លើយឆ្លងដែលចេញតាមមធ្យោបាយទូរគមនាគមន៍ ជាអាទិ៍ សារតាមទូរសារ ឬ សារតាមអិនធើណែត។[28]

**គ.១.៤ ការអនុវត្តការឃាត់ខ្លួន**

មន្ត្រីនគរបាលយុត្តិធម៌អាចឃាត់ ខ្លួនគ្រប់បុគ្គលដែលសង្ស័យថា បានប្រព្រឹត្តបទល្មើសនិងបានចូលរួមប្រព្រឹត្តបទល្មើសបញ្ជូនទៅអង្គភាពរបស់ខ្លួនបាន។ ក្រៅពីមន្ត្រីនគរបាលយុត្តិធម៌ នៅក្នុងករណីបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង បុគ្គលទាំងអស់អាចចាប់ខ្លួនជនល្មើស ហើយនាំខ្លួនជននោះ ទៅប្រគល់ជូនមន្ត្រីនគរបាលយុត្តិធម៌ដែល នៅជិតបំផុត។[29] មន្ត្រីនគរបាលយុត្តិធម៌ក៏អាចឃាត់ខ្លួនបុគ្គលដែលអាចផ្តល់ព័ត៌មានស្តីអំពីរឿងហេតុបានដែរ លុះត្រាតែបុគ្គលដែលអាចផ្តល់ព័ត៌មានប្រកែកមិនព្រមផ្តល់ព័ត៌មាន និងមានការយល់ព្រមជាលាយលក្ខណ៍អក្សរអោយ ធ្វើការឃាត់ខ្លួនពីព្រះរាជអាជ្ញា។ នៅពេលដែលមានការឃាត់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការរាយការណ៍ទៅព្រះរាជអាជ្ញាភ្លាម ព្រមទាំងបញ្ជូនគ្រប់ភស្តុតាងទាំងអស់ដែលត្រូវអោយមានការឃាត់ខ្លួននេះ។ នៅពេលដែលឃាត់ខ្លួនបុគ្គល ណាម្នាក់មន្ត្រីនគរបាលយុត្តិធម៌ត្រូវអោយ ដំណឹងជាបន្ទាន់អំពីសេចក្តីសម្រេចរបស់ខ្លួនដល់បុគ្គលនោះ ដោយប្រាប់អោយដឹងពីមូលហេតុនៃសេចក្តីសម្រេចឃាត់ខ្លួន និងប្រាប់ដល់សាមីខ្លួនអោយដឹងពីសិទ្ធិរបស់ខ្លួនដែលត្រូវទទួលបានក្នុងដំណាក់កាល នៃការឃាត់ខ្លួន។[30] បុគ្គលដែលឃាត់ខ្លួនអាច មិនឆ្លើយសំនួររបស់ មន្ត្រីនគរបាលយុត្តិធម៌បានក្រោយរយៈពេល២៤ម៉ោងបានកន្លងផុតទៅតាំងពីពេលផ្តើមការឃាត់ខ្លួនមកនោះបុគ្គលដែលឃាត់ខ្លួនអាចសុំសន្ទនាជាមួយមេធាវី ឬជាមួយជនណាម្នាក់ដែលខ្លួនជ្រើសរើស កុំអោយតែជននេះមានការទាក់ទិននៅក្នុងរឿងជាមួយគ្នា ហើយជននេះត្រូវទទួលដំណឹងពីការស្នើសុំជ្រើសរើស តាមគ្រប់មធ្យោបាយ និងជាបន្ទាន់ នៅពេលទៅដល់ទីកន្លែងបុគ្គលដែលឃាត់ខ្លួន និងការសន្ទនាគ្នាមានរយៈពេល៣០(សាមសិប)នាទី ចំណែកឯការសន្ទនាត្រូវធានាដោយការសម្ងាត់។ ប៉ុន្តែបើការឃាត់ខ្លួន ចំពោះអនីតិជនមន្ត្រីនគរបាលយុត្តិធម៌ត្រូវ ជូនដំណឹងជាបន្ទាន់ទៅ ឪពុកម្តាយអ្នកតំណាងស្របច្បាប់ ឬដល់អ្នកទទួលភារកិច្ចលើអនីតិជន។[31] ចំណែកឯ ថិរវេលានៃការឃាត់ខ្លួនរបស់និតីជន និងអនីតិជនមានលក្ខណៈមិនដូចគ្នាទេចំពោះបទឧក្រិដ្ឋ និងមជ្ឈិមជាក់ស្តែង។ ការឃាត់ខ្លួនមានថិរវេលា ៤៨(សែសិបប្រាំបី)ម៉ោង គិត

[28] មាត្រា១០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[29] មាត្រា៨៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[30] មាត្រា៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[31] មាត្រា៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ចាប់ពីម៉ោងដែលសាមីខ្លួនមកដល់អង្គភាពកងរាជអាវុធហត្ថឬនគរបាល។ ប៉ុន្តែចំពោះបទឧក្រិដ្ឋ កាលណាមានតម្រុយដែលបង្ហាញ អោយឃើញថាមានពិរុទ្ធភាពលើបុគ្គលដែលឃាត់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌អាច ពន្យារការឃាត់ខ្លួនបាន ប្រសិនបើវិធានការនេះជាការចាំបាច់ ដើម្បីអោយការស៊ើបអង្កេតប្រព្រឹត្តទៅបានល្អ ការពន្យារពេលនេះត្រូវសុំទៅព្រះរាជអាជ្ញា ដែលផ្ទៀងផ្ទាត់មើលមូលភាព។ ហើយការអនុញ្ញាតអោយពន្យារពេល ត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ ត្រូវដាក់បញ្ចូលគ្នាទៅក្នុងសំណុំរឿង ។ការពន្យារពេលនេះមិនអាចអោយលើសពី២៤(ម្ភៃបួន)ម៉ោងឡើយ ដោយមិនគិតពីថិរវេលាចាំបាច់ក្នុងការដឹកជញ្ជូន។

ហើយការពន្យារពេលនៃឃាត់ខ្លួនមិនត្រូវធ្វើ ចំពោះអនីតិជនបានទេ។

ថិរវេលានៃការឃាត់ខ្លួនទៅលើអនីតិជន ប្រែប្រួលទៅតាមប្រភេទនៃបទល្មើសៈ

- **ចំពោះបទឧក្រិដ្ឋ**

- អនីតិជនដែលមានអាយុពី ១៤ឆ្នាំ ដល់ក្រោម១៦ឆ្នាំមិនត្រូវឃាត់ខ្លួនហួសរយៈពេល៣៦ម៉ោង
- អនីតិជនដែលមានអាយុពី ១៦ឆ្នាំ ដល់ក្រោម១៨ឆ្នាំមិនត្រូវឃាត់ខ្លួនហួសរយៈពេល៤៨ម៉ោង

- **ចំពោះបទមជ្ឈិម**

- អនីតិជនដែលមានអាយុពី ១៤ឆ្នាំ ដល់ក្រោម១៦ឆ្នាំមិនត្រូវឃាត់ខ្លួនហួសរយៈពេល២៤ម៉ោង
- អនីតិជនដែលមានអាយុពី ១៦ឆ្នាំ ដល់ក្រោម១៨ឆ្នាំមិនត្រូវឃាត់ខ្លួនហួសរយៈពេល៣៦ម៉ោង

អនីតិជនដែលមានអាយុក្រោម១៤ ឆ្នាំពុំអាចត្រូវបានឃាត់ខ្លួនបានឡើយ។[32]

នៅពេលបុគ្គលដែលឃាត់ខ្លួនមានស្ថានភាពសុខភាពមិនសូវល្អ ព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ អាចសុំអោយគ្រូពេទ្យមកពិនិត្យបុគ្គលដែលឃាតខ្លួនបានគ្រប់ពេលវេលា។ គ្រូពេទ្យផ្ទៀងផ្ទាត់មើលថា តើស្ថានភាពសុខភាពបុគ្គលនោះគួរតែអាចឃាត់ខ្លួនបន្ត ឬក៏អាចអោយសម្រាកនៅមន្ទីរពេទ្យ។ ប្រសិនបើគ្រូពេទ្យយល់ឃើញពីស្ថានភាពសុខភាពរបស់បុគ្គលនោះ ពុំសមស្របជាមួយនឹងការឃាត់ខ្លួនទេ នោះគ្រូពេទ្យត្រូវចេញ វិញ្ញាបនបត្របញ្ជាក់សុខភាពទៅអោយមន្ត្រីនគរបាលយុត្តិធម៌រាយការណ៍ជាបន្ទាន់ដល់ព្រះរាជអាជ្ញា។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវ ចុះនិទ្ទេសនៅកំណត់ហេតុអំពីឈ្មោះរបស់គ្រូពេទ្យ ព្រមទាំងថ្ងៃ ខែ ឆ្នាំ និងម៉ោងនៃ ការពិនិត្យសុខភាព។ព្រះរាជអាជ្ញាអាចចុះទៅ កាន់ទីកន្លែងផ្ទាល់ ដើម្បីផ្ទៀងផ្ទាត់លក្ខខណ្ឌនៃការឃាត់ខ្លួន។[33]

គ្រប់ការឃាត់ខ្លួនត្រូវធ្វើកំណត់ហេតុសរុប ដោយមានឈ្មោះ និងឋានៈមន្ត្រីនគរបាលយុត្តិធម៌ដែលបង្គាប់

[32] មាត្រា៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[33] មាត្រា៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

អោយធ្វើការឃាត់ខ្លួន,អត្តសញ្ញាណរបស់បុគ្គលដែលឃាត់ខ្លួន,មូលហេតុនៃការឃាត់ខ្លួន, ថ្ងៃ ខែ ឆ្នាំ និងម៉ោងដែលចាប់ផ្តើមឃាត់ខ្លួនរបស់គ្រូពេទ្យដែលបានដែលបានពិនិត្យបុគ្គលឃាត់ខ្លួន (ក្នុងករណីសុខភាពបុគ្គលឃាត់ខ្លួនមិនល្អ)ឈ្មោះ និងឋានៈរបស់ចៅក្រមដែលបានអនុញ្ញាតអោយបន្តការឃាត់ខ្លួន បែបបទនៃការជូនដំណឹងដល់ព្រះរាជអាជ្ញា អត្តសញ្ញាណរបស់ជនដែលបានសន្ទនាជាមួយបុគ្គល ដែលឃាត់ខ្លួនប្រភេទសេចក្តីសម្រេចរបស់អាជ្ញាធរតុលាការនៅ ពេលបញ្ចប់ការឃាត់ខ្លួន លក្ខខណ្ឌនៃការប្រព្រឹត្តិទៅនៃការឃាត់ខ្លួន។ កំណត់ហេតុសរុបនៃការឃាត់ខ្លួនត្រូវភ្ជាប់ជាមួយសំណុំរឿង។ នៅក្នុងកន្លែងនីមួយៗ របស់នគរបាល ឬកងរាជអាវុធហត្ថ ដែលសម្រាប់ទទួលជនដែលត្រូវឃាត់ខ្លួនត្រូវមានបញ្ជីស្តីពីការឃាត់ខ្លួនមួយ។[34] នៅក្រោយពេលបញ្ចប់ចិរវេលានៃការឃាត់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនខ្លួនបុគ្គលដែលត្រូវឃាត់ខ្លួននោះទៅព្រះរាជអាជ្ញា ឬដោះលែងបុគ្គលនោះអោយមានសេរីភាពវិញ តែការដោះលែង ឬក៏បញ្ជូនខ្លួនត្រូវតែធ្វើឡើងដោយ សេចក្តីសម្រេចរបស់ព្រះរាជអាជ្ញា។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការបញ្ជូនខ្លួនបុគ្គលដែលឃាត់ខ្លួនទៅចំពោះមុខព្រះរាជអាជ្ញាភ្លាមហើយ ការបញ្ជូនខ្លួននោះត្រូវភ្ជាប់ជាមួយការ កំណត់ហេតុនិងវត្ថុតាងទាំងអស់។ [35]

ករណីបើការបង្ហាញខ្លួន បុគ្គលដែលត្រូវបានឃាត់ខ្លួន ពុំអាចធ្វើឡើងនៅ ថ្ងៃតែមួយបាន ដោយសារមានមូលហេតុពិសេសដែលបណ្តាល មកពីការលំបាកក្នុងការដឹកជញ្ជូន ឬចម្ងាយផ្លូវនៃការដឹកជញ្ជូននោះរយៈពេលបន្ថែមអាចផ្តល់អោយដោយព្រះរាជអាជ្ញាបាន។ នៅក្នុងកាលៈទេសៈបែបណាក៏ដោយ ការបង្ហាញខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួន ត្រូវធ្វើឡើងនៅក្នុងរយៈពេលដ៏ឆាប់បំផុតតាមការដែលអាចធ្វើទៅបាន។[36]

**គ.២ នីតិវិធីការស៊ើបអង្កេតបទល្មើសបឋម**

កាលណាមន្ត្រីនគរបាលយុត្តិធម៌ដឹងអំពើដែលអាចជាបទឧក្រិដ្ឋ ឬមជ្ឈិម ឬ បទលហុ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការស៊ើបអង្កេតបឋមដោយឯកឯង ឬ តាមការសុំរបស់ព្រះរាជអាជ្ញា។ ហើយការស៊ើបអង្កេតបឋមក៏អាចធ្វើបានក្នុងករណី បទឧក្រិដ្ឋ ឬបទមជ្ឈិម ដែលចិរវេលានៃការស៊ើបអង្កេតជាក់ស្តែងបានកន្លងផុត។[37]

**គ.២.១ ការបើកចំហរការស៊ើបអង្កេត**

ក្នុងករណីស៊ើបអង្កេតបឋម មន្ត្រីនគរបាលយុត្តិធម៌អាចកោះហៅ និងស្តាប់ចម្លើយបុគ្គលគ្រប់រូបដែលសង្ស័យថា បានចូលរួមប្រព្រឹត្តបទល្មើស ឬបុគ្គលដែលអាចផ្តល់ព័ត៌មានដែលខ្លួនបានដឹង បានឃើញអំពីរឿងហេតុ។

---

[34] មាត្រា១០២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[35] មាត្រា១០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[36] មាត្រា១០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[37] មាត្រា១១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

បុគ្គលដែល បានកោះហៅត្រូវចូលបង្ហាញខ្លួនភ្លាម។ ករណីរឹងទទឹងមិនចូលខ្លួន មន្ត្រីនគរបាលយុត្តិធម៌អាចជូនដំណឹងទៅព្រះរាជអាជ្ញា ដែលចេញបញ្ជាអោយចូលខ្លួនបានមន្ត្រីនគរបាលយុត្តិធម៌ អាចប្រើប្រាស់កម្លាំងសាធារណៈដើម្បីបង្ខំបុគ្គលនោះអោយចូលបង្ហាញខ្លួននៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌។[38]

- **ការឆែកឆេរ**

ការស៊ើបអង្កេតបឋមដែលទាក់ទងនិងបទឧក្រិដ្ឋ ឬបទមជ្ឈិម មន្ត្រីនគរបាលយុត្តិធម៌អាចឆែកឆេរ និងចាប់យកវត្ថុតាងបាន តែជាបឋមត្រូវទទួលការយល់ច្បាស់លាស់ និងពិតប្រាកដពីអ្នកកាន់កាប់ទីកន្លែង។ ការយល់ព្រមនេះត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយត្រូវសរសេរដោយផ្ទាល់ដៃពីអ្នកកាន់កាប់ទីកន្លែង។ ប្រសិនបើអ្នកកាន់កាប់ទីកន្លែង មិនចេះអក្សរ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវសរសេរអោយបានច្បាស់លាស់ក្នុងកំណត់ហេតុ អ្នកកាន់កាប់ទីកន្លែងមិនចេះអក្សរហើយយល់ព្រមអោយឆែកឆេរ។

ក្នុងករណីដែលអ្នកកាន់កាប់ទីកន្លែងអវត្តមាន ឬបដិសេធការឆែកឆេរ មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ជាបន្ទាន់ទៅព្រះរាជអាជ្ញា ហើយព្រះរាជអាជ្ញាត្រូវសុំធ្វើការអនុញ្ញាតឆែកឆេរទៅ ប្រធានសាលាដំបូងដែលមានសមត្ថកិច្ចដែនដី នៅពេលមានការយល់ព្រមការឆែកឆេរពី ប្រធានសាលាដំបូងហើយព្រះរាជអាជ្ញាត្រូវដឹកនាំដោយផ្ទាល់ នូវការឆែកឆេរនេះនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ទីកន្លែង ត្រូវធ្វើចំពោះមុខសាក្សីពីរនាក់ ដែលត្រូវបានចាត់តាំងដោយព្រះរាជអាជ្ញា។ សាក្សីមិនត្រូវជ្រើសរើសចេញ ពីនគរបាល ឬ កងរាជអាវុធហត្ថ ដែលជាកងកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះឡើយ។ ការឆែកឆេរ មិនអាចផ្តើមមុខម៉ោង៦(ប្រាំមួយ)ព្រឹក និងក្រោយម៉ោង១៨(ដប់ប្រាំបី)ល្ងាចឡើយ។ ការអនុវត្តការចាប់យកវត្ថុតាង ត្រូវអនុវត្តដូច(ការបិទស្លាកបោះត្រាលើវត្ថុ)នៅក្នុងការស៊ើបអង្កេតជាក់ស្តែងដែរ។ [39]

**គ.២.២ ការអនុវត្តការឃាត់ខ្លួន**

ដើម្បីឆ្លើយតប និងតម្រូវការចាំបាច់នៃការស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌អាចឃាត់ខ្លួនបុគ្គលដែលសង្ស័យ ថាបានចូលរួមក្នុងការប្រព្រឹត្តបទល្មើស តែជាបឋមត្រូវទទួលការអនុញ្ញាតពីព្រះរាជអាជ្ញាជាមុខសិន។ មន្ត្រីនគរបាលយុត្តិធម៌ក៏អាចឃាត់ខ្លួនបុគ្គលដែលអាចផ្តល់ព័ត៌មានស្តីពីរឿងហេតុបានដែរ ប្រសិនបើបុគ្គលដែលអាចផ្តល់ព័ត៌មានប្រកែកមិនព្រមផ្តល់ព័ត៌មាន និងមានការយល់ព្រមជាលាយក្ខណ៍អក្សរ អោយធ្វើការឃាត់ខ្លួនពីព្រះរាជអាជ្ញា។ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវរាយការណ៍ភ្លាមជូនព្រះរាជអាជ្ញា ព្រមទាំងត្រូវបញ្ជូនគ្រប់ភស្តុតាងទាំងអស់ ដែលតម្រូវអោយមានការឃាត់ខ្លួននេះ។ ចំពោះថិរវេលានៃការឃាត់ខ្លួនក្នុងការស៊ើបអង្កេតបឋម គឺ

[38] មាត្រា១១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[39] មាត្រា១១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ដូចគ្នានឹងការឃាត់ខ្លួននៃការស៊ើបអង្កេតជាក់ស្តែងដែល។ នៅពេលផុតរយៈពេលឃាត់ខ្លួនមន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនខ្លួនបុគ្គលនោះទៅចំពោះមុខ ព្រះរាជអាជ្ញាឬដោះលែងជននោះអោយមានសេរីភាព ។ ការបញ្ជូនខ្លួនរបស់ជនដែលបានឃាត់ខ្លួនទៅព្រះរាជអាជ្ញា ត្រូវភ្ជាប់ជាមួយកំណត់ហេតុ និងភស្តុតាងដែលមន្ត្រីនគរបាលយុត្តិធម៌បានស្វែងរកនៅពេលបំពេញតួនាទីរបស់ខ្លួន។

**សម្គាល់**:កំណត់ហេតុដែលមន្ត្រីនគរបាលយុត្តិធម៌ ធ្វើឡើងក្នុងករណី(ការស៊ើបអង្កេតជាក់ស្តែងឬការស៊ើបអង្កេតបឋម)កំណត់ហេតុនោះមានតម្លៃគ្រាន់តែជាព័ត៌មានប៉ុណ្ណោះ។ ប៉ុន្តែកំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ត្រូវទុកជាបន្ទាល់ (ឯកសារដើម) មានន័យថា ត្រូវទុកជាឯកសារដែលជឿរហូតដល់មានភស្តុតាងផ្ទុយ។

ភស្តុតាងផ្ទុយអាចជូនមកចៅក្រមបានដោយសេរី តាមគ្រប់មធ្យោបាយត្រឹមត្រូវតាមច្បាប់។[40]

## ផ្នែកទី២ ស្ថាប័នអយ្យការ

អង្គការអយ្យការ ធ្វើការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌ និងសន្និដ្ឋានអោយតុលាការអនុវត្តច្បាប់ ហើយធានារ៉ាប់រងការអនុវត្តសេចក្តីសម្រេចខាងបទល្មើសព្រហ្មទណ្ឌ ព្រមទាំងធានាយកចិត្តទុកដាក់លើការផ្សព្វផ្សាយដីកាបង្គាប់អោយចាប់ខ្លួន។ ការចោទប្រកាន់នេះត្រូវធ្វើតាមរយៈបណ្តឹងអាជ្ញា ព្រោះមានតែមានអង្គការអយ្យការតែប៉ុណ្ណោះ ដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា។[41] នៅក្នុងអង្គការអយ្យការមានចៅក្រមអយ្យការ ដែលធ្វើការនៅទីនោះ។ តើចៅក្រមអយ្យការជានរណា? ចៅក្រមអយ្យការគឺជាម្ចាស់បណ្តឹងអាជ្ញា ហើយចៅក្រមអយ្យការមានដូចខាងក្រោម:

- អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូល
- អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍
- ព្រះរាជអាជ្ញា និង ព្រះរាជអាជ្ញារងអមសាលាដំបូង

- **គោលការណ៍នៃឋានានុក្រម**

ចៅក្រមអយ្យការគ្រប់រូបត្រូវ គោរពតាមអធិបញ្ជាថ្នាក់លើ របស់ខ្លួនតាមឋានានុក្រម។[42] ឋានានុក្រមដែលខ្ពស់ជាងគេគឺរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលគេហៅថាជានាយឋានានុក្រមនៃ អង្គការអយ្យការ ហើយអាចធ្វើអធិបញ្ជាតាមការណែនាំ ជាលាយលក្ខណ៍អក្សរទៅអង្គការអយ្យការគ្រប់ជាន់ថ្នាក់។ នៅពេលដឹងអំពីបទល្មើស មួយកើតឡើងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចប្តឹងបរិហារទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬ ព្រះរាជអាជ្ញាអម

[40] មាត្រា១១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[41] មាត្រា២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[42] មាត្រា២៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

សាលាដំបូង អាចធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរ ដែលត្រូវដាក់បញ្ចូលក្នុងសំណុំរឿង។ ចំពោះអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ មានអំណាចលើ ចៅក្រមអយ្យការទាំងអស់ ដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន អគ្គព្រះរាជអាជ្ញាអាចធ្វើអធិបញ្ញាអោយចោទប្រកាន់ ឬ ក៏ចាត់អោយចោទប្រកាន់ ឬ ក៏ធ្វើសេចក្តីសន្និដ្ឋាន យ៉ាងណាដែលខ្លួន យល់ឃើញថាជាការគួរទៅព្រះរាជអាជ្ញា។[43] ប៉ុន្តែពេលសវនាការ ចៅក្រមអយ្យការអាចធ្វើសេចក្តីសន្និដ្ឋាន ផ្ទាល់មាត់ដោយសេរី តាមការដែលខ្លួនយល់ឃើញ ទោះបីការសន្និដ្ឋាននេះផ្ទុយ និង អធិបញ្ញារបស់ថ្នាក់លើក៏ដោយ។ ឧទាហរណ៍ៈអំពើមួយត្រូវបានព្រះរាជអាជ្ញាយល់ឃើញថា ជាបទល្មើសប្រទូស្តកេរ្តិ៍ខ្មាស តែត្រូវបានថ្នាក់លើធ្វើអធិបញ្ញាអោយ ចោទប្រកាន់ពីបទល្មើសប៉ុនប៉ងរំលោភ។ នៅពេលនេះព្រះរាជអាជ្ញា ត្រូវតែចោទប្រកាន់តាម។ ប៉ុន្តែនៅពេលសវនាការ ព្រះរាជអាជ្ញាអាចធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់ដោយចោទប្រកាន់ពី បទប្រទូស្តកេរ្តិ៍ខ្មាសបាន តាមការយល់ឃើញរបស់ខ្លួន។

ការធ្វើអធិបញ្ញារបស់ឋានានុក្រមថ្នាក់លើ មិនអាចបញ្ញាអោយចៅក្រមអយ្យការ មួយរូបណា តម្កល់រឿងទុកឥតចាត់ការបានទេ។ នៅពេលបំពេញភារកិច្ចចៅ ក្រមអយ្យការ មានសិទ្ធិកេណ្ឌកងកម្លាំងសាធារណៈដោយផ្ទាល់ជាជំនួយ។ នៅក្នុងរឿងព្រហ្មទណ្ឌនៅ ពេលសវនាការដាច់ខាតចៅក្រមអយ្យការត្រូវតែមានវត្តមាន។

- **គោលការណ៍នៃភាពមិនអាចចែកដាច់គ្នា**

នៅក្នុងការបំពេញមុខងាររបស់ ចៅក្រមក្រមអយ្យការអាចជំនួសគ្នាបានជាបន្តបន្ទាប់។ឧទាហរណ៍ៈ ការបើកការជំនុំជម្រះនៅសាលាដំបូងរាជធានីភ្នំពេញ ក្នុងរឿងព្រហ្មទណ្ឌដោយមានព្រះរាជអាជ្ញាធ្វើជាតំណាងអយ្យការ ប៉ុន្តែនៅពេលពេលបើកសវនាការ ព្រះរាជអាជ្ញាដែលតំណាងអយ្យការនោះបានឈឺធ្ងន់ដែលមិនអាចទៅបាន នោះព្រះរាជអាជ្ញាត្រូវចាត់តាំងព្រះរាជអាជ្ញារងណាម្នាក់មកជំនួសខ្លួន ដូចនេះព្រះរាជអាជ្ញារងអាចធ្វើជា តំណាងអយ្យការជំនួសព្រះរាជអាជ្ញាបាន។ តែត្រូវស្ថិតក្រោមការទទួលខុសត្រូវ របស់ព្រះរាជអាជ្ញា(ខុសពីចៅក្រមអាសនៈ)។ មានន័យថា នៅពេលព្រះរាជអាជ្ញារងធ្វើខុស ព្រះរាជអាជ្ញាដែលមានឋានានុក្រមខ្ពស់ជាង ត្រូវទទួលខុសរួមគ្នាជាមួយព្រះរាជអាជ្ញារង ចំពោះថ្នាក់លើរបស់ខ្លួន។

## កថាខណ្ឌទី១៖ ការទទួលពាក្យបណ្តឹងក្នុងរឿងព្រហ្មទណ្ឌ

ក្រោយពីការទទួលពាក្យបណ្តឹងទាំងបណ្តឹងទាមទារ បណ្តឹងបរិហារ និងបណ្តឹងព្រហ្មទណ្ឌជនណាម្នាក់ ឬទទួលរបាយការណ៍ពីមន្ត្រីនគរបាលយុត្តិធម៌ អយ្យការអាចមិនទាន់ធ្វើការចោទប្រកាន់ ប្រសិនបើយល់ឃើញថាពុំទាន់មានភស្តុតាងគ្រប់គ្រាន់ ដើម្បីធ្វើការចោទប្រកាន់នៅឡើយ។ ព្រះរាជអាជ្ញាជាម្ចាស់បណ្តឹងអាជ្ញាគាត់ទទួលពាក្យបណ្តឹងពី រឿងព្រហ្មទណ្ឌទាំងអស់។ ពាក្យបណ្តឹងនោះអាចធ្វើឡើយដោយជនរងគ្រោះ ឬសាច់ញាត្តិ

[43] មាត្រា២៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

របស់ជនរងគ្រោះ មន្ត្រីនគរបាលយុត្តធម៌ មន្ត្រីផ្សេងទៀតដែលមានសមត្ថកិច្ចចាត់ការរឿងព្រហ្មទណ្ឌដូចជាៈ មន្ត្រីគយ មន្ត្រីព្រៃឈើជាដើម ឬក៏តតិយជនដែលដឹងឮពីបទល្មើសឧក្រិដ្ឋ ឬ មជ្ឈិមណាមួយ។

**ក.តាមមន្ត្រីនគរបាលយុត្តធម៌**

នៅពេលដែលមន្ត្រីនគរបាលយុត្តិធម៌ទទួលពាក្យបណ្ដឹងក្នុងរឿងព្រហ្មទណ្ឌ នោះមន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ភ្លាមទៅព្រះរាជអាជ្ញា ព្រោះមន្ត្រីនគរបាលយុត្តិធម៌ គ្មានសិទ្ធិតម្កល់ពាក្យបណ្ដឹងរបស់ណាម្នាក់ទុកឥតចាត់ការបានទេ។ ក្រោយពីទទួលព័ត៌មាន ព្រះរាជអាជ្ញាត្រូវ អនុញ្ញាតអោយមន្ត្រីនគរបាលយុត្តិធម៌បើកស៊ើបអង្កេតភ្លាម។ក្រោយពីអនុវត្តនីតិវិធី និងឈានទៅដល់ការបញ្ចប់នីតិវិធី គឺមន្ត្រីនគរត្រូវរាយការណ៍គ្រប់ការអនុវត្តទាំងអស់ទៅព្រះរាជអាជ្ញា ព្រោះព្រះរាជអាជ្ញា ជាអ្នកដឹកនាំ និងសម្របសម្រួលសកម្មភាពរបស់មន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់ នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។ នៅពេលបញ្ចប់នីតិវិធីនៃការស៊ើបអង្កេតលើពាក្យបណ្ដឹងដែលប្ដឹងមកខ្លួន នោះមន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនខ្លួនជនដែលឃាត់ខ្លួន ដែលភ្ជាប់ជាមួយកំណត់ និងភស្តុតាងដែលមកអោយព្រះរាជអាជ្ញាដើម្បីចាត់ការនីតិវិធីបន្តតាមផ្លូវច្បាប់។

**ខ.ដើមបណ្ដឹងរដ្ឋប្បវេណី ឬជនរងគ្រោះ**

ជនរងគ្រោះ អាចដាក់ពាក្យបណ្ដឹងទៅមន្ត្រីនគរបាលយុត្តិធម៌ ឬអាចដាក់ពាក្យបណ្ដឹងដោយផ្ទាល់ ឬក៏ជនរងគ្រោះអាចពឹងពាក់មេធាវីអោយជួយក្នុងដាក់ពាក្យបណ្ដឹងទៅ តុលាការដែលមានសមត្ថកិច្ចទទួលពាក្យបណ្ដឹង។ ការដាក់ពាក្យបណ្ដឹងត្រូវបញ្ជូនទៅព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចដែនដីនៃពាក្យបណ្ដឹងខាងក្រោមៈ

- ព្រះរាជអាជ្ញានៃទីកន្លែងដែលមានការប្រព្រឹត្តបទល្មើស
- ព្រះរាជអាជ្ញានៃទីលំនៅរបស់ជនដែលគេសង្ស័យ បានប្រព្រឹត្តបទល្មើស
- ព្រះរាជអាជ្ញានៃទីកន្លែងចាប់ខ្លួនជនដែលត្រូវបានគេសង្ស័យ បានប្រព្រឹត្តបទល្មើស

នៅពេលដាក់ពាក្យបណ្ដឹង ជនរងគ្រោះត្រូវតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។[44]ប៉ុន្តែនៅពេលដែលជនរងគ្រោះស្លាប់អ្នកតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីអាចជា សហពន្ធ័ សាច់ញាតិ ឪពុកម្ដាយ របស់ជនរងគ្រោះ ឬក៏ព្រះរាជអាជ្ញាដែលជាម្ចាស់បណ្ដឹងអាជ្ញា។ **ឧទាហរណ៍ៈ** បុគ្គល ក មានទីកន្លែងរស់នៅ នៅខេត្តព្រៃវែង ហើយនៅថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ២០២០ បុគ្គល ក នោះបានធ្វើសកម្មភាពឆក់កាបូប បុគ្គល ខ ដោយបុគ្គល ក នោះធ្វើគេចខ្លួនបាន សម្រេច។ ដូចនេះ បុគ្គល ខ ត្រូវដាក់ពាក្យបណ្ដឹងទៅ អយ្យការអមសាលាដំបូងខេត្តព្រៃវែង។

[44] មាត្រា៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

## កថាខណ្ឌទី២៖ គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញា

ជាដំបូងព្រះរាជអាជ្ញា ត្រូវត្រួតពិនិត្យលើពាក្យបណ្តឹងជាមុខសិនដោយធ្វើស៊ើបអង្កេតបឋម ឬ ធ្វើការស្រាវជ្រាវបន្ថែមដើម្បីប្រមូលព័ត៌មានអោយកាន់តែច្បាស់ ថាវាជាប្រភេទបណ្តឹងព្រហ្មទណ្ឌដែលឬទេ បើសិនពាក្យបណ្តឹងនេះជាបណ្តឹងព្រហ្មទណ្ឌ ព្រះរាជអាជ្ញាត្រូវមើលទៅលើធាតុផ្សំនៃបទល្មើសវាគ្រប់គ្រាន់ហើយ។ បន្ទាប់មកព្រះរាជអាជ្ញាត្រូវថ្លឹងថ្លែងរាល់ពាក្យបណ្តឹង ដែលខ្លួនទទួលដោយផ្ទាល់ខ្លួន ដោយប្រជាពលរដ្ឋ មន្ត្រីរាជការ ឬក៏មន្ត្រីនគរបាលយុត្តិធម៌បញ្ជូនមក។ ការថ្លឹងថ្លែងនេះ មានន័យថាគឺជាការសម្រេចចិត្តរបស់ ព្រះរាជអាជ្ញាលើពាក្យបណ្តឹងដែលទទួលមក ថាគួរតែចោទប្រកាន់ ឬ តម្កល់រឿងទុកឥតចាត់ការ។ ព្រោះជាគោលការណ៍ព្រះរាជអាជ្ញាមាន សេរីភាពពេញលេញ ក្នុងការចោទប្រកាន់ ឬតម្កល់រឿងទុក។ ប៉ុន្តែការតម្កល់រឿងទុករបស់ព្រះរាជអាជ្ញាត្រូវប្រែប្រួលដោយសារ ព្រះរាជអាជ្ញាត្រូវគោរព អធិបញ្ញារបស់ឋានានុក្រមរបស់ខ្លួននៅពេល ដែលព្រះរាជអាជ្ញាតម្កល់រឿងណាមួយទុកឥតចាត់ការប្រសិនបើឋានានុក្រមធ្វើអធិបញ្ញាអោយចោទ រឿងដែលតម្កល់នោះ ព្រះរាជអាជ្ញាត្រូវតែចោទប្រកាន់ឡើងវិញ។

### ក.ការចោទប្រកាន់ក្នុងរឿងព្រហ្មទណ្ឌ

នៅពេលដែលមានភស្តុតាងដែលធ្ងន់ល្មមដែលអាចបញ្ជាក់ពី ពិរុទ្ធភាពនៃជនសង្ស័យ ដែលធ្វើអោយព្រះរាជអាជ្ញាជឿបានថាជនសង្ស័យអាច នឹងប្រព្រឹត្តអំពើដែលគេប្តឹងមកនោះមែនព្រះរាជអាជ្ញានឹងចាប់ផ្តើមការចោទប្រកាន់ តាមនីតិវិធីដែលបានចែងក្នុងច្បាប់។ ការចាប់ផ្តើមចោទប្រកាន់ ចំពោះអនីតិជន ត្រូវជូនដំណឹងទៅអនីតិជន និងឪពុកម្តាយ ឬ អាណាព្យាបាល ឬអ្នកតំណាងស្របច្បាប់។ ប៉ុន្តែ ការចោទប្រកាន់បានតែអនីតិជនចាប់ពី ១៤ឆ្នាំឡើងទៅ។ នៅក្នុងរឿងព្រហ្មទណ្ឌអនីតិជនត្រូវមានមេធាវីអមជានិច្ច។ ក្នុងករណីដែលការចោទប្រកាន់ទៅលើមន្ត្រីរាជការណាម្នាក់ ព្រះរាជអាជ្ញាត្រូវជូនដំណឹងទៅប្រធានស្ថាប័នសាមី រយៈពេល៧២យ៉ាងយូរ តាមគ្រប់ មធ្យោបាយ។ ការចោទប្រកាន់ត្រូវធ្វើតាមនីតីវីធី៣យ៉ាងដូចខាងក្រោមៈ[45]

#### ក.១ ការបើកការស៊ើបសួរ

ការបើកការស៊ើបសួរនេះធ្វើឡើងដោយព្រះរាជអាជ្ញា នៅពេលដែលសំណុំរឿងមួយមានការស្មុគស្មាញ ពិបាកក្នុងការដោះស្រាយព្រះរាជអាជ្ញាធ្វើការបើកស៊ើបសួរ ដើម្បីស្វែងរកភស្តុតាង និងធ្វើការស្រាវជ្រាវបន្ថែមទៅលើសំណុំរឿងដែលខ្លួនបានទទួល។ ការបើការស៊ើបសួរត្រូវតែធ្វើដាច់ខាតចំពោះករណីបទឧក្រិដ្ឋ។ មុននឹងធ្វើការស៊ើបសួរបានព្រះរាជអាជ្ញាត្រូវ ចេញដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរទៅ ទៅមន្ទីរស៊ើបសួរ ហើយប្រធានមន្ទីរស៊ើបសួរនឹងចាត់ចៅក្រមមួយរូបអោយអនុវត្តដីកានេះ។ ចៅក្រមដែលអនុវត្តដីកានេះគេ អោយឈ្មោះថា

[45] មាត្រា៤៣ នៃក្រមនីតីវីធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ចៅក្រមស៊ើបសួរ។ ការស៊ើបសួរអាចបើកប្រឆាំងលើបុគ្គលម្នាក់ ឬច្រើនអ្នក ដោយមានចង្អុលប្រាប់ឈ្មោះ ឬប្រឆាំងទៅអញ្ញាតជន(ជនដែលមិនស្គាល់)។ ដីកាបញ្ជូនរឿងអោយស៊ើបសួររួមមានៈ សេចក្តីសង្ខេបនៃអង្គហេតុ ការកំណត់ឈ្មោះបទល្មើស,ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស ឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរ ប្រសិនបើអាចកំណត់បាន (មានន័យថាករណី ដែលអ្នកដាក់ពាក្យបណ្តឹង មិនស្គាល់ជនបង្ក)។[46]

**ក.២ បញ្ជូនទៅជំនុំជម្រះផ្ទាល់**

ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ធ្វើឡើងដោយព្រះរាជអាជ្ញាដែល បញ្ជាអោយជនជាប់ចោទទៅបង្ហាញខ្លួននៅចំពោះមុខ តុលាការជាន់ដំបូង។ បទល្មើសដែលព្រះរាជអាជ្ញាបញ្ជូនជនជាប់ចោទទៅជំនុំជម្រះផ្ទាល់ ភាគច្រើនគ្រប់បទលហុទាំងអស់។ ចំណែក បទមជ្ឈិមមួយចំនួន ក៏ព្រះរាជអាជ្ញាធ្វើការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ដែលកាលណារឿងនោះវាមានលក្ខណៈមិនស្មុគស្មាញ ហើយរឿងនេះធនល្មមនឹងអាចជំនុំជម្រះបាន។ ការបញ្ជារជនជាប់ចោទទៅជំនុំជម្រះផ្ទាល់ ព្រះរាជអាជ្ញាត្រូវចេញដីកាកោះហៅបញ្ជូនទៅជនុំជម្រះផ្ទាល់ៈ

- អត្តសញ្ញាណនៃ ជនជាប់ចោទ
- សេចក្តីសង្ខេបនៃអង្គហេតុ
- ឈ្មោះនៃបទល្មើស
- អត្ថបទដែលច្បាប់បានកំណត់

ដីកានេះត្រូវចង្អុលប្រាប់ជនជាប់ចោទអោយស្គាល់ពីតុលាការដែលត្រូវទៅជំនុំជម្រះ និងប្រាប់អំពី ទីកន្លែង កាលបរិច្ឆេទ ម៉ោងពេលសវនាការ ហើយនៅក្នុងដីកាត្រូវបញ្ជាក់ថា ជនជាប់ចោទអាចពឹងមេធាវីអោយអមជាមួយខ្លួនបាន។ព្រះរាជអាជ្ញាជាអ្នកប្រគល់ដីកាៈនេះអោយទៅ ជនជាប់ចោទ ឬ ព្រះរាជអាជ្ញាក៏អាចសុំអាជ្ញាសាលាក្រឡាបញ្ជី អាជ្ញាធររដ្ឋបាល អាជ្ញាធរពន្ធនាគារ(ករណីជនជាប់ចោទ ដែលជាប់ឃុំ) មន្ត្រីនគរបាល ឬកងរាជអាវុធហត្ថ ប្រគល់ដីកានេះជំនួសខ្លួនបាន។ អ្នកប្រគល់ដីកា ត្រូវប្រគល់ដីកានេះអោយទៅជនជាប់ចោទ បានគ្រប់ទីកន្លែងដែលមានវត្តមាន របស់ជនជាប់ចោទ ឬបើជនជាប់ចោទមិនសិត្ថនៅក្នុងលំនៅឋានរបស់ខ្លួនទេ អ្នកដែលប្រគល់ដីកាត្រូវប្រគល់អោយទៅបុគ្គលគ្រប់រូបដែលមានវត្តមាននៅក្នុងឋានៈជនជាប់ចោទ តែការប្រគល់អោយបានតែនីតិជន។ ករណីដែលជនជាប់ចោទ ឬក៏អវត្តមានដែលនៅក្នុងលំនៅឋាន ឬអ្នកដែលវត្តមានក្នុងលំនៅឋានមិនព្រមទទួលដីកា នោះអ្នកដែលប្រគល់ដីកាត្រូវ ប្រគល់ចុងដីកាអោយទៅដល់ដៃមេឃុំ ឬចៅសង្កាត់ ឬចៅសង្កាត់រង។ នៅពេលដែលអ្នកប្រគល់ដីកា អោយទៅអ្នកណាម្នាក់ត្រូវតែប្រគល់ចុងដីកាអោយទៅជននោះ ហើយត្រូវចុះនិទ្ទេសស្តីពីកាលបរិច្ឆេទនៃកាលប្រគល់ដីកា។ អ្នកដែលទទួលត្រូវហត្ថលេខានៅលើដើមដីកា ដែល

[46] មាត្រា៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ត្រូវបង្វិលមកព្រះរាជអាជ្ញាវិញភ្លាម។[47] បុគ្គលដែលទទួលដីកានេះក្រៅពីជនជាប់ចោទត្រូវសន្យាថា នឹងប្រគល់ដីកានេះទៅអោយជនជាប់ចោទក្នុងរយៈពេលយ៉ាងខ្លី បំផុតក្រោយពីបានទទួលបានដីកានេះ ពីព្រោះ រយៈពេលដែលត្រូវគោរពរវាង ការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់អោយ ដល់ជនជាប់ចោទនិងថ្ងៃកំណត់អោយចូលបង្ហាញខ្លួននៅមុខតុលាការត្រូវកំណត់ដូចខាងក្រោមៈ

- ១៥(ដប់ប្រាំ)ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងដែនដីនៃទីស្នាក់ការ របស់តុលាការជាន់ដំបូង។
- ២០(ម្ភៃ)ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងទីកន្លែងមួយផ្សេងទៀតក្នុងដែនដីជាតិ។
- ២ (ពីរ)ខែ ប្រសិនបើជនជាប់ចោទរស់នៅក្នុងរដ្ឋមួយជាប់ព្រំដែនព្រះរាជណាចក្រកម្ពុជា។
- ៣ (បី)ខែ ប្រសិនបើ ជនជាប់ចោទរស់នៅក្នុងទីកន្លែងដទៃផ្សេងទៀត។[48]

### ក.៣ នីតិវិធីការបង្ហាញខ្លួនភ្លាម

នីតិវិធីបង្ហាញខ្លួនភ្លាម គឺធ្វើឡើងដោយព្រះរាជអាជ្ញាអាចបង្គាប់អោយនាំខ្លួនជនជាប់ចូលបង្ហាញខ្លួនភ្លាមនៅចំពោះមុខតុលាការជាន់ដំបូង ប្រសិនចូលក្នុងលក្ខខណ្ឌខាងក្រោមៈ

- បទល្មើសឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងនិងការចាត់ទុកដូចជាបទល្មើសឧក្រិដ្ឋឬបទមជ្ឈិមជាក់ស្តែង
- បទល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារយ៉ាងតិច១ឆ្នាំ និង យ៉ាងច្រើន៥(ប្រាំ)ឆ្នាំ
- ជនជាប់ចោទជានីតិជន
- រឿងក្តីមានលក្ខណៈគ្រប់គ្រាន់ធួនល្មមអាចជំនុំជម្រះបាន។[49]

**ឧទាហរណ៍ៈ** អំពើលួច បទបង្ករបួសស្នាមដោយអចេតនា ...។ លក្ខ័ខណ្ឌខាងលើនេះត្រូវតែគោរពព្រោះបើខ្វះលក្ខខណ្ឌណា មួយនោះនីតិវិធីនៃការបង្ហាញខ្លួន មិនអាចប្រព្រឹត្តទៅបានទេ។ តើនៅពេលលក្ខខណ្ឌខាងលើគ្រប់គ្រាន់ព្រះរាជអាជ្ញាត្រូវធ្វើដូចម្តេច? ក្រោយពីលក្ខខណ្ឌខាងលើមានគ្រប់គ្រាន់ហើយ នោះព្រះរាជអាជ្ញាត្រូវៈ

- ពិនិត្យអត្តសញ្ញាបុគ្គលដែលបញ្ជូនអោយមកខ្លួន
- អោយដំណឹងដល់ជននោះ អំពីរឿងរ៉ាវដែលគេចោទប្រកាន់ និងឈ្មោះបទល្មើស
- ទទួលចម្លើយបុគ្គលនោះបើខ្លួនចង់និយាយ

ព្រះរាជអាជ្ញាអោយប្រាប់សិទ្ធិរបស់ជនជាប់ចោទអាចរកមេធាវីអមខ្លួនបាន។ ហើយមេធាវីដែលអមនោះអាចពិនិត្យសំណុំរឿងដែលទាក់ទងនឹងជនចោទបាន។

[47] មាត្រា៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[48] មាត្រា៤៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[49] មាត្រា៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

**បញ្ជាក់៖** បណ្ដឹងដែលព្រះរាជអាជ្ញាបញ្ជូនខ្លួនជនជាប់ចោទទៅចំពោះមុខសាលាដំបូង គឺមិនមែនជាដីកានោះទេ តែជាកំណត់ហេតុស្ដីពីការបង្គាប់អោយចូលបង្ហាញខ្លួនភ្លាម។ ការបញ្ជូនខ្លួនជនជាប់ចោទទៅមុខតុលាការសាលាដំបូងត្រូវអមដោយកងការពាររហូតទៅដល់តុលាការហើយ សវនាការត្រូវបើកនៅថ្ងៃនោះ។ នៅពេលទៅដល់តុលាការនោះផ្ទៀងផ្ទាល់អត្តសញ្ញាណជនជាប់ចោទ កំណត់ហេតុដែលព្រះរាជអាជ្ញាដាក់មក។តុលាការនឹងពិនិត្យមើលលើសំណុំរឿងថាអាចជនុំជម្រះបាន ឬ ក៏អាចលើកទៅសវនាការលើកក្រោយ ដោយសាររឿងក្ដីនេះមានលក្ខណៈមិនទាន់អាចជំនុំជម្រះបាន ឬ ទុកពេលអោយជនជាប់ចោទដើម្បីរៀបចំខ្លួន(ការទុករយៈពេលនេះអាចធ្វើដោយតុលាការ ឬ តាមការសុំរបស់ជនជាប់ចោទ)។ នៅពេលផ្អាកសវនាការតុលារការ ត្រូវបង្គាប់អោយឃុំខ្លួនជនជាប់ចោទជាបណ្ដោះអាសន្ន ដោយមានសាលក្រមដែល សំអាតហេតុ(សេចក្ដីសម្រេចមុនអង្គសេចក្ដី)។ ប្រសិនបើតុលាការពិនិត្យទៅឃើញថាពាក្យបណ្ដឹងមានសាំញ៉ាំដែលត្រូវអោយមានការស្រាវជ្រាវបន្ថែម នោះតុលាការនឹងបង្វិលសំណុំរឿងនោះទៅព្រះរាជអាជ្ញាដើម្បីធ្វើការបើកការស៊ើបសួរ ដោយបញ្ជូនជនជាប់ចាប់ទៅបង្ហាញខ្លួននៅថ្ងៃនោះតែម្ដងចំពោះមុខចៅក្រមស៊ើបសួរ បើពុំដូច្នេះជនជាប់ចោទត្រូវបានដោះលែងអោយវិញ។ ពីព្រោះ សាលក្រមលើកអង្គសេចក្ដី(មានន័យថាគឺ ជាសេចក្ដីសម្រេចរបស់តុលាការលើកសំណុំរឿងដែលគេដាក់មក) ត្រូវតែប្រកាស រយៈពេលនៃការឃុំខ្លួនមិនលើសពីរយៈពេល ២សប្ដាហ៍គិតពីថ្ងៃដែលចូលបង្ហាញខ្លួនលើកដំបូងនៅចំពោះមុខតុលាការ។បើមិនដូចនេះការឃុំខ្លួនត្រូវតែបញ្ឈប់ភ្លាមក្រោយរយៈពេល២(ពីរ)សប្ដាហ៍។[50]នីតិវិធីការបង្ហាញខ្លួនភ្លាម មិនធ្វើបានចំពោះបទល្មើសប្រើប្រាស់គ្រឿងញៀនបានទេ។

**ខ.ការតម្កល់រឿងទុកឥតចាត់ការ**

នៅពេលព្រះរាជាអាជ្ញាបានទទួលពាក្យបណ្ដឹង ឬ ពាក្យបរិហាព្រះរាជអាជ្ញាត្រូវពិនិត្យទៅលើពាក្យបណ្ដឹងនោះ ដោយជាដំបូងព្រះរាជអាជ្ញាត្រូវបើកស៊ើបអង្កេតបឋម ឬក៏ ស្រាវជ្រាវបន្ថែម ដែលជាគ្រឹះក្នុងការចោទប្រកាន់ព្រោះកុំអោយមានភន្ដ័ច្រឡំបន្ទាប់មកព្រះរាជអាជ្ញាត្រូវថ្លឹងថ្លែងទៅលើពាក្យបណ្ដឹងដែលខ្លួនបានទទួល។ ក្រោយពីមានការស្រាវជ្រាវបន្ថែម បើព្រះរាជអាជ្ញាយល់ឃើញថាមាននត្ថិភាពនៃបទល្មើស(មានន័យថាអវត្តមាននៃបទល្មើស ឬ បទល្មើសមិនមែនជាបទល្មើសព្រហ្មទណ្ឌ) ហើយមានបន្ទុកគ្រប់គ្រាន់ បង្ហាញអោយឃើញគ្មានពិរុទ្ធភាពនៃបទល្មើស ម៉្យាងទៀត នៅពេលដែលស្រាវជ្រាវវាដូចជាហាក់គ្មានប្រយោជន៍ និងគ្មានប្រសិទ្ធិភាព(ប្រសិទ្ធិភាពមានន័យថាៈ ការរលត់នៃបណ្ដឹងអាជ្ញា មរណៈភាពនៃជនល្មើស ការលើកលែងទោសជាទូទៅ ការនិរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ អាជ្ញាអស់ជំនុំ។ ក្រៅពីមូលហេតុនេះ ព្រះរាជអាជ្ញាក៏អាចតម្កល់រឿងទុកឥតចាត់ការបានដែរមានលក្ខខណ្ឌដូចខាងក្រោមៈ

[50] មាត្រា៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

- អង្គហេតុនៃរឿងមិនមែនជារឿងព្រហ្មទណ្ឌ (មានន័យថានៅពេលជនរងគ្រោះ ដាក់ពាក្យបណ្ដឹងមកព្រះរាជអាជ្ញាក្នុងរឿងព្រហ្មទណ្ឌ តែនៅពេលដែលព្រះរាជអាជ្ញាធ្វើការបើកការស៊ើបអង្កេតបឋម ឬ ស្រាវជ្រាវបន្ថែម តែនៅពេលប្រមូលព័ត៌មានបានបង្ហាញថា ពាក្យបណ្ដឹងនេះជាបណ្ដឹងរដ្ឋប្បវេណីមិនមែនបណ្ដឹងព្រហ្មទណ្ឌទេ ដូចនេះព្រះរាជអាជ្ញានឹងបញ្ជូនពាក្យបណ្ដឹងទៅតុលាការជំនាញរដ្ឋប្បវេណីវិញ)។
- អង្គហេតុនៃរឿងជារឿងព្រហ្មទណ្ឌប៉ុន្តែជាបទតូចតាច(មានន័យថាអំពើនេះជាបទល្មើសព្រហ្មទណ្ឌ តែព្យសនកម្មដែលកើតឡើងវាមានលក្ខណៈតូចតាច។ **ឧទាហរណ៍៖** បុគ្គល ក បានលួចបេះក្ដិបស្វាយ១ផ្លែ តែម្ចាស់ចំការមកដាក់ពាក្យបណ្ដឹងទៅ បុគ្គល ក នោះពីបទលួច ដោយសារបទលួចជាបទមជ្ឈិម ប៉ុន្តែដោយសារព្យសនកម្ម វាតិចតួចពេក នោះព្រះរាជអាជ្ញាគាត់និងធ្វើជាអ្នកសម្របសម្រួលក្នុងរឿងនេះវិញ។ ការតម្កល់រឿងនីមួយៗហើយព្រះរាជអាជ្ញាត្រូវមានសំអាងហេតុ និងសំអាងច្បាប់។ ការតម្កល់រឿងទុកឥតចាត់ការ មិនមានអាជ្ញាអស់ជំនុំទេ ព្រោះព្រះរាជអាជ្ញា អាចសើរើកែប្រែសេចក្ដីសម្រេចរបស់ខ្លួនបាន ក្នុងករណីដែលបណ្ដឹងអាជ្ញាមិនទាន់រលត់នៅឡើយ។

### ខ.១ ភាគីដែលអាចធ្វើបណ្ដឹង

នៅពេលដែលអ្នកប្ដឹងមិនសុខចិត្ត នឹងសេចក្ដីសម្រេចតម្កល់រឿងទុកឥតចាត់ការទេ ដោយខ្លួនយល់ឃើញថាការសម្រេចនេះ ផ្ដល់ផលប៉ះដល់ផលប្រយោជន៍ជនរងគ្រោះ ឬ ជនដែលពាក់ពន្ធ សាមីខ្លួនអាចធ្វើការតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។

### ខ.២ រយៈពេលនៃការតវ៉ា

កាលណា ការតម្កល់រឿទុកឥតចាត់ការកើតឡើង ជៀសមិនផុតនៃការបណ្ដឹងតវ៉ាទាំងតែកើតមានឡើងនោះទេ។ ហេតុនេះហើយបានព្រះរាជអាជ្ញាត្រូវអោយដំណឹងដល់អ្នកបណ្ដឹង អំពីសេចក្ដីសម្រេចរបស់ខ្លួនយ៉ាងឆាប់ហើយយ៉ាងយូរបំផុតរយៈពេល២(ពីរ)ខែ ដោយគិតពីថ្ងៃចុះបញ្ជីពាក្យបណ្ដឹង។ បន្ទាប់ពីទទួលដំណឹងនៃការតម្កល់រឿងទុកឥតចាត់ការពីព្រះរាជអាជ្ញា ត្រូវធ្វើពាក្យបណ្ដឹងសាមញ្ញាមួយ ទៅអង្គការអយ្យការដែលពាក់ពន្ធ័។ បន្ទាប់តំណាងអយ្យការនៅសាលាដំបូង ត្រូវបញ្ជូនសំណុំរឿងទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ ហើយរយៈនៃការប្ដឹងតវ៉ាត្រូវធ្វើនៅក្នុងរយៈពេល ២(ពីរ)ខែគិតពីថ្ងៃទទួលដំណឹងអំពីសេចក្ដីសម្រេចតម្កល់រឿងទុកឥតចាត់ការ។

### ខ.៣ អនុវត្ត

ពេលជនរងគ្រោះ ដាក់ពាក្យប្ដឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អគ្គព្រះរាជអាជ្ញានិង ពិនិត្យទៅលើពាក្យបណ្ដឹងដែលដាក់មកអោយខ្លួនថា ក្រោយពេលពិនិត្យហើយអគ្គព្រះរាជអាជ្ញាយល់ឃើញ ពាក្យបណ្ដឹង

នោះមានមូលហេតុត្រឹមត្រូវ អគ្គព្រះរាជអាជ្ញានឹងធ្វើអធិបញ្ញាទៅព្រះរាជអាជ្ញាអោយធ្វើការចោទតាមការយល់ឃើញ។ ព្រះរាជអាជ្ញាត្រូវធ្វើតាមអធិបញ្ញារបស់ឋានានុក្រមរបស់ខ្លួន។ អគ្គព្រះរាជអាជ្ញាត្រូវធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរ។ ប៉ុន្តែ បើការបណ្តឹងរបស់ជនរងគ្រោះផ្ទុយពីការរៀបរាប់ខាងលើនោះ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ តម្កល់សេចក្តីសម្រេចសាលាដំបូងទុកជាបានការ។ ក្រោយពីបានសម្រេចហើយអគ្គព្រះរាជអាជ្ញា ត្រូវអោយដំណឹងទៅជនរងគ្រោះ។[51]

## ផ្នែកទី ៣ យុត្តាធិការស៊ើបសួរ

យុត្តាធិការស៊ើបសួរ គឺជាឈ្មោះស្ថាប័នមួយដែលមានតួនាទីការពារសិទ្ធិ និងផលប្រយោជន៍របស់ ជនរងគ្រោះ និង ជនត្រូវចោទ អោយស្ថិតក្នុងសមភាពចំពោះមុខច្បាប់។ ហើយអ្នកបំពេញការងារនៅក្នុងស្ថាប័ននេះជាសមាសភាពចៅក្រមស៊ើបសួរ។ យុត្តាធិការស៊ើបសួរមាននៅសាលាដំបូងដែលគេហៅថាមន្ទីរស៊ើបសួរ ចំណែកឯសាលាឧទ្ធរណ៍ គេអោយឈ្មោះថា សភាស៊ើបសួរ ប៉ុន្តែនៅតុលាការកំពូលមិនមានយុត្តាធិការស៊ើបទេ។ សភាស៊ើបសួរជាអ្នកដែលមានសមាសភាពត្រួតពិនិត្យរាល់ប្រតិបត្តិការរបស់មន្ទីរស៊ើបសួរ គ្រប់សាលាដំបូងរាជធានីខេត្ត ទូទាំងប្រទេស និងជនុំជម្រះលើបណ្តឹងឧទ្ធរណ៍ដែលប្តឹងប្រឆាំងនឹងសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរសាលាដំបូង ហើយក៏ធ្វើការសេចក្តីម្រេចជំនួសរាល់បណ្តឹងដែលដាក់មកចៅក្រមស៊ើបសួរ ដែលមិនបានឆ្លើយតប។

### កថាខណ្ឌទី១ ការស៊ើបសួររបស់ចៅក្រមស៊ើបសួរ

ចៅក្រមស៊ើបសួរ គឺជាចៅក្រមអាសនៈដែលបំពេញមុខងារស៊ើបសួរនៅសាលាដំបូង។ ជាគោលការណ៍ ចៅក្រមអយ្យការ ត្រូវចែកដាច់ពី ចៅជនុំជម្រះ ព្រោះចៅក្រមស៊ើបសួរ មិនអាចមកធ្វើជាចៅក្រមជំនុំជម្រះក្នុងរឿងដែលខ្លួនធ្វើការស៊ើបសួរបានទេ។

#### ក.ការបើកការស៊ើបសួរ

ការបើកស៊ើបសួរ ជាដំណាក់មួយដែលព្រះរាជអាជ្ញាយល់ឃើញថា ពាក្យបណ្តឹងមានភាពស្មុគស្មាញ ហើយចំបាច់ក្នុងការស្វែងរកភស្តុតាងបន្ថែមក្នុងការចោទប្រកាន់។ ការស៊ើបសួរ ត្រូវធ្វើដោយដាច់ខាតចំពោះបទឧក្រិដ្ឋ។ ចំពោះបទមជ្ឈិម ការស៊ើបសួរអាចធ្វើក៏បាន ឬមិនធ្វើក៏បាន។ ដើម្បីអោយចៅក្រមស៊ើបសួរ បើកការស៊ើបសួររឿងណាមួយបានព្រះរាជអាជ្ញានឹងចេញដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ ដែលសុំអោយចៅក្រមស៊ើបសួរ បើការស៊ើបសួរតាមការអ្វីដែលខ្លួនបានចោទប្រកាន់។ ក្រៅពីដីការបស់ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរក៏អាចបើក

[51] មាត្រា៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ការស៊ើបសួរតាមរយៈ ការប្តឹងនៅចំពោះមុខដែលមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ ចំណែកការអនុវត្ត ត្រូវស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដែលមានដូចខាងក្រោមៈ

- ចៅក្រមស៊ើបសួរដែលនាទីកន្លែងបទល្មើស
- ចៅក្រមស៊ើបសួរនាទីលំនៅដ្ឋាន ឬ ទីសំណាក់របស់បុគ្គលដែលសង្ស័យថាបានប្រព្រឹត្តបទល្មើស
- ចៅក្រមស៊ើបសួរ នាទីកន្លែងចាប់ខ្លួនបុគ្គលដែលសង្ស័យថាប្រព្រឹត្តបទល្មើស

ក្នុងករណីដែលមានទំនាស់រវាងចៅក្រមស៊ើបសួរច្រើនរូប នៅសាលាដំបូងខុសៗគ្នា ហើយទទួលពាក្យបណ្តឹង ទាំងអស់គ្នា អំពីរឿងព្រហ្មទណ្ឌតែមួយដូចគ្នា ទំនាស់នេះត្រូវបញ្ជូនទៅប្រធានសភាស៊ើបសួរជាអ្នកសម្រេច។ **ឧទាហរណ៍:**បើមានវិវាទសមត្ថកិច្ចដែនដី រវាងសភាស៊ើបសួរច្រើនត្រូវសម្រេចដោយប្រធានតុលាការកំពូល ដែល ជាសេចក្តីសម្រេចបិទផ្លូវតវ៉ា។

### ក.១ដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួររបស់ព្រះរាជអាជ្ញា

ចៅក្រមស៊ើបសួរមិនអាចបំពេញកិច្ចស៊ើបសួរ ណាមួយដែលគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ របស់ព្រះរាជអាជ្ញាបានទេ។ ចៅក្រមស៊ើបសួរ អាចស៊ើបសួរតែអំពីអង្គហេតុដែលបានកំណត់ក្នុងដីការបស់ព្រះ រាជអាជ្ញាតែប៉ុណ្ណោះ។ ប្រសិនបើលេចចេញនៃអង្គហេតុថ្មីដែលអាចជាបទល្មើសព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរត្រូវ ជូនដំណឹងទៅព្រះរាជអាជ្ញា ដើម្បីសុំដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរបន្ថែម ទើបស៊ើបសួរលើអង្គហេតុថ្មី នេះបាន។ ប៉ុន្តែបើអង្គហេតុថ្មីនោះជាស្ថានទម្ងន់ទោសទៅលើអង្គហេតុចាស់ ចៅក្រមស៊ើបសួរអាចស៊ើបសួរបាន ដោយមិនចាំបាច់សុំដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរពីព្រះរាជអាជ្ញានោះទេ។ លក្ខខណ្ឌខាងលើត្រូវតែ គោរព បើមិនដូច្នេះការស៊ើបសួរនេះ នឹងទុកជាមោឃ។[52]

**ឧទាហរណ៍:** ព្រះរាជអាជ្ញាសន្និដ្ឋានបញ្ជូនរឿងលោក ក ទៅអោយចៅក្រមស៊ើបសួរ ដោយចោទប្រកាន់ពីបទ ឃាតកម្ម។ នៅពេលដែលស៊ើបសួរស្រាប់តែចៅក្រមស៊ើបសួរ រកឃើញលោក ក បានជាប់ពាក់ពន្ធ័នឹងការជួញដូរ គ្រឿងញៀនមួយទៀត ចៅក្រមស៊ើបសួរ ត្រូវសុំដីកាសន្និដ្ឋានពីព្រះរាជអាជ្ញាបន្ថែម ទើបអាចស៊ើបសួរពីការពាក់ព ន្ធ័គ្រឿងញៀននេះបាន។

**ឧទាហរណ៍:** ព្រះរាជអាជ្ញា សន្និដ្ឋានបញ្ជូនរឿងលោក ក ទៅអោយចៅក្រមស៊ើបសួរ ដោយចោទប្រកាន់ពីបទ ហិង្សាដោយចេតនា។នៅពេលដែលស៊ើបសួរស្រាប់តែចៅក្រមស៊ើបសួររកឃើញ ថានៅពេលប្រព្រឹត្តបទល្មើស លោក ក បានប្រើអាវុធ។ ក្នុងករណីនេះចៅក្រមស៊ើបសួរមិចចាំបាច់សុំដីកាសន្និដ្ឋានពីព្រះរាជអាជ្ញានោះទេ (ព្រោះការប្រើអាវុធវាគ្រាន់តែស្ថានទម្ងន់ទោសប៉ុណ្ណោះ)។

[52] មាត្រា១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

### ក.២ ការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ

ចៅក្រមស៊ើបសួរមានតួនាទីស្វែងរកភស្តុតាងទាំង ភស្តុតាងដាក់បន្ទុកនិងភស្តុតាងដោះបន្ទុកជនត្រូវចោទ។[53]នៅពេលដែលទទួលបានដីកា ហើយចៅក្រមស៊ើបសួរ និងបើកការស្រាវជ្រាវទៅលើការចោទនោះ ដោយការបើកការស្រាវជ្រាវនេះត្រូវធ្វើដូចខាងក្រោមៈ

- **ការដាក់អោយស្ថិតនៅក្រោមការត្រួតពិនិត្យ**

ជាដំបូងជនត្រូវចោទត្រូវបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ ហើយចៅក្រមត្រូវត្រួតពិនិត្យអត្តសញ្ញាណរបស់ជនត្រូវចោទ នឹងប្រាប់ពីការចោទប្រកាន់ទៅលើខ្លួន ជនត្រូវចោទអាចឆ្លើយ ឬមិនឆ្លើយបាននូវសំនួររបស់ចៅក្រមស៊ើបសួរ បន្ទាប់មកចៅក្រមស៊ើបសួរ និងប្រាប់ជនត្រូវចោទថាខ្លួនអាចមានសិទ្ធិជ្រើសរើសមេធាវីបាន ប៉ុន្តែបើជនត្រូវចោទជាអនីតិជនត្រូវមានមេធាវីអមជានិច្ច។ បន្ទាប់ពីបានរៀបរាប់ខាងលើមក ចៅក្រមស៊ើបនឹងសម្រេចថា គួរតែឃុំខ្លួន ឬក៏ដាក់អោយស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការទៅលើជនត្រូវចោទដែលមានឈ្មោះដីកា។ ប៉ុន្តែការសម្រេចរបស់ចៅក្រមស៊ើបសួរអាចអនុវត្តទៅលើជនណាអោយតែមានតម្រុយច្បាស់លាស់ ហើយស៊ីចង្វាក់គ្នាយ៉ាងខ្លាំងក្នុងការចូលរួមប្រព្រឹត្តបទល្មើសទោះ គ្មានចង្អុលប្រាប់ឈ្មោះក្នុងដីកាសន្និដ្ឋាន បញ្ជូនរឿងអោយស៊ើបសួរក៏ដោយ។ ការដាក់អោយស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការមានដូចខាងក្រោមៈ ករណីដែលជនត្រូវចោទបានបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ ចៅក្រមស៊ើបសួរបានសម្រេចជននោះអោយស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវការ ដោយការសម្រេចនេះអាចធ្វើដោយគំនិតផ្តួចផ្តើមផ្ទាល់ដោយខ្លួនឯង ឬ តាមសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា។ ហើយគោលបំណងដែលចៅក្រមស៊ើបសួរសម្រេចនេះគឺ ដើម្បីធានាអោយជនត្រូវចោទមកបង្ហាញខ្លួននៅចំពោះមុខតុលាការ បន្ថយសេរីភាពមួយចំនួន កុំអោយកើតបទល្មើសបន្តទៀតដាក់កំហិតនូវការព្យាបាលផ្នែកសង្គម ដើម្បីដាក់ប្រាក់ធានាដើម្បីទុកសងការខូចខាតដល់ជនរងគ្រោះ។[54]

- **ការសួរចម្លើយជនត្រូវចោទ**

កាលណាជនត្រូវចោទមានមេធាវីអម ចៅក្រមស៊ើបសួរត្រូវកោះមេធាវីយ៉ាងតិច៥(ប្រាំ)ថ្ងៃមុន មុខការសួរចម្លើយ។ ជនត្រូវចោទ អាចត្រូវសួរចម្លើយនៅចំពោះមុខមេធាវីរបស់ខ្លួនប៉ុណ្ណោះ ប្រសិនមេធាវីអវត្តមានតាមការកោះហៅនោះចៅក្រមស៊ើបសួរក៏សួរចម្លើយជនត្រូវចោទបានដែល ដោយចុះនិទ្ទេសអំពីអវត្តមានមេធាវីក្នុងកំណត់ហេតុ។

ក្នុងករណីពិសេសចៅក្រមស៊ើបសួរ អាចសួរចម្លើយជនត្រូវចោទដោយមិនបាច់កោះហៅមេធាវីរបស់

[53] មាត្រា១២៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[54] មាត្រា១២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ជនត្រូវចោទបាន ក្នុងភាពបន្ទាន់ដែលបណ្តាលមកពីគ្រោះថ្នាក់ដល់ស្លាប់ ឬ បណ្តាលមកពីការភ័យបាត់តម្រុយនៃភស្តុតាង ប្រភេទនៃបន្ទាន់នេះ ត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុ។ ករណីម៉្យាងទៀតការសួរចម្លើយជនត្រូវចោទដោយមិនបាច់កោះហៅមេធាវី ប្រសិនបើជនត្រូវបោះបង់យ៉ាងជាក់លាក់នូវវត្តមានរបស់ខ្លួន ក្នុងករណីចៅក្រមស៊ើបសួរត្រូវចុះក្នុង កំណត់ហេតុមួយផ្សេងទៀត ហើយជនត្រូវចោទត្រូវចុះហត្ថលេខា។[55] ពេលសួរចម្លើយជនត្រូវចោទ ព្រះរាជអាជ្ញា និងមេធាវី ក៏មានវត្តមានដែរ ហើយអាចលើកសំនួរទៅជនត្រូវចោទបាន បន្ទាប់ពីមានការអនុញ្ញាតពីចៅក្រមស៊ើបសួរ។[56]ជនត្រូវចោទមានសិទ្ធិស្នើសុំអោយចៅក្រមស៊ើបសួរ សួរចម្លើយខ្លួន ឬ សួរតទល់កាលណាថេរវេលា ៤ខែ បានកន្លងផុតទៅ ចាប់ពីពេលសួរចម្លើយនៅពេលបង្ហាញខ្លួនលើកដំបូង។ ក្រោយពីស្នើសុំ រយៈពេល១ខែកន្លងផុតទៅ ចៅក្រមស៊ើបសួរមិនបានកោះហៅ នោះជនត្រូវចោទនឹងប្តឹងផ្ទាល់ទៅសភាស៊ើបសួរដែលទទួលចម្លើយនេះដោយខ្លួនឯង។ កំណត់ដែលធ្វើដោយសភាស៊ើបសួរក្នុងការសួរចម្លើយត្រូវបញ្ជូនទៅចៅក្រមស៊ើបសួរ។[57]

- **ការស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី**

ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ត្រូវធ្វើនៅចំពោះមុខមេធាវី តាមការកោះហៅយ៉ាងត្រឹមត្រូវ បើមេធាវីជនត្រូវមិនចូលបង្ហាញខ្លួនតាមការកោះនោះទេ ចៅក្រមស៊ើបសួរនិងចុះនិទ្ទេសក្នុងកំណត់ហេតុ។ ករណីមួយចំនួនដែលចៅក្រមស៊ើបមិនចាំបាច់កោះមេធាវីរបស់ជនត្រូវចោទ ក្នុងករណីជនត្រូវចោទបោះបង់អវត្តមានមេធាវីខ្លួន និងម៉្យាងទៀត ភាពបន្ទាន់ ដែលបណ្តាលមកពីគ្រោះថ្នាក់ដល់ស្លាប់ ឬ បណ្តាលមកពីភាពភ័យខ្លាចបាត់បង់តម្រុយភស្តុតាង។ ការធ្វើកំណត់ហេតុត្រូវធ្វើដូចការសួរចម្លើយជនត្រូវចោទដែល។[58]

- **ការស្តាប់ចម្លើយសាក្សី**

ធ្វើការឆែកឆេរនៅចំពោះមុខសាក្សីនេះ។សាក្សីនេះមិនអាចជាមន្ត្រីនគរបាល ឬ កងរាជអាវុធហត្ថ ដែលចូលចៅក្រមស៊ើបសួរ អាចស្តាប់ចម្លើយបុគ្គលគ្រប់រូបដែលចម្លើយនោះអាចមានប្រយោជន៍នៅក្នុងការសម្តែងអោយឃើញការពិត។ មុនឆ្លើយសាក្សីត្រូវស្បថ ចៅក្រមស៊ើបសួរអាចម្លើយសាក្សី នៅដាច់ដោយឡែក ឬ ក៏សួរតទល់គ្នា ជាមួយដើមបណ្តឹងរដ្ឋប្បវេណី និង ជនត្រូវចោទ។ គ្រប់បុគ្គលដែលកោះហៅជាសក្សីត្រូវតែបង្ហាញខ្លួន។ ករណីរឹងទទឹងចៅក្រមស៊ើបសួរ អាចសុំអោយកងកម្លាំងសាធារណៈបង្ខំសាក្សីនេះអោយចូលបង្ហាញខ្លួនបាន

[55] មាត្រា១៤៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[56] មាត្រា១៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[57] មាត្រា១៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[58] មាត្រា១៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ចៅក្រមស៊ើបសួរចេញបញ្ជាអោយចូលមកបង្ហាញខ្លួន ។ប្រសិនបើសាក្សីឈឺ ឬមិនអាចធ្វើដំណើរបាន ចៅក្រមស៊ើបសួរ និងក្រឡាបញ្ជីអាចចុះទៅដល់ទីកន្លែងស្នាក់នៅរបស់សាក្សី ដើម្បីធ្វើការសួរចម្លើយ។[59]

- **ការឆែកឆេរ និងការចាប់យកវត្ថុតាង**

ចៅក្រមស៊ើបសួរ អាចធ្វើការឆែកឆេរចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬបើមិនមានអ្នកកាន់កាប់ទីកន្លែងទេ ចៅក្រមស៊ើបសួរត្រូវ ចាត់តាំងសាក្សី២(ពីរ)រូបហើយ រួមក្នុងប្រតិបត្តិការ នេះបានឡើយ។ ការឆែកឆេរមិនអាចធ្វើនៅមុនម៉ោង៦(ប្រាំមួយ)ព្រឹក និង ក្រោយម៉ោង១៨(ដប់ប្រាំបី)ល្ងាចបានទេ។តែមានករណីលើកលែងដូចខាងក្រោមៈ

- ក្នុងករណីឆែកឆេរនៅទីកន្លែងដែលបើកចំហដល់សាធារណៈជន

- ក្នុងករណីឆែកឆេរនៅគ្រប់ទីកន្លែងដែលផលិត រក្សាទុក ចែកចាយ ជួញដូរ ឬ ប្រើប្រាស់គ្រឿង ញៀន។[60]

នៅពេលដែលចៅក្រមស៊ើបសួរបានប្រមូលវត្ថុតាងដែល ជាតម្រុយមានប្រយោជន៍ក្នុងការបង្ហាញអោយឃើញការពិត វត្ថុដែលចាប់នោះចៅក្រមស៊ើបត្រូវតែបិទស្លាកបោះត្រាលើវត្ថុដែលចាប់យកនោះ។ វត្ថុដែលបានចាប់យកនោះចៅក្រមស៊ើបសួរ ត្រូវបង្ហាញចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬសាក្សីទាំង២(ពីរ)រូប។ ក្រោយពីបង្ហាញវត្ថុតាងហើយចៅក្រមស៊ើបត្រូវធ្វើកំណត់ហេតុនៃការចាប់យកវត្ថុតាង ដោយត្រូវមានហត្ថលេខា ចៅក្រមស៊ើបសួរ ក្រឡាបញ្ជីនិងអ្នកកាន់កាប់ទីកន្លែង ឬ សាក្សីទាំងពីររូប។[61] វត្ថុដែលចាប់យកអាចប្រគល់អោយវិញ ឬ មិនប្រគល់អោយវិញទៅម្ចាស់ដើម។ វត្ថុដែលប្រគល់អោយវិញលុះត្រាតែវត្ថុនោះមិនមានប្រយោជន៍ដែលបង្ហាញអោយឃើញការពិតហើយវត្ថុនេះនៅពេលចាប់យកគ្មានការជំទាស់អ្វីប្រាកដប្រជាពីម្ចាស់ដើមទេ។ ចំ ណែកឯងវត្ថុដែលចាប់យកហើយមិនប្រគល់អោយវិញដូចជា វត្ថុដែលមានគ្រោះថ្នាក់ដល់បុគ្គល ឬ ទ្រព្យសម្បត្តិដូចជាអាវុធ ឬជាតិផ្ទុះព្រមទាំងវត្ថុដែលកាន់កាប់មិនស្របច្បាប់។ វត្ថុទាំងអាចបំផ្លាញចោល ឬ រឹបអូសទុកជាកម្មសិទ្ធិរបស់រដ្ឋ។[62]ភស្តុតាងខ្លះដែលរកឃើញតម្រូវអោយមានការធ្វើកោសលវិច័យដូចជា ឈាម ស្បែក ស្លាកស្នាមផ្សេងៗព្រោះវាមានសារៈសំខាន់អាចអោយយើងរកវត្ថុតាងដទៃទៀតដែលជាប់ពាក់ពន្ធ័។

- **ការធ្វើកោសលវិច័យ**

ករណីដែលរឿងនោះពាក់ពន្ធ័នឹងបញ្ហាបច្ចេកទេសចោទឡើង ចៅក្រមស៊ើបសួរអាចបង្គាប់អោយធ្វើកោសលវិច័យដោយឯកឯង ឬតាមពាក្យសុំរបស់ព្រះរាជអាជ្ញា ឬជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី ដោយចៅក្រមស៊ើប

[59] មាត្រា១៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[60] មាត្រា១៥៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[61] មាត្រា ១៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[62] មាត្រា១៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ត្រូវចេញដីកាចាត់តាំងអ្នកជំនាញ បញ្ជាក់ពីបេសកម្មរបស់អ្នកជំនាញ និងរយៈពេលដែលត្រូវបំពេញបេសកម្ម។ នៅពេលដែលប្រគល់វត្ថុដែលពាក់ពន្ធ័អោយអ្នកជំនាញចៅក្រមស៊ើបត្រូវធ្វើកំណត់ហេតុពីការប្រគល់វត្ថុ។ សកម្មភាពរបស់អ្នកជំនាញទាំងអស់ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ចៅក្រមស៊ើបសួរ។[63]

- **ការស្តាប់ទូរស័ព្ទ**

ការស្តាប់ទូរស័ព្ទ គឺជាវិធានការមួយដែលប៉ះពាល់ខ្លាំងដល់សិទ្ធិបុគ្គលឯកជន ទាក់ទិននឹងការរក្សាការសម្ងាត់នៃការឆ្លងឆ្លើយ។ ប៉ុន្តែចៅក្រមស៊ើបសួរមានសិទ្ធិក្នុងការបង្គាប់អោយអង្គភាពសាធារណៈ ឬ មន្ត្រីរាជការជំនាញតាំងឧបករណ៍ស្តាប់ និងថតការសន្ទនាតាមទូរស័ព្ទ បង្គាប់អោយចាប់ និងថតគ្រប់ការឆ្លើយឆ្លងគ្នា តាមគ្រប់មធ្យោបាយ ទូគមនាគមន៍ផ្សេងទៀតដូចជាសារតាមទូរសារតាមអិនធើណែត។ តែការបង្គាប់នេះត្រូវចេញដីកាហើយក្នុងដីកាត្រូវបញ្ជាក់ពីប្រភេទទំនាក់ទំនងដែលត្រូវចាប់ និងរយៈពេលនៃបេសកម្ម។ ក្រោយពលដែលបំពេញបេសកម្មនេះហើយ អង្គភាពសាធារណៈ ឬ មន្ត្រីរាជការត្រូវចម្លងជាលាយលក្ខណ៍អក្សរនូវ សម្លេងដែលបានថត ហើយត្រូវប្រគល់ជូនចៅក្រមស៊ើបសួរ។[64]

### ក.៣ ដីការចេញដោយចៅក្រមស៊ើបសួរ

នៅក្នុងដំណាក់ស៊ើបសួរចៅក្រមស៊ើបសួរបានចេញដីកាជា ច្រើនដែលធ្វើអោយការស៊ើបសួរមានដំណើរការងាយស្រួលក្នុងការអនុវត្ត និងសម្រួលក្នុងការស្វែងរកភស្តុតាង។ ហើយការចេញដីកានីមួយៗ គ្មានលំដាប់លំដោយទេពោលគឺការចេញដីកាចៅក្រមស៊ើបសួរត្រូវពិនិត្យមើលភាពត្រឹមត្រូវតាមកាលៈទេសៈ។ ដីកាដែលចៅក្រមស៊ើបសួរចេញក្នុងពេលបំពេញបេសកម្មមានដូចខាងក្រោមៈ

- **ដីការចាត់អោយស៊ើបសួរជំនួស**

ជាដីកាដែលចៅក្រមស៊ើបសួរប្រគល់សិទ្ធិអោយទៅចៅក្រមនៃតុលាការរបស់ខ្លួន ឬ តុលាការផ្សេងទៀត ឬ មន្ត្រីនគរបាលយុត្តិធម៌ ធ្វើកិច្ចស៊ើបសួរជំនួយខ្លួន។[65] ចំណែក ការអនុវត្តទៅលើដីកានេះគឺមានភាពមិនដូចគ្នាទេគឺ ចៅក្រមណាម្នាក់ ដែលចៅក្រមស៊ើបសួរចាត់អោយស៊ើបសួរជំនួស ចៅក្រមរូបនោះអាចប្រើប្រាស់អំណាចទាំងអស់របស់ចៅក្រមស៊ើបសួរបាន។[66] ប៉ុន្តែ មន្ត្រីនគរបាលយុត្តិធម៌នៅពេលដែលចៅក្រមស៊ើបសួរ ចាត់អោយសួរជំនួសចៅក្រមស៊ើបសួរ នឹងកម្រិតការអនុវត្តខ្លះទៅលើមន្ត្រីនគរបាលយុត្តិធម៌។ នៅពេលអនុវត្តដីកាចាត់អោ

[63] មាត្រា១៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[64] មាត្រា ១៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[65] មាត្រា ១៧៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[66] មាត្រា១៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

យសុើបសួរជំនួស មន្ត្រីនគរបាលយុត្តិធម៌ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ចៅក្រមសុើបសួរ នឹងត្រូវរាយការណ៍ទៅចៅក្រមសុើបសួរនោះប៉ុណ្ណោះ។[67] ចៅក្រមសុើបសួរមិនអាចប្រគល់សិទ្ធិមួយចំនួនឲ្យមន្ត្រីនគរបាលយុត្តិធម៌បានទេដូចជា ការសួរចម្លើយជនត្រូវចោទ ការសួរចម្លើយដើម្បីបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែសាក្សី មន្ត្រីនគរបាលយុត្តិធម៌អាចសួរចម្លើយបានតែ ត្រូវអោយសាក្សីស្បថ ជាមុន។ ប្រសិនបើធ្វើការឃាត់ខ្លួនក្នុងក្របខណ្ឌនៃការអនុវត្តដីកាចាត់អោយសុើបសួរជំនួស អំណាចដែលប្រគល់អោយព្រះរាជអាជ្ញា ត្រូវបានប្រើប្រាស់ដោយចៅក្រមសុើបសួរ។ហើយដីកាចាត់អោយសុើបសួរជំនួសចៅក្រមសុើបសួរអាចដកហូតដីកាបានគ្រប់ពេលវេលា។

- **ដីកាបង្គាប់អោយចូលខ្លួន**

ដីកាបង្គាប់អោយខ្លួន គឺជាបញ្ជាដល់បុគ្គលណាម្នាក់អោយចូលទៅបង្ហាញខ្លួនចំពោះមុខចៅក្រមសុើបសួរ។ ដីកានេះអាចចេញទៅលើជនត្រូវចោទ ឬ បុគ្គលមានតម្រុយពិរុទ្ធភាពប៉ុណ្ណោះ។[68]

ដីកានេះត្រូវអោយដំណឹងដល់បុគ្គលពាក់ពន្ធ័ ដោយមន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ ឬអាជ្ញាសាលា។

បុគ្គលដែលពាក់ពន្ធ័ទទួលចុងដីកាហើយចុះហត្ថលេខាលើដើមដីកាដែលត្រូវបង្វិលជូនទៅចៅក្រមសុើបវិញ។[69]

- **ដីកាបង្គាប់អោយនាំខ្លួន**

ដីកាបង្គាប់អោយនាំខ្លួន គឺជាបញ្ជាដល់កងកម្លាំងសាធារណៈអោយចាប់ខ្លួន និងនាំខ្លួនបុគ្គលេណាម្នាក់ទៅចំពោះមុខចៅក្រមសុើបសួរ។ ដីកានេះអាចចេញទៅលើជនត្រូវចោទ ឬបុគ្គលណាម្នាក់ដែលមានពិរុទ្ធភាពប៉ុណ្ណោះ។[70] ដីកានេះត្រូវប្រគល់អោយមន្ត្រីនគរបាលយុត្តិធម៌។ នៅក្នុងករណីបន្ទាន់ត្រូវផ្សព្វផ្សាយដល់អង្គភាពនគរបាល ឬកងរាជអាវុធហត្ថតាមគ្រប់មធ្យោបាយ។ មន្ត្រីនគរបាលយុត្តិធម៌ មិនអាចចូលទៅក្នុងលំនៅឋានរបស់បុគ្គលពាក់ពន្ធ័មុនម៉ោង (ប្រាំមួយ) និងក្រោយម៉ោង (ដប់ប្រាំបី)បានទេ ត្រូវជូនដំណឹងដល់ចៅក្រមសុើបសួរអំពីការលំបាកនៃការអនុវត្តរបស់ខ្លួន។[71] ក្រោយពីចាប់ខ្លួនបាន ប្រសិនបើមិនអាចនាំទៅបង្ហាញខ្លួននៅចំពោះមុខចៅក្រមសុើបសួរបានទេ ដោយមូលហេតុនៃកាលៈទេសៈត្រូវនាំបុគ្គលនោះទៅអង្គភាពនគរបាល ឬ កងរាជអាវុធហត្ថក្នុងមណ្ឌលឃុំខ្លួន ឬទៅក្នុងពន្ធនាគារ។ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវប្រើគ្រប់មធ្យោបាយទាំងអស់

---

[67] មាត្រា១៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[68] មាត្រា១៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[69] មាត្រា១៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[70] មាត្រា១៩០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[71] មាត្រា១៩២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ដើម្បីនាំខ្លួនជននេះទៅ បង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរយ៉ាងឆាប់បំផុតដែលអាចធ្វើទៅបាន។[72]

- **ដីកាបង្គាប់អោយចាប់ខ្លួន**

ដីកាបង្គាប់អោយចាប់ខ្លួន គឺជាបញ្ជាដល់កងកម្លាំងសាធារណៈអោយស្រាវជ្រាវរកចាប់ និងអោយនាំខ្លួនបុគ្គលនោះ ទៅក្នុងពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ដល់ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនអោយទទួលនិងឃុំខ្លួនបុគ្គលនោះ។

ចៅក្រមស៊ើបសួរអាចចេញដីកានេះបានលុះត្រាតែបានបំពេញលក្ខខណ្ឌដូចខាងក្រោមៈ

- បទល្មើសដែលចោទប្រកាន់ជាបទល្មើសឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ។
- បុគ្គលដែលពាក់ពន្ធបានគេចខ្លួន មិនដឹងជាស្ថិតនៅទៅកន្លែងណា ឬស្ថិតនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា។[73] មុននឹងចេញដីកា នេះចៅក្រមស៊ើបសួរត្រូវតែទទួល យោបល់ពីព្រះរាជអាជ្ញាពីព្រោះព្រះរាជអាជ្ញាជាអ្នក ធានារ៉ាប់រងផ្សព្វផ្សាយដីកាបង្គាប់អោយចាប់ខ្លួន។[74]មន្ត្រីនគរបាលយុត្តិធម៌អាចចូលក្នុងលំនៅឋានរបស់បុគ្គលដែលពាក់ព័ន្ធដោយពុំចាំបាច់មានអនុញ្ញាតអោយឆែកឆេរទេ ហើយមន្ត្រីនគរបាលយុត្តិធម៌មិនអាចចូលមុនម៉ោងប្រាំមួយ និងក្រោយម៉ោងដប់ប្រាំបីបានទេ។[75] ក្នុងករណីចាំបាច់ដីកានេះអាចផ្សព្វផ្សាយជាអន្តរជាតិតាមរយៈក្រសួងយុត្តិធម៌ ដោយប្រើយន្តការនានាដែលមានប្រសិទ្ធិភាព។[76] នៅពេលចាប់ខ្លួនបាន ត្រូវនាំបុគ្គលនោះទៅបង្ហាញខ្លួនចំពោះមុខចៅក្រមស៊ើបសួរ ឬអ្នកជំនួសក្នុងរយៈពេលខ្លីបំផុតប្រសិនបើស្ថិតនៅក្នុងដំណាក់កាលស៊ើបសួរ។ ប្រសិនបើមិនបាននាំខ្លួនទៅបង្ហាញចៅក្រមស៊ើបសួរ ឬ អ្នកជំនួស នៅថ្ងៃបន្ទាប់ពីការចាប់ខ្លួនទេ បុគ្គលនោះត្រូវតែព្រះរាជអាជ្ញានាទីកន្លែងឃុំខ្លួនស្តាប់ចម្លើយ ដោយធ្វើកំណត់ហេតុបញ្ជូនទៅចៅក្រមស៊ើបសួរ។ ចិរវេលានៃការឃុំខ្លួននេះ ត្រូវគិតបញ្ចូលក្នុងចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន(ប្រសិនបើមាន)។[77] នៅពេលដែលជនត្រូវចោទបានជួបចៅក្រមស៊ើបសួរហើយ ដីកាចាប់ខ្លួនលែងមានអនុភាពហើយ បើចង់ឃុំខ្លួនបុគ្គលនេះបន្តទៀតដើម្បីស្វែងរកភស្តុតាងបន្ថែម ត្រូវប្រើវិធានផ្សេង (ដីកាឃុំខ្លួន បណ្តោះអាសន្ន និង ដីកាបង្គាប់អោយឃុំខ្លួន)។

- **ដីកាបង្គាប់អោយឃុំខ្លួន**

[72] មាត្រា១៩៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[73] មាត្រា១៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[74] មាត្រា១៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[75] មាត្រា១៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[76] មាត្រា២០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[77] មាត្រា២០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ជាដីកា ដែលបញ្ជាដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនអោយទទួល និងឃុំខ្លួនជនត្រូវចោទរហូតទាល់តែបានទទួលដំណឹង អោយដោះលែងអោយមានសេរីភាពវិញ។[78] ប្រធានពន្ធនាគារឬ មណ្ឌលឃុំខ្លួនរក្សាដើមដីកា ឬចុងដីកាបង្គាប់អោយឃុំខ្លួននេះដែលបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម។[79]ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់អោយឃុំខ្លួនបាន លុះត្រាតែជនត្រូវចោទជាកម្មវត្ថុនៃដីកាសម្រេចអោយឃុំខ្លួនបណ្តោះអាសន្ន។

- **ដីកាបង្គាប់អោយឃុំខ្លួនបណ្តោះអាសន្ន**

ការឃុំខ្លួនបណ្តោះអាសន្ន គឺជាវិធានការមួយដែលផ្តល់អំណាចធំបំផុតទៅអោយចៅក្រមស៊ើបសួរ។ ប៉ុន្តែវាធ្វើអោយប៉ះពាល់ដល់សេរីភាពជនត្រូវចោទ ព្រោះជាគោលការណ៍ជនត្រូវចោទត្រូវតែមានសេរីភាព ហើយការឃុំខ្លួនបុគ្គលណាម្នាក់ ត្រូវសេចក្តីសម្រេចស្ពាពពីតុលាការ។ តែដោយយោងទៅលើភាពចាំបាច់ ទើបចៅក្រមស៊ើបសួរសម្រេចក្នុងការឃុំខ្លួនបណ្តោះអាសន្នទៅបុគ្គលណាម្នាក់ដោយសម្រួលក្នុងការស៊ើបសួរ។ ការឃុំខ្លួនបណ្តោះអាសន្ន អាចអនុវត្តបានតែក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋឬបទមជ្ឈិមដែលមានការផ្តន្ទាទោសដាក់ពន្ធនាគារស្មើ ឬ លើស ១(មួយ) ឆ្នាំ។[80]

មូលហេតុដែលចៅក្រមស៊ើបសួរអាចឃុំខ្លួនជនត្រូវចោទបានមានដូចខាងក្រោមៈ

- ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំអោយកើតជាថ្មី។
- ដើម្បីរារាំងកុំអោយមានការគាបសង្កត់សាក្សី ឬ ជនរងគ្រោះ ឬដើម្បីរារាំងកុំមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទនឹងអ្នកសមគំនិត។
- ដើម្បីរក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ។
- ដើម្បីធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី។
- ដើម្បីការពារសន្តិសុខអោយជនត្រូវចោទ។
- ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈកុំអោយ មានការច្របូកច្របល់ដែលបណ្តាល ពីបទ ល្មើស។[81]

កាលណាចៅក្រមស៊ើបសួរ ចេញដីកាឃុំខ្លួនបណ្តោះអាសន្ន ចៅក្រមស៊ើបសួរ ត្រូវជូនដំណឹងភ្លាមទៅព្រះរាជអាជ្ញា និងជនត្រូវចោទ។[82] ព្រះរាជអាជ្ញាអាចស្នើសុំអោយចៅក្រមស៊ើបសួរ ធ្វើការឃុំខ្លួនជនត្រូវចោទបណ្តោះ

[78] មាត្រា ២២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[79] មាត្រា២២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[80] មាត្រា២០០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[81] មាត្រា២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[82] មាត្រា២០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

អាសន្ន ដោយការស្នើនេះត្រូវធ្វើដោយផ្ទាល់មាត់ ឬធ្វើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ស្នើសុំទៅចៅក្រមស៊ើបសួរ ប្រសិនបើចៅក្រមស៊ើបសួរមិនព្រមធ្វើតាមការស្នើសុំ នោះចៅក្រមស៊ើបសួរត្រូវចេញ ដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្ន ក្នុងរយៈពេល៥ថ្ងៃ ដោយមិនចាំបាច់មានសំអាងហេតុ។ តែត្រូវជូនដំណឹងទៅដល់ព្រះរាជអាជ្ញាវិញ។ ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចនៅក្នុងរយៈពេល៥ថ្ងៃ ព្រះរាជអាជ្ញាអាចធ្វើពាក្យបណ្តឹងទៅសភាស៊ើបសួរ ដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។[83] ហើយការឃុំខ្លួនក៏ត្រូវមានថិរវេលាទៅ តាមប្រភេទបទល្មើស និងអាយុជនត្រូវចោទដែល។

ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នមានដូចខាងក្រោមៈ

| អាយុ | ក្រោម១៤ឆ្នាំ | ពី១៤ឆ្នាំដល់ក្រោម១៦ឆ្នាំ | ពី១៦ឆ្នាំដល់ក្រោ១៨ឆ្នាំ | ១៨ឆ្នាំឡើងទៅ |
|---|---|---|---|---|
| បទមជ្ឈិម | 0 | ២ខែ+0 | ៤ខែ+0 | ៤ខែ +(២ខែ x ១) |
| បទឧក្រិដ្ឋ | 0 | ៤ខែ+0 | ៦ខែ+0 | ៦ខែ+(៦ខែ X ២) |

កាលណាចៅក្រមស៊ើបសួរសម្រេច ពន្យារពេលឃុំខ្លួនបណ្តោះអាសន្នត្រូវអោយដំណឹងដល់ជនត្រូវចោទ។ ការពន្យារពេលនេះធ្វើឡើងតាមដីកាដោយមានសំអាងហេតុ។ ចំពោះបទមជ្ឈិមថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ខាងលើមិនត្រូវ លើពាក់កណ្តាលនៃអប្បបរមានៃទោសដែល ច្បាប់បានកំណត់ ឡើយ។

**ឧទាហរណ៍:** បទល្មើសមួយត្រូវបានច្បាប់កំណត់ផ្តន្ទាទោសពី១ (មួយ)ឆ្នាំ ទៅ៣ (បី)ឆ្នាំ។ ដូចនេះការឃុំខ្លួនបណ្តោះអាសន្ន មិនត្រូវអោយលើសពី៦ (ប្រាំមួយ)ខែទេ។ ចំពោះបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ បទឧក្រិដ្ឋប្រល័យពូជសាសន៍ ឬក៏ឧក្រិដ្ឋសង្គ្រាមមិនឃុំខ្លួនបណ្តោះអាសន្នលើសពី១ឆ្នាំបានទេ។ ប៉ុន្តែចៅក្រមស៊ើបអាចសុំធ្វើការពន្យារម្តងបាន ១ឆ្នាំ បានពីរដង។ ការដោះលែងជនណាម្នាក់ដែលឃុំខ្លួនបណ្តោះអាសន្ន អោយនៅក្រៅឃុំវិញអាចធ្វើបានតាមវិធីដូចខាងក្រោមៈ

- **ការអោយនៅក្រៅឃុំដោយចៅក្រមស៊ើបសួរ**

កាលណាចៅក្រមស៊ើបសួរយល់ឃើញថា ការឃុំខ្លួនបណ្តោះអាសន្នលែងមានភាពចំបាច់ នោះចៅក្រមអាចបង្គាប់អោយដោះលែងជនត្រូវចោទអោយនៅក្រៅឃុំវិញបានគ្រប់ពេលវេលា ដោយជូនព័ត៌មានដល់ព្រះរាជអាជ្ញាដើម្បីសុំយោបល់ ហើយបញ្ជូនសំណុំរឿងទៅអោយព្រះរាជអាជ្ញាពិនិត្យ។ ព្រះរាជអាជ្ញាផ្តល់យោលបល់របស់ខ្លួននៅក្នុងរយៈពេលយ៉ាងខ្លីបំផុត។ ចៅក្រមស៊ើបសួរចម្រេចយ៉ាងយូរបំផុត៥(ប្រាំ)ថ្ងៃ បន្ទាប់ពីការបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។ ក្នុងករណីបន្ទាន់ចៅក្រមស៊ើបសួរ អាចបង្គាប់អោយដោះលែងជនត្រូវចោទនៅក្រៅឃុំភ្លាម

[83] មាត្រា២០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

បាន ដោយមិនចាំបាច់សុំយោបល់ព្រះរាជអាជ្ញាដូចជាជនត្រូវចោទ មានជម្ងឺធ្ងន់ធ្ងរត្រូវព្យាបាលនៅខាងក្រៅ។ ប៉ុន្តែត្រូវចុះមូលហេតុនៃការបន្ទាន់នេះក្នុងដីការបស់ខ្លួន។[84]

- **ការបណ្តឹងសុំនៅក្រៅឃុំដោយព្រះរាជអាជ្ញា**

ព្រះរាជអាជ្ញាធ្វើសេចក្តីសន្និដ្ឋានសុំអោយដោះលែងជនត្រូវចោទទៅចៅក្រមស៊ើបសួរ។ ចៅក្រមស៊ើបសួរត្រូវសម្រេចក្នុងរយៈពេល៥ថ្ងៃ ថាយល់ព្រមដោះលែងអោយនៅក្រៅឃុំ ឬ មិនព្រមដោះលែងអោយនៅក្រៅឃុំ។ ប្រសិនបើចៅក្រមស៊ើបសួរពុំបានសម្រេចក្នុងរយៈពេល៥ថ្ងៃនេះទេ ព្រះរាជអាជ្ញា អាចសុំប្តឹងទៅសភាស៊ើបសួរដើម្បីសម្រេចជំនួសក្នុងរយៈ១៥ថ្ងៃ។ ចៅក្រមស៊ើបសួរត្រូវ អនុវត្តតាមការសម្រេចរបស់សភាស៊ើបសួរ។ ការសម្រេចមិនព្រមដោះលែងអោយនៅក្រៅឃុំត្រូវតែមានសំអាងហេតុ។[85]

- **ការបណ្តឹងសុំនៅក្រៅឃុំរបស់ខ្លួនជនត្រូវចោទ** ជនត្រូវចោទអាចដាក់ពាក្យសុំទៅ ចៅក្រមស៊ើបសួរ អោយដោះលែងនៅក្រៅឃុំបានគ្រប់ពេលវេលា។ ចៅក្រមស៊ើបសួរបញ្ជូនពាក្យនោះនិងសំណុំរឿងភ្លាមទៅព្រះរាជអាជ្ញាពិនិត្យ ដើម្បីផ្តល់យោបល់ក្នុងរយៈពេលខ្លីបំផុត។ ចៅក្រមស៊ើបសួរសម្រេចយ៉ាងយូរបំផុត៥(ប្រាំ)ថ្ងៃ បន្ទាប់ពីពេលបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។ ប្រសិនបើចៅក្រមស៊ើបសួរបដិសេធ ជនត្រូវចោទអាចដាក់ពាក្យសុំនៅក្រៅឃុំសាជាថ្មីម្តងទៀតទៅចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរក្នុងរយៈពេល ១ខែ បន្ទាប់ពីមានសេចក្តីសម្រេចបដិសេធពាក្យសុំលើកមុន។ ចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរត្រូវសម្រេចក្នុងរយៈពេល ៥ថ្ងៃបន្ទាប់ពីបានទទួលពាក្យសុំ។ ដីកាសម្រេចមិនព្រមដោះលែងត្រូវមានសំអាងហេតុ។ ប្រសិនបើចៅក្រមស៊ើបសួរ មិនបានសម្រេចក្នុងរយៈពេល៥ថ្ងៃទេ ជនត្រូវចោទអាចធ្វើពាក្យប្តឹងផ្ទាល់ទៅសភាស៊ើបសួរ ដែលត្រូវសម្រេចក្នុងរយៈពេល១៥ ថ្ងៃជំនួសចៅក្រមស៊ើបសួរ។ ប្រសិនបើចៅក្រមស៊ើបសួរយល់ព្រម ចៅក្រមស៊ើបសួរអាចដោះលែង ឬដាក់ជននោះអោយស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបាន។[86]ជាគោលការណ៍សេចក្តីសម្រេចអោយនៅក្រៅឃុំ មិនអាចយកទៅអនុវត្តបានភ្លាមទេ គឺត្រូវទុកអោយផុតរយៈពេលប្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាសិន។ លើកលែងតែព្រះរាជអាជ្ញាយល់ព្រមជាលាយលក្ខណ៍អក្សរ និងករណីបន្ទាន់ប៉ុណ្ណោះទើបអាចដោះលែងភ្លាមបាន។

- **ដីកាសម្រេចដាក់ជនត្រូវចោទស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ**

ក្នុងករណីចៅក្រមស៊ើបសួរ សម្រេចមិនឃុំខ្លួនជនត្រូវចោទ ឬដោះលែងជនត្រូវចោទអោយនៅ ក្រៅឃុំ

[84] មាត្រា២១៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[85] មាត្រា២១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[86] មាត្រា២១៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

បណ្ដោះអាសន្នចៅក្រមស៊ើបសួរអាចសម្រេចដាក់ជនត្រូវចោទអោយស្ថិត ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលា។ ការត្រួតពិនិត្យតាមផ្លូវតុលាការមានអនុភាពបង្គាប់ជនត្រូវចោទ ដែលនៅក្រៅឃុំអោយគោរពកាតព្វកិច្ចមួយចំនួនដូចជាៈ

- មិនត្រូវចេញក្រៅព្រំប្រទល់ដែនដី ដែលកំណត់ដោយចៅក្រមស៊ើបសួរ។
- មិនត្រូវផ្លាស់ប្ដូរលំនៅឋាន ដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបសួរ។
- មិនត្រូវទៅកាន់ទីកន្លែងខ្លះដែលកំណត់ដោយចៅក្រមស៊ើបសួរ។
- ត្រូវចូលបង្ហាញខ្លួនតាមការកំណត់នៅអង្គភាពនគរបាល ឬកងរាជអាវុធហត្ថដែលចាត់តាំងដោយចៅក្រមស៊ើបសួរ។
- ត្រូវឆ្លើយតបនឹងដីកាកោះហៅពីគ្រប់បុគ្គលដែលចាត់តាំងដោយចៅក្រមស៊ើបសួរ។
- ប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជី គ្រប់ឯកសារបញ្ជាក់អំពីអត្តសញ្ញាណ។
- មិនត្រូវបើករថយន្ត។
- មិនត្រូវទទួល ឬក៏ជួបបុគ្គលមួយចំនួនដែលចង្អុលបង្ហាញដោយចៅក្រមស៊ើបសួរ។
- ដាក់ប្រាប់ធានា ដែលមានចំនួនប្រាក់ធានានិងថិរវេលាបង់ប្រាក់នេះត្រូវកំណត់ដោយចៅក្រមស៊ើបសួរដោយផ្អែកលើធនធានរបស់ជនត្រូវចោទ។
- មិនត្រូវកាន់កាប់នឹងយកអាវុធតាមខ្លួន។ ត្រូវប្រគល់អាវុធជូនដល់ការិយាល័យក្រឡាបញ្ជីនូវអាវុធដែលជនត្រូវចោទកាន់កាប់។
- ត្រូវប្រគល់ខ្លួនអោយពេទ្យពិនិត្យព្យាបាល និងជាយថាហេតុដាក់អោយស្ថិតនៅក្រោមរបបព្យាបាលរោគក្នុងមន្ទីរពេទ្យ។
- មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈខ្លះ។

ក្នុងករណីនេះចៅក្រមស៊ើបសួរមិនអាចហាមឃាត់ការអនុវត្តនូវអាណត្តិបោះឆ្នោត ឬសកម្មភាពសហជីពបានទេ។[87]ការត្រួតពិនិត្យតាមផ្លូវតុលាការ មិនត្រូវបានអនុវត្តចំពោះអនីតិជនអាយុតិចជាង១៤ឆ្នាំទេ។[88]

កាលណាចៅក្រមស៊ើបសួរដាក់ជនណាម្នាក់អោយស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវ ចៅក្រមស៊ើបសួរអាចធ្វើតាមការផ្តួចផ្តើមរបស់ខ្លួន ឬ សេចក្ដីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញា ត្រូវបណ្ដឹងសុំអោយចៅក្រម

[87] មាត្រា២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[88] មាត្រា២២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ស៊ើបសួរដាក់ជនត្រូវចោទអោយស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ប្រសិនបើចៅក្រមស៊ើបសួរមិនសម្រេចតាមការសុំទេ ត្រូវចេញដីកាបដិសេធក្នុងរយៈពេល៥(ប្រាំ)ថ្ងៃ និងត្រូវជូនដំណឹងក្នុងរយៈពេលយ៉ាងខ្លីបំផុតដល់ព្រះរាជ អាជ្ញា។ ប្រសិនបើមិនសម្រេចក្នុងរយៈពេល៥(ប្រាំ)ថ្ងៃទេ ព្រះរាជអាជ្ញាអាចប្តឹងទៅសភាស៊ើបសួរដែលសម្រេចជំនួស។ ចៅក្រមស៊ើបសួរ ត្រូវអនុវត្តសេចក្តីសម្រេចរបស់សភាស៊ើប។ ការត្រួតពិនិត្យតាមផ្លូវតុលាការអាចធ្វើការកែប្រែ ឬលុបចោលបាន តាមគំនិតរបស់ចៅក្រមស៊ើបសួរ តាមបណ្តឹងសុំរបស់ព្រះរាជអាជ្ញា ឬតាមបណ្តឹងសុំរបស់ជនត្រូវចោទ។ ប្រសិនបើជនត្រូវចោទគេចវេះពីកាតព្វកិច្ចត្រួតពិនិត្យតាមផ្លូវតុលាការ ចៅក្រមស៊ើបសួរអាចសម្រេចឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្នបាន។

### ខ.ការបិទការស៊ើបសួរ

#### ខ.១តាមរយៈព្រះរាជអាជ្ញា

កាលណាចៅក្រមស៊ើបសួរយល់ឃើញថា ការស៊ើបសួរបានបញ្ចប់ ចៅក្រមស៊ើបសួរនឹងជូនព័ត៌មានដល់ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវី។ ក្រោយពីផ្តល់ព័ត៌មានបាន ២(ពីរ)ថ្ងៃចៅក្រមស៊ើបសួរ ត្រូវបញ្ជូនសំណុំរឿងអោយព្រះរាជអាជ្ញាពិនិត្យ។ ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថាមានការចាំបាច់ត្រូវធ្វើកិច្ច ស៊ើបសួរថ្មីព្រះរាជអាជ្ញា នឹងត្រូវធ្វើតាមមាត្រា១៣២(ការស្នើសុំអោយបំពេញកិច្ចដោយព្រះរាជអាជ្ញា) ដែលមានចែង ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។ ក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃប្រសិនបើជនត្រូវចោទត្រូវឃុំខ្លួន និង១(មួយ)ខែ ក្នុងករណីដែលជនត្រូវចោទនៅក្រៅឃុំ ព្រះរាជអាជ្ញានឹងបង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរវិញដោយភ្ជាប់ ដីកាសន្និដ្ឋានជាមួយផង។ ចិរវេលានេះត្រូវគិតពីថ្ងៃដែលព្រះរាជអាជ្ញាបានទទួលសំណុំរឿង។

ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញដូចចៅក្រមស៊ើបសួរដែរថា ការស៊ើបសួរត្រូវតែបញ្ចប់នោះព្រះរាជអាជ្ញាត្រូវធ្វើដីសន្និដ្ឋានស្ថាពរជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ។ ព្រះរាជអាជ្ញាអាចប្តឹងសុំអោយចៅក្រមស៊ើបសួរសម្រេចបញ្ជូនខ្លួនជនត្រូវចោទទៅកាន់តុលាការជំនុំជំម្រះ ឬ លើកលែងលែងការចោទប្រកាន់។[89]

#### ខ.២ ដីកាដំណោះស្រាយ

ដីកាដំណោះស្រាយ គឺជាដីកាមួយដែលបិទកិច្ចស៊ើបសួររបស់ចៅក្រមស៊ើបសួរ។ ដីកានេះអាចជាដីកាដែលបញ្ជូនជនត្រូវចោទទៅជំនុំជម្រះផ្ទាល់ ឬ ជាដីកាលើកលែងការចោទប្រកាន់។ ប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថាអំពើនោះជា បទឧក្រិដ្ឋ ឬ បទមជ្ឈិម ឬ បទលហុ នឹងសម្រេចបញ្ជូនជនត្រូវចោទទៅជំនុំជំម្រះផ្ទាល់។ ដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ត្រូវរៀបរាប់អំពើដែលត្រូវចោទប្រកាន់ នឹងឈ្មោះបទល្មើសតាមច្បាប់ ហើយដីកានេះចៅក្រមស៊ើបសួរត្រូវបញ្ជូនសំណុំរឿងជាបន្ទាន់ទៅប្រធានតុលាការ ដើម្បីកំណត់ពេលសវនាការជំនុំ

[89] មាត្រា២៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ជម្រះលើជនត្រូវចោទ។ ប្រសិនបើចៅក្រមស៊ើបសួរចេញដីការលើលែងការចោទប្រកាន់ត្រូវមានករណីដូចខាងក្រោមៈ

- អំពើប្រព្រឹត្ត មិនមែនជាបទឧក្រិដ្ឋ ឬ បទមជ្ឈិម ឬ បទលហុ
- ជនដែលប្រព្រឹត្តអំពើនោះនៅតែមិនស្គាល់(អញ្ញាតជន)
- គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ

ដីកាដំណោះស្រាយត្រូវតែមានសំអាងហេតុ។ ដីកាដំណោះស្រាយត្រូវជូនដំណឹងក្នុងរយៈពេលយ៉ាងខ្លីបំផុតដល់ព្រះរាជអាជ្ញា ជនត្រូវចោទ នឹងដើមបណ្តឹងរដ្ឋប្បវេណី។ នៅពេលចៅក្រមស៊ើបសួរចេញដីកាដំណោះស្រាដីកានេះ អាចបញ្ចប់ការឃុំខ្លួនបណ្តោះអាសន្ន ឬ ការត្រួតពិនិត្យតាមផ្លូវតុលាការបានក្នុងលក្ខខណ្ឌដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។[90]

## កថាខណ្ឌទី២ បណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ

### ក.និយមន័យ

បណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ គឺជាបណ្តឹងដែលភាគីណាមួយក្នុងរឿងក្តីដែលមិនសុខចិត្ត នឹងសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរប្តឹងទៅតុលាការជាន់ខ្ពស់ (ទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៍) ដែលបណ្តឹងនេះទាក់ទងនឹងដីកាសម្រេចរបស់ចៅក្រមស៊ើបសួរនៅមន្ទីរស៊ើបសួរនៃសាលាដំបូង ដើម្បីទាមទារអោយវិនិច្ឆ័យលើសេចក្តីសម្រេចមុនអង្គសេចក្តី ដែលចេញដោយចៅក្រមស៊ើបសួរ។

ឧទាហរណ៍ៈ លោក ក ប្តឹងលោក ខ ប្តឹងពីបទលួចនៅពេលដែលព្រះរាជអាជ្ញាចេញដីកាសន្និដ្ឋាន បញ្ជូនរឿងអោយស៊ើបសួរទៅចៅក្រមស៊ើបសួរតែនៅ ពេលអនុវត្តនីតិវិធីចៅក្រមស៊ើបសួរចេញដីកាសម្រេចឃុំខ្លួនជនត្រូវចោទ ខ បណ្តោះអាសន្ន តែជនត្រូវចោទ ខ បានធ្វើពាក្យបណ្តឹងទៅសភាស៊ើបសួរ ដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរដែលឃុំខ្លួនបណ្តោះអាសន្ន។ នេះមានន័យថាលោក ខ មិនបានធ្វើពាក្យបណ្តឹងទៅលើអង្គសេចក្តី(បទលួច) នោះទេ តែខ្លួនធ្វើការបណ្តឹងមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរ(ការឃុំខ្លួនបណ្តោះអាសន្ន)ដែលនេះគេហៅថាសេចក្តីសម្រេចមុនអង្គសេចក្តី។

### ខ.សិទ្ធិប្តឹងឧទ្ធរណ៍ ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ

នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់សិទ្ធិអោយភាគីមួយចំនួនអាចធ្វើបណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរបាន។ហើយបុគ្គលដែលអាចធ្វើ បណ្តឹងឧទ្ធរណ៍បានមានដូចខាងក្រោមៈ

[90] មាត្រា២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

- **អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងព្រះរាជអាជ្ញា**

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍និងព្រះរាជអាជ្ញាមានសិទ្ធិអាចប្តឹងទាស់ចំពោះគ្រប់ដីកាសម្រេចរបស់ចៅក្រមស៊ើបសួរបានទាំងអស់ ហើយសិទ្ធិទាំងអស់នេះផ្តល់ដោយក្រមនីតិវិធីព្រហ្មទណ្ឌ។[91]

- **ជនត្រូវចោទ**

ជនត្រូវចោទមិនអាចប្តឹងឧទ្ធរណ៍ចំពោះគ្រប់ដីកាសម្រេចរបស់ចៅក្រមស៊ើបសួរបាន។ ប្រភេទដីកាដែលជនត្រូវចោទអាចប្តឹងឧទ្ធរណ៍បានមានដូចខាងក្រោមៈ

- ដីកាបដិសេធពាក្យសុំអោយធ្វើកិច្ចស៊ើបសួរជាទូទៅនៅពេលដែលជនត្រូវចោទបានស្នើសុំអោយ ចៅក្រមស៊ើបសួរធ្វើការបំពេញកិច្ចនៅចំណុចណាមួយដែលខ្លួនយល់ឃើញថាមានប្រយោជន៍សម្រាប់ខ្លួនតែចៅក្រមស៊ើបសួរមិនបានសម្រេចធ្វើតាមកាស្នើសុំនោះទេ ចៅក្រមត្រូវចេញដីកាបដិសេធដោយសំអាងហេតុក្នុងចិរវេលាមួយខែ បន្ទាប់ពីបានទទួលពាក្យសុំ ហើយត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។[92]

- ដីកាមិនព្រមប្រគល់វត្ថុដែលចាប់យកអោយទៅម្ចាស់ដើម

នៅពេលដែលជនត្រូវចោទ ដាក់ពាក្យសុំអោយចៅក្រមស៊ើបសួរធ្វើការប្រគល់វត្ថុដែលចាប់យកមកអោយខ្លួនវិញតែចៅក្រមស៊ើបសួរមិនបានសម្រចតាមការស្នើសុំរបស់ជនត្រូវចោទទេចៅក្រមស៊ើបសួរត្រូវដីការសម្រេចដោយមានសំអាងហេតុ ហើយត្រូវជូនដំណឹងជាបន្ទាន់ដល់ជនត្រូវចោទ។[93]

- ដីកាបដិសេធពាក្យសុំអោយធ្វើកោសលវិច័យ

ប្រសិនបើជនត្រូវចោទយល់ឃើញ ការធ្វើកោសលវិច័យមានសារៈសំខាន់សំរាប់ខ្លួន នោះជនត្រូវដាក់ពាក្យសុំទៅចៅក្រមស៊ើបសួរ ដើម្បីអោយចៅក្រមស៊ើបសួរធ្វើកោសលវិច័យទៅលើអ្វីមួយដែលជនត្រូវចោទយល់ថាវាមានប្រយោជន៍សំរាប់ខ្លួន។ ប៉ុន្តែ បើចៅក្រមស៊ើបសួរបដិសេធមិនព្រមធ្វើតាមពាក្យសុំ នោះចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចក្នុងរយៈពេល១(មួយ)ខែដែល មានសំអាងហេតុហើយ ត្រូវអោយដំណឹងទៅអ្នកជនត្រូវចោទជាបន្ទាន់។[94]

- ដីកាបដិសេធពាក្យសុំធ្វើកោសលវិច័យបន្ថែម ឬ សុំអោយធ្វើប្រតិកោសលវិច័យ

កាលណាចៅក្រមស៊ើបសួរ ធ្វើកោសលវិច័យរួចហើយ លើសំណុំរឿងណាមួយនោះប៉ុន្តែ ជនត្រូវចោទក្នុងរឿង

[91] មាត្រា២៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[92] មាត្រា១៣៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[93] មាត្រា១៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[94] មាត្រា១៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

នោះយល់ឃើញថាការធ្វើកោសលវិច័យបន្ថែមមានប្រយោជន៍សំរាប់ខ្លួន នោះជនត្រូវចោតត្រូវដាក់ពាក្យសុំទៅចៅ ក្រមស៊ើបសួរ។ ប៉ុន្តែបើចៅក្រមស៊ើបសួរបដិសេធលើពាក្យសុំនោះ ចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចរយៈពេល១(មួយ)ខែ ដែលមានសំអាងហេតុ និងត្រូវជូនដំណឹងទៅជនត្រូវចោទ។[95]

- ដីកាស្តីពីរឿងឃុំខ្លួនបណ្តោះអាសន្ន និងការត្រួតពិនិត្យតាមផ្លូវតុលាការ

នៅពេលដែលចៅក្រមស៊ើបសួរ ធ្វើចំណាត់ការរបស់ខ្លួនដែលទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្ន និងការត្រួតពិនិត្យតាមផ្លូវតុលាការ លើជនត្រូវចោទដោយចេញដីកាសម្រេចដែលអាចអោយជនត្រូវចោទធ្វើការប្តឹងឧទ្ធរណ៍ៈ

- ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន
- ដីកាសម្រេចពន្យារពេលការឃុំខ្លួនបណ្តោះអាសន្ន
- ដីកាសម្រេចមិនព្រមដោះលែងនៅក្រៅឃុំបណ្តោះអាសន្ន
- ដីកាសម្រេចដាក់ជនត្រូវចោទអោយស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ
- ដីកាសម្រេចមិនព្រមកែប្រែ ឬលើកលែងការត្រួតពិនិត្យតាមផ្លូវតុលាការ
- ដីកាសម្រេចរក្សាទុកជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

- **ដើមបណ្តឹងរដ្ឋប្បវេណី**

ដើមបណ្តឹងរដ្ឋប្បវេណី មិនអាចប្តឹងឧទ្ធរណ៍ចំពោះគ្រប់ដីកាសម្រេចរបស់ចៅក្រមស៊ើបសួរបានទេ។[96] ប្រភេទដីកាដែលដើមបណ្តឹងរដ្ឋប្បវេណីអាចប្តឹងឧទ្ធរណ៍បានមានដូចខាងក្រោមៈ

- **ដីកាបដិសេធពាក្យសុំអោយធ្វើកិច្ចស៊ើបសួរ**

ដើមបណ្តឹងរដ្ឋប្បវេណីអាចធ្វើការស្នើសុំ អោយចៅក្រមស៊ើបសួរធ្វើកិច្ចស៊ើបសួរណាមួយ បានដែលមានប្រយោជន៍សំរាប់ខ្លួន។ ប៉ុន្តែបើចៅក្រមស៊ើបសួរ បដិសេធលើពាក្យបណ្តឹងនេះចៅក្រមស៊ើបសួរត្រូវចេញដីកាបដិសេធ ក្នុងរយៈពេល១ខែ ដែលត្រូវមានសំអាងហេតុ។ ហើយត្រូវជូនដំណឹងទៅដើមបណ្តឹងរដ្ឋប្បវេណី។[97]

- **ដីកាមិនព្រមស៊ើបសួរ**

នៅក្នុងពេលដែលមានការតាំងខ្លួន ដើមបណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខចៅក្រមស៊ើបសួរ ហើយចៅក្រមស៊ើបសួរបញ្ជូនរឿងនោះអោយ ព្រះរាជអាជ្ញា ដើម្បីធ្វើការចោទប្រកាន់ដើម្បីចេញ ដីកាសន្និដ្ឋានបញ្ជូនរឿង

[95] មាត្រា១៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[96] មាត្រា២៦៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[97] មាត្រា១៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

អោយចៅក្រមស៊ើបសួរ។ នៅពេលដែលចៅក្រមស៊ើបសួរ បានទទួលដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ ហើយមិនអនុវត្ត ចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចដែលមានសំអាងហេតុ និងធ្វើការជូនដំណឹងជាបន្ទាន់ដល់ដើមបណ្ដឹងរដ្ឋប្បវេណី។[98]

- **ដីកាកំណត់ចំនួនទឹកប្រាក់កក់**

ករណីដែលចៅក្រមស៊ើបសួរបានបើការស៊ើបសួរ ចៅក្រមស៊ើបសួរយល់ឃើញថា មានការលំបាកក្នុងអនុវត្តដែលខ្លួនអាចមើលឃើញជាមុន នោះចៅក្រមស៊ើបសួរនឹងកំណត់តាមដីកាសម្រេច នូវចំនួនទឹកប្រាក់ដែលដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបង់ ព្រមទាំងរយៈពេលដែលត្រូវបង់ ទៃត្រូវផ្អែកលលើជីវភាពជាក់ស្ដែងដែល។

- **ដីកាប្រកាសមិនព្រមទទួលពាក្យបណ្ដឹង ដោយមានការតាំងខ្លួនជាដើម្បីបណ្ដឹងរដ្ឋប្បវេណី**

នៅពេលដែលចៅក្រមស៊ើបសួរ បានកំណត់រយៈពេលអោយដើមបណ្ដឹងរដ្ឋប្បវេណីធ្វើការបង់ប្រាក់តម្កល់ទុកសម្រាប់ធ្វើការស៊ើបសួរ តែដើមបណ្ដឹងរដ្ឋប្បវេណីមិនបានធ្វើការបង់ប្រាក់តាមការកំណត់ទេនោះ ចៅក្រមស៊ើបសួរអាចចេញដីកាសម្រេចមិនព្រមទទួលពាក្យបណ្ដឹង ដោយតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។ ហើយជូនដំណឹងជាបន្ទាន់ទៅដើមបណ្ដឹងរដ្ឋប្បវេណីអំពីការសម្រេចរបស់ខ្លួន។[99]

- **ដីកាផ្ដន្ទាទោសដើមបណ្ដឹងរដ្ឋប្បវេណី**

ក្នុងករណីដែលចៅក្រមស៊ើបសួ រដែលចៅក្រមស៊ើបសួរបើក ស៊ើបសួរតាមការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។ នៅពេលដែលចៅក្រមស៊ើបសួរ ទៅឃើញថានីតិវិធីដោយរំលោភបំពាន និងបានអូសបន្លាយពេលវេលាយូរនោះចៅក្រមស៊ើបសួរអាចចេញដីកាសម្រេចអោយដើមបណ្ដឹងរដ្ឋប្បវេណី បង់ប្រាក់ពិន័យមិនអោយលើសប្រាក់តម្កល់ទេ និងត្រូវជូនដំណឹងបន្ទាន់ដល់ដើមបណ្ដឹងរដ្ឋប្បវេណី។[100]

- **ដីកាមិនព្រមប្រគល់សងវត្ថុដែលចាប់យកអោយទៅម្ចាស់ដើមវិញ**

នៅពេលដែលដើមបណ្ដឹងរដ្ឋប្បវេណី ដាក់ពាក្យសុំអោយចៅក្រមស៊ើបសួរធ្វើការប្រគល់វត្ថុដែលចាប់យកមកអោយខ្លួនវិញ តែចៅក្រមស៊ើបសួរមិនបានសម្រចតាមការស្នើសុំរបស់ដើមបណ្ដឹងរដ្ឋប្បវេណីទេ ចៅក្រមស៊ើបសួរត្រូវដីកាសម្រេចដោយមានសំអាងហេតុ ហើយត្រូវជូនដំណឹងជាបន្ទាន់ដល់ដើម
បណ្ដឹងរដ្ឋប្បវេណី។[101]

---

[98] មាត្រា១៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[99] មាត្រា១៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[100] មាត្រា១៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[101] មាត្រា១៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

- **ដីកាបដិសេធពាក្យសុំអោយធ្វើកោសលវិច័យ**

ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីយល់ឃើញ ការធ្វើកោសលវិច័យមានសារៈសំខាន់សំរាប់ខ្លួន នោះដើមបណ្តឹងរដ្ឋប្បវេណីត្រូវដាក់ពាក្យសុំទៅចៅក្រមស៊ើបសួរ ដើម្បីអោយចៅក្រមស៊ើបសួរធ្វើកោសលវិច័យទៅលើអ្វីមួយដែលដើមបណ្តឹងរដ្ឋប្បវេណីយល់ថាវាមានប្រយោជន៍សំរាប់ខ្លួន។ ប៉ុន្តែ បើចៅក្រមស៊ើបសួរបដិសេធមិនព្រមធ្វើតាមពាក្យសុំ នោះចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចក្នុងរយៈពេល១ (មួយ)ខែដែលមានសំអាងហេតុ ហើយត្រូវអោយដំណឹងទៅដើមបណ្តឹងរដ្ឋប្បវេណីជាបន្ទាន់។[102]

- **ដីកាបដិសេធពាក្យសុំធ្វើកោសលវិច័យបន្ថែម ឬ សុំអោយធ្វើប្រតិកោសលវិច័យ**

កាលណាចៅក្រមស៊ើបសួរធ្វើកោសលវិច័យរួចហើយលើសំណុំរឿងណាមួយនោះ ប៉ុន្តែដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងនោះយល់ឃើញថាការធ្វើកោសលវិច័យបន្ថែមមានប្រយោជន៍សំរាប់ខ្លួន នោះដើមបណ្តឹងរដ្ឋប្បវេណីត្រូវដាក់ពាក្យសុំទៅចៅក្រមស៊ើបសួរ។ ប៉ុន្តែបើចៅក្រមស៊ើបសួរបដិសេធលើពាក្យសុំនោះ ចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចរយៈពេល១(មួយ)ខែ ដែលមានសំអាងហេតុ និងត្រូវជូនដំណឹងទៅដើមបណ្តឹងរដ្ឋប្បវេណី។[103]

- **ដីកាដំណោះស្រាយ**

នៅពេលដែលចៅក្រម បានបិទការស៊ើបសួររបស់ខ្លួន ហើយបញ្ជូនសំណុំរឿងទៅអយ្យការដើម្បីអោយអយ្យការធ្វើដីកាសន្និដ្ឋានស្ថាពរ រួចចៅក្រមស៊ើបសួរធ្វើការចេញដីកាដំណោះស្រាយដើម្បីបញ្ជូនសំណុំរឿងទៅជំនុំជម្រះឬលើកលែងការចោទប្រកាន់ បន្ទាប់មកចៅក្រមស៊ើបសួរត្រូវធ្វើការជូនព័ត៌មានទៅដើម្បីបណ្តឹងរដ្ឋប្បវេណី និងមេធាវីបើមាន។[104]

## គ.រយៈពេលនៃការធ្វើបណ្តឹងឧទ្ធរណ៍ទៅលើសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរ

យើងដឹងអ្នកដែលមានសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរមានដូចខាងលើ ហើយការធ្វើបណ្តឹងឧទ្ធរណ៍ចំពោះបុគ្គលនីមួយៗមានរយៈពេលមិនដូចគ្នាទេ។ នៅពេលដែលមានបណ្តឹងដែលអ្នកប្តឹងដោយអគ្គព្រះរាជអាជ្ញារយៈពេលឧទ្ធរណ៍ចំពោះសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរមុនអង្គសេចក្តីមានរយៈពេល១ខែ។ធ្វើយ៉ាងយូរ គិតពីពេលប្រកាសដីកា។ពាក្យបណ្តឹងដែលធ្វើឡើងដោយព្រះរាជអាជ្ញាដែលប្តឹងទៅលើសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរមានរយៈពេល៥(ប្រាំ)ថ្ងៃ។ ត្រូវធ្វើចាប់ពីពេលជូនដំណឹងអំពីដីកានេះ។ ការដាក់ពាក្យបណ្តឹងរបស់ជនត្រូវចោទ ដើម បណ្តឹងរដ្ឋប្បវេណី និងគ្រប់បុគ្គលនៅក្រៅនិតីវិធី ចំពោះសេចក្តី

[102] មាត្រា១៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[103] មាត្រា១៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[104] មាត្រា២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

សម្រេចរបស់ចៅក្រមស៊ើបសួរមុនអង្គសេចក្ដីមាន រយៈពេល៥(ប្រាំ)ថ្ងៃ។ ត្រូវធ្វើពីពេលដែលមានការជូនដំណឹង ធ្វើឡើងដោយការប្រគល់សេចក្ដីចម្លងនៃដីកាដែលមានចំណារទទួលបាន ការបតឹ្ងត្រូវធ្វើពេលចុះកាលបរិច្ឆេទនៃចំណារនោះ។[105]

**ឃ.ការអនុវត្តពាក្យបណ្ដឹងឧទ្ធរណ៍ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ**

បណ្ដឹងឧទ្ធរណ៍ត្រូវធ្វើតាមការប្រកាសប្ដឹងនៅ ក្រឡាបញ្ជីនៃតុលាការជាន់ដំបូង។ មានន័យថាបុគ្គលដែលច្បាប់កំណត់ថា អាចធ្វើបណ្ដឹងឧទ្ធរណ៍បានត្រូវ ប្រកាសបណ្ដឹងរបស់ខ្លួននៅតុលាការដែលចេញសេចក្ដីសម្រេច។[106] បណ្ដឹងឧទ្ធរណ៍ត្រូវចុះក្នុងបញ្ជីនៃបណ្ដឹងឧទ្ធរណ៍របស់តុលាការ។ ប៉ុន្តែប្រសិនបើអគ្គព្រះរាជអាជ្ញាជាអមសាលាឧទ្ធរណ៍ជាអ្នកធ្វើបណ្ដឹងឧទ្ធរណ៍ ត្រូវធ្វើពាក្យសុំ និងចុះបញ្ជីនៅការិយាល័យក្រឡាបញ្ជីសភាស៊ើបសួរ។

ក្រឡាបញ្ជីនៃសភាស៊ើបសួរត្រូវសុំ អោយក្រឡាបញ្ជីនៃចៅក្រមស៊ើបសួរផ្ញើសំណុំរឿងមក អោយខ្លួន។[107]អ្នកដែលច្បាប់កំណត់អោយធ្វើបណ្ដឹងឧទ្ធរណ៍ ត្រូវបញ្ជូនពាក្យបណ្ដឹងនេះទៅ សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ដែលមានសមត្ថកិច្ចក្នុងការវិនិច្ឆ័យលើពាក្យបណ្ដឹងនេះ។ជនត្រូវចោទ ដើមបណ្ដឹងរដ្ឋប្បវេណី ឬគ្រប់បុគ្គលដែលនៅក្រៅនីតិវិធីត្រូវមានភ្ជាប់ជាមួយលិ ខិតផ្ទេរសិទ្ធិរបស់បុគ្គលមកជាមួយ មេធាវីរបស់ខ្លួនព្រោះនៅពេលដែលមេធាវីធ្វើពាក្យបណ្ដឹងឧទ្ធរណ៍បានទល់តែមានលិខិតផ្ទេរសិទ្ធិមកមេធាវី។ ហើយមេធាវីត្រូវប្រកាសបណ្ដឹងក្រឡាបញ្ជីនៃតុលាការដំបូងនោះ។ ករណីដែលជនត្រូវចោទ ដែលត្រូវបានឃុំខ្លួនបណ្ដឹងឧទ្ធរណ៍ត្រូវធ្វើតាមការប្រកាសប្ដឹងនៅមុខ ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន។ ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនត្រូវប្រគល់លិខិតប្ដឹងមួយច្បាប់ជូនទៅ ក្រឡាបញ្ជីនៃតុលាការជាន់ដំបូង ហើយលិខិតនេះត្រូវចុះនៅក្នុងបញ្ជីនៃបណ្ដឹងឧទ្ធរណ៍។[108]

កាលណាបញ្ជូនពាក្យបណ្ដឹងឧទ្ធរណ៍ ក្រឡាបញ្ជីនៅតុលាការជាន់ដំបូងជូន ដំណឹងភ្លាមទៅដល់ចៅក្រមស៊ើបសួរដែលជាអ្នកចេញដីកា។ ក្រឡាបញ្ជីនៃចៅក្រមស៊ើបសួររូបនោះត្រូវរៀបចំ និងបញ្ជូនសំណុំរឿងទៅសភាស៊ើបសួរដោយមាន សេចក្ដីចម្លងនៃលិខិតប្ដឹងឧទ្ធរណ៍ភ្ជាប់ជាមួយ។ សេចក្ដីចម្លងនេះត្រូវធ្វើឡើងដោយក្រឡាបញ្ជីនៃតុលាការជាន់ដំបូងក្រោយពីបានឃើញនិទ្ទេសដែលមានចុះ ក្នុងបញ្ជីបណ្ដឹងឧទ្ធរណ៍។សំណុំរឿង

105 មាត្រា២៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

106 មាត្រា២៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

107 មាត្រា២៧៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

108 មាត្រា២៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

នេះត្រូវបញ្ជូនទៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ នៅក្នុងរយៈពេល៥(ប្រាំ)ថ្ងៃ បន្ទាប់ពីមានបណ្តឹងឧទ្ធរណ៍ លើកលែងតែកាលៈទេសៈដែលមិនអាចជំនះបាន។ នៅពេលដែលបញ្ជូនចៅក្រមស៊ើបសួរត្រូវរក្សាទុកសំណុំរឿងដើម ហើយក្រឡាបញ្ជីត្រូវចម្លងលិខិតនីមួយៗនៃសំណុំរឿងតាមលទ្ធភាពដែលអាចធ្វើទៅបាន ហើយក្រឡាបញ្ជីត្រូវបញ្ជាក់ថាលិខិតដែលចម្លងត្រឹមត្រូវតាមលិខិតដើម សំណុំរឿងនេះត្រូវបញ្ជូនទៅសភាស៊ើបសួរ។

សេចក្តីសម្រេចរបស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ គឺជាសាលដីកា ដែលមានអនុភាពដល់ការធ្វើបណ្តឹងឧទ្ធរណ៍នៃសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរ។ ហើយសេចក្តីសម្រេចនេះជាសេចក្តីសម្រេចមុនអង្គសេចក្តី។

ក្នុងករណីដែលមានបណ្តឹងឧទ្ធរណ៍ចំពោះដីកាណាមួយក្រៅពីដីកាដំណោះស្រាយចៅក្រមស៊ើបសួរអាចបន្តការស៊ើបសួររបស់ខ្លួនបាន លើកលែងតែមានសេចក្តីសម្រេចផ្ទុយរបស់ប្រធានសភាស៊ើបសួរ។ សេចក្តីសម្រេចនេះគឺបិទផ្លូវតវ៉ា។ ចំណែកឯ ដីកាដំណោះស្រាយដែលមិនអាចធ្វើការស៊ើបសួរបានដោយសារ ដីកាដំណោះស្រាយអាចជាដីកាលើកលែងការចោទប្រកាន់ ឬ ដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ដូច្នេះហើយចៅក្រមស៊ើបសួរមិនអាចបន្តស៊ើបសួរទៅលើសេចក្តីសម្រេចដដែល ដែលនាំខ្លួនអោយខាតបង់ពេលវេលាច្រើន និងធ្វើអោយរាំងស្ទះសំណុំរឿង។កាលណាចៅក្រមស៊ើបសួរសម្រេចដោះលែងអោយជនត្រូវចោទ ដែលជាប់ឃុំបណ្តោះអាសន្នជនត្រូវចោទនោះត្រូវរក្សាទុកក្នុងពន្ធនាគារ រហូតផុតរយៈពេលសម្រាប់បណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា លើកលែងតែព្រះរាជអាជ្ញាយល់ព្រមអោយដោះលែងជនត្រូវចោទនោះភ្លាម។ សេចក្តីសម្រេចជាលាយលក្ខណ៍អក្សររបស់ព្រះរាជអាជ្ញា ត្រូវដាក់បញ្ជូនក្នុងសំនុំរឿងនីតិវីធី។ ដីកាលើកលែងការចោទប្រកាន់ក៏ធ្វើនីតិវីធីដូចគ្នាដែរ កាលណាដីកានេះមានអនុភាពអោយដោះលែងជនត្រូវចោទដែលជាប់ឃុំ។ ចំពោះដីកាដោះលែងអោយនៅក្រៅឃុំ ឬលើកលែងការចោទប្រកាន់ដែលប្តឹងដោយព្រះរាជអាជ្ញា ជនត្រូវចោទដែលជាប់ឃុំ ត្រូវរក្សាទុកក្នុងពន្ធនាគាររហូតទាល់តែសភាស៊ើបសួរសម្រេចពីបណ្តឹងឧទ្ធរណ៍។

# ជំពូកទី៣

# ដំណាក់កាលសវនាការ

## ផ្នែកទី១៖ ការជំនុំជម្រះក្នុងរឿងក្តីព្រហ្មទណ្ឌ

នៅក្នុងរឿងព្រហ្មទណ្ឌនៅពេលដែលទទួលពាក្យបណ្តឹងពីជនរងគ្រោះ ឬ បណ្តឹងបរិហាពីរឿងក្តីព្រហ្មទណ្ឌណាមួយតុលាការត្រូវតែធ្វើចំណាត់ការទៅលើរឿងក្តីនោះជាដាច់ខាត។ ចំណាត់ការដែលត្រូវធ្វើលើរឿងក្តីព្រហ្មទណ្ឌនោះមាន៤ដំណាក់ការដូចជាៈ ដំណាក់ការស៊ើបអង្កេត(ដែលធ្វើដោយមន្ត្រីនគរបាលយុត្តិធម៌) ដំណាក់ការចោទប្រកាន់(ដែលធ្វើឡើងដោយព្រះរាជអាជ្ញា) ដំណាក់កាលស៊ើបសួរ(ដែលធ្វើដោយចៅក្រមស៊ើបសួរ) ហើយដំណាក់ការចុងក្រោយគឺជាដំណាក់ការដែលវិនិច្ឆ័យជនណាម្នាក់អោយទទួលទោស ឬដោះលែងជនម្នាក់ណាបានគឺដំណាក់ការសវនាការ(ដែលធ្វើឡើងដោយចៅក្រមជំនុំជម្រះ)។

### កថាខណ្ឌទី១ ការជំនុំជម្រះមុនចេញសេចក្តីសម្រេចពីតុលាការ

ការជនុំជម្រះមុនចេញសេចក្តីសម្រេចពីតុលាការនេះ មានន័យថាជានីតិវិធីមួយដែលធ្វើមុនពេលដែលចៅក្រមជំនុំជម្រះចេញសេចក្តីសម្រេចរបស់ខ្លួនដែលហៅថា សាលក្រម។

#### ក. រចនាសម្ព័ន្ធរបស់តុលាការ

នៅប្រទេសកម្ពុជាគេបែងចែកតុលាការជាពីរគឺ តុលាការជាន់ទាប និងតុលាការជាន់ខ្ពស់។ តុលាការជាន់ទាបមានដូចជាៈសាលាដំបូងឬតុលាការរាជធានី - ខេត្ត(ដែលមានគ្រប់រាជធានី ខេត្ត) និងតុលាការយោធា(មានតែមួយគត់ ដែលមានទីតាំងស្ថិតនៅរាជធានីភ្នំពេញ)។ តុលាការជាន់ខ្ពស់មានដូចជាៈ សាលាឧទ្ធរណ៍(ដែលពីមុនមានតែមួយនៅរាជធានីភ្នំពេញ និងប៉ុន្តែសព្វថ្ងៃមានឧទ្ធរណ៍តំបន់ចំនួន៣ទៀតគឺ សាលាឧទ្ធរណ៍បាត់ដំបង សាលាឧទ្ធរណ៍ត្បូងឃ្មុំ សាលាឧទ្ធរណ៍ព្រះសីហនុ) និងតុលាការកំពូល(មានទីតាំងតែមួយគត់នៅរាជធានីភ្នំពេញ)។

- សាលាដំបូងរាជធានី ខេត្ត មានប្រធានសាលាដំបូងដែលមានអំណាចឋានានុក្រមផ្នែករដ្ឋបាលដោយលើប្រធានតុលាការជំនាញហើយតុលាការជំនាញនៅសាលាដំបូងមានដូចខាងក្រោមៈ

- តុលាការព្រហ្មទណ្ឌ(មានមន្ទីរស៊ើបសួរជាផ្នែកមួយនៃតុលាការនេះ)
- តុលាការរដ្ឋប្បវេណី
- តុលាការពាណិជ្ជកម្ម

- តុលាការការងារ[109]

នៅក្នុងតុលាការជំនាញនីមួយៗត្រូវមាន ប្រធានតុលាការជំនាញ ចៅក្រម ក្រឡាបញ្ជី និងមន្ត្រីរដ្ឋបាលព្រមទាំងអាចមានមន្ត្រីជំនាញច្បាប់ជាជំនួយការតាមការចាំបាច់។ ការជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌនៅសាលាដំបូងរាជធានី ខេត្ត គឺធ្វើឡើងដោយសមាសភាពចៅក្រមទោល(ចំពោះបទលហុ ឬ បទមជ្ឈិម) និងដោយក្រុមប្រឹក្សាជំនុំជម្រះដែលមានសមាសភាព ៣(បី)រូប(ចំពោះបទឧក្រិដ្ឋ)។ នៅអមសាលាដំបូងរាជធានី ខេត្ត ត្រូវមានអង្គការអយ្យការមួយហៅថា អយ្យការអមសាលាដំបូង។

អយ្យការអមសាលាដំបូងរាជធានី ខេត្ត មាន:

- ព្រះរាជអាជ្ញា
- ព្រះរាជអាជ្ញារង
- ក្រឡាបញ្ជី
- មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀតដែលបម្រើការងារនៅ អយ្យការអមសាលាដំបូង។[110]

▪ សាលាឧទ្ធរណ៍ មានសមាសដូចខាងក្រោម:

- ប្រធាន
- អនុប្រធាន
- ចៅក្រម
- ក្រឡាបញ្ជី
- មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀតដែលបម្រើការងារនៅសាលាឧទ្ធរណ៍។[111]

នៅសាលាឧទ្ធរណ៍មានសភាជំនាញដូចខាងក្រោម:

- សភាព្រហ្មទណ្ឌ
- សភាស៊ើបសួរ
- សភារដ្ឋប្បវេណី

[109] មាត្រា ១៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ

[110] មាត្រា២៩ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ

[111] មាត្រា៣៦ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ

- សភាពាណិជ្ជកម្ម
- សភាការងារ[112]

សភាជំនាញទាំងអស់ត្រូវបានចាត់តាំងដោយ ប្រធានសាលាឧទ្ធរណ៍។ ចំណែកឯសមាសភាពសភាជំនាញទាំងអស់មានដូចខាងក្រោមៈ

- ប្រធានសភា
- ចៅក្រម
- ក្រឡាបញ្ជី[113]

សភានីមួយៗនៃសាលាឧទ្ធរណ៍សម្រេច សេចក្តីដោយ ចៅក្រម៣(បី)រូប ដែលមាន១(មួយ)រូបជា ប្រធានករណីរឿងក្តីដែលតុលាការបង្វិលមកវិញនោះ សាលាឧទ្ធរណ៍ត្រូវជំនុំជម្រះនៅក្នុងសវនាការមួយ ដែលមានចៅក្រម៥(ប្រាំ)រូប ហើយសុទ្ធតែជាចៅក្រមមិនចូលជំនុំជម្រះលើកមុន។ នៅអមសាលាឧទ្ធរណ៍ ត្រូវមានអង្គអយ្យការមួយហៅថា មហាអយ្យការអមសាលាឧទ្ធរណ៍។ មហាអយ្យការអមសាលាឧទ្ធរណ៍មានសមាសភាពដូចខាងក្រោមៈ

- អគ្គព្រះរាជអាជ្ញា
- អគ្គព្រះរាជអាជ្ញារង
- ព្រះរាជអាជ្ញា
- ក្រឡាបញ្ជី
- មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀតដែលបម្រើការងារនៅមហាអយ្យការអមសាលាឧទ្ធរណ៍។[114]

▪ **តុលាការកំពូល មានសមាសដូចខាងក្រោមៈ**

- ប្រធាន
- អនុប្រធាន
- ចៅក្រម
- ក្រឡាបញ្ជី

[112] មាត្រា៣៧ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ

[113] មាត្រា៣៨ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ

[114] មាត្រា៤៩ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ

- មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀតដែល បម្រើការងារនៅតុលាការ កំពូល។

▪ **នៅតុលាការកំពូលមានសភាជំនាញដូចខាងក្រោមៈ**

- សភាព្រហ្មទណ្ឌ
- សភារដ្ឋប្បវេណី
- សភាពាណិជ្ជកម្ម
- សភាការងារ

សភាជំនាញទាំងអស់ត្រូវបានចាត់តាំងដោយ ប្រធានតុលាការកំពូល ហើយចំនួនចៅក្រម ក្រឡាបញ្ជី និងដំណើការរបស់សភាទាំងអស់ក៏ត្រូវកំណត់ដោយប្រធានតុលាការកំពូល។ ចំណែកឯសមាសភាពសភាជំនាញទាំងអស់មានដូចខាងក្រោមៈ

- ប្រធានសភា
- ចៅក្រម
- ក្រឡាបញ្ជី

សភាជំនាញនីមួយៗនៃតុលាការកំពូលសម្រេចសេចក្តីដោយចៅក្រម៥(បី)រូប ដែលមាន១(មួយ)រូបជាប្រធាន។ ករណីបើសភារួមក្រុមត្រូវបង្កើតអោយមានឡើង សភានេះត្រូវមានសមាសភាពចៅក្រមយ៉ាងតិច៩(ប្រាំបួន)រូប ដែលបែងចែងស្មើគ្នារវាងចៅក្រមជាតំណាងនៃសភាពាក់ពន្ធ។ សភារួមក្រុមត្រូវស្ថិតក្រោមអធិបតីភាពរបស់ប្រធានតុលាការ។

នៅអមតុលាការកំពូល ត្រូវមានអង្គអយ្យការមួយហៅថា មហាអយ្យការអមតុលាការកំពូល។ មហាអយ្យការអមតុលាការកំពូលមានសមាសភាពដូចខាងក្រោមៈ

- អគ្គព្រះរាជអាជ្ញា
- អគ្គព្រះរាជអាជ្ញារង
- ព្រះរាជអាជ្ញា
- ក្រឡាបញ្ជី
- មន្ត្រីរដ្ឋបាលនិងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀតដែលបម្រើការងារ នៅមហាអយ្យការអមតុលាការកំពូល។

### ខ. សមត្ថកិច្ចរបស់សាលាដំបូង

ចំពោះរឿងក្តីព្រហ្មទណ្ឌ ការជំនុំជំជម្រះអាចធ្វើទៅបានលុះត្រាតែមានការបញ្ជូន សំណុំរឿងជូន

យុត្តាធិការ

ជំនុំជម្រះ

តាមរយៈរបៀបប្តឹងមកតុលាការ។ ជំហានដំបូង ប្រធានសាលាដំបូងគប្បីពិនិត្យមើល អំពីសមត្ថកិច្ចរបស់សាលាដំបូងជាមុនសិន ថាតើចំពោះសំនុំរឿងដែលខ្លួនត្រូវបន្តចំណាត់ការនោះស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដែរឬទេ?

សាលាដំបូងរាជធានី ខេត្តមានសមត្ថកិច្ចជំនុំជំម្រះទៅលើរឿងក្តីដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន លើកលែងតែរឿងក្តីទាំងឡាយណាដែល ច្បាប់ប្រគល់ទៅសាលាជម្រះក្តីផ្សេងទៀត។ តុលាការដែលមានសមត្ថកិច្ចក្នុងការជំនុំជម្រះក្នុងរឿងក្តីព្រហ្មទណ្ឌគឺ តុលាការនាទីកន្លែងបទល្មើស តុលាការនាលំនៅឋានរបស់ជនជាប់ចោទ ឬតុលាការនាទីកន្លែងចាប់ខ្លួនជនជាប់ចោទ។ ក្នុងករណីដែលមានតុលាការពីរ ឬច្រើនស្ថិតក្នុងមណ្ឌលនៃសាលាឧទ្ធរណ៍តែមួយបានទទួលពាក្យបណ្តឹងលើរឿងតែមួយដូចគ្នា ប្រធានសាលាឧទ្ធរណ៍ចាត់តាំងតុលាការដែលនឹងត្រូវទទួលបន្ទុកលើសំណុំរឿង។ វិវាទសមត្ថកិច្ចដែនដីរវាងតុលាការច្រើនដែលមានថ្នាក់ស្មើគ្នាត្រូវសម្រេចដោយប្រធានតុលាការកំពូល ការសម្រេចនេះបិទផ្លូវតវ៉ា។

**គ.ការទទួលពាក្យបណ្តឹងរបស់តុលាការ**

នៅក្នុងរឿងព្រហ្មទណ្ឌតុលាការអាចជំនុំជម្រះតែ លើពាក្យបណ្តឹងដែលប្តឹង មកខ្លួនប៉ុណ្ណោះ។ បណ្តឹងដែលប្តឹងមកតុលាការមានដូចខាងក្រោមៈ

- ដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬ សាលដីកាបញ្ជូនរបស់សភាស៊ើបសួរ
- ដីកាបញ្ជូនទៅតុលាការជំនុំជម្រះដោយផ្ទាល់របស់ព្រះរាជអាជ្ញា
- កំណត់ស្តីពីការចូលបង្ហាញខ្លួនភ្លាមដែលធ្វើដោយព្រះរាជអាជ្ញា

នៅពេលដែលបញ្ជូនបណ្តឹងមក តុលាការត្រូវធ្វើចំណាត់ការភ្លាមទៅលើបណ្តឹងទាំងនេះ។ ហើយចំណាត់ការនេះត្រូវធ្វើតែទៅលើប្រភេទបណ្តឹងដែលគេបញ្ជូនមកតែប៉ុណ្ណោះ។

**ឃ. ការកោះហៅភាគីពាក់ព័ន្ធអោយចូលសវនាការ**

បន្ទាប់ពីតុលាការបានទទួលសំណុំរឿង ដោយយោងតាមនីតិវិធីនៃការប្តឹងទៅតុលាការ ប្រធានតុលាការត្រូវកំណត់ពីកាលបរិច្ឆេទនៃសវនាការ លើកលែងតែករណីនៃនីតិវិធីចូលបង្ហាញខ្លួនភ្លាម ដោយបើកសវនាការដើម្បីកំណត់ពីកាលបរិច្ឆេទនេះ។ នៅក្នុងករណីដែលតុលាការបានទទួលបណ្តឹងទទួលស្គាល់បណ្តឹងដោយការបញ្ជូនទៅជំនុំជម្រះផ្ទាល់ដោយដីការបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬសាលដីការបញ្ជូនរបស់សភាស៊ើបសួរ ប្រធានតុលាការត្រូវត្រូវតែគិតគូរតាមរយៈពេលដែលមានចែងក្នុងមាត្រា៤៥៧ (រយៈពេលដែលត្រូវគោរពរវាងការប្រគល់ដីការកោះហៅ បញ្ជូនទៅជំនុំជម្រះផ្ទាល់ និងការបង្គាប់ឲ្យចូលបង្ហាញខ្លួន) និងមាត្រា ៤៦៦ (រយៈពេលដែល

ត្រូវគោរពរវាងដីការកោះហៅ និងការបង្គាប់ឲ្យចូលបង្ហាញខ្លួន) នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ ដើម្បីកំណត់កាលបរិច្ឆេទនេះត្រូវជូនដំណឹងដោយផ្ទាល់មាត់ដល់ព្រះរាជអាជ្ញា។[115]ការហៅរបស់ភាគីណាម្នាក់ដែលពាក់ពន្ធ័ក្នុងសំណុំរឿង ហើយភាគីក្នុងសំណុំរឿងព្រហ្មទណ្ឌអាចមានដូចខាងក្រោមៈ

- ជនជាប់ចោទ(អាចជា នីតិជន ឬ អនីតិជន)
- ដើមបណ្តឹងរដ្ឋប្បវេណី
- សាក្សី
- អ្នកបកប្រែ
- អ្នកទទួលខុសត្រូវរដ្ឋប្បវេណី
- អ្នកជំនាញ(គ្រូពេទ្យ អ្នកចិត្តវិទ្យា)។

ដីកាកោះហៅជនជាប់ចោទត្រូវធ្វើដោយ ព្រះរាជអាជ្ញា ឬ អាជ្ញាសាលា ការបញ្ជូនដីកាកោះហៅនេនេះត្រូវបញ្ជូនអោយដល់ផ្ទាល់ដៃជនជាប់ចោទដោយប្រើគ្រប់មធ្យោបាយទាំងអស់ ប៉ុន្តែបើអវត្តមានជនជាប់ចោទ ឬ អ្នកដែលមានវត្តមានក្នុងលំនៅឋានរបស់ជនជាប់ចោទមិនព្រមទទួលដីកាកោះហៅនេះ អាជ្ញាសាលាត្រូវប្រគល់ដីកានេះទៅមេឃុំ ឬ ចៅសង្កាត់។ហើយការប្រគល់ដីកាកោះហៅនីមួយត្រូវប្រគល់តែចុងដីកាតែប៉ុណ្ណោះ។

ដីកាកោះហៅបុគ្គលដែលពាក់ព័ន្ធមួយចំនួនដែលក្រៅពីជនជាប់ចោទធ្វើឡើងដោយ ព្រះរាជអាជ្ញា អាជ្ញាសាលា មេឃុំ ឬ ចៅសង្កាត់ ឬ ជំទប់ ឬ ចៅសង្កាត់រង ក្រឡាបញ្ជី ឬតាមផ្លូវរដ្ឋបាល។ ចំណែករយៈពេលដែលត្រូវគោរពសម្រាប់ការកោះហៅភាគីក្រៅពីជនជាប់ចោទអោយចូលសវនាការ ក្រមនីតិវិធីមិនបានកំណត់នោះទេ។ ករណីនេះព្រះរាជអាជ្ញាត្រូវកំណត់រយៈពេលអោយបានសមរម្យសម្រាប់បុគ្គលដែលពាក់ព័ន្ធ ដើម្បីអោយភាគីទាំងអស់នោះត្រៀមខ្លួនក្នុងចូលសវនាការតាមការកោះហៅ។

## កថាខណ្ឌទី២ កិច្ចនីតិវិធីនៃការជំនុំជម្រះ

### ក. មុនពេលប្រកាសបើកសវនាការ

ជាទូទៅទិដ្ឋភាពក្នុងដំណើរការជំនុំជម្រះនៅសាលាដំបូងយើងសង្កេតឃើញមានចៅក្រម១រូបចំពោះបទមជ្ឈិម និងបទលហុ ឬចៅក្រម៣រូប ចំពោះបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ តំណាងអយ្យការ១រូប ក្រឡាបញ្ជី១(មួយ)រូប មេធាវីការពារជនជាប់ចោទ១(មួយ)រូប មេធាវីដើមបណ្តឹង១រូប ជនរងគ្រោះ ជនជាប់ចោទ សាក្សី អ្នកបកប្រែ(ករណីជនរងគ្រោះ ឬ ជនជាប់ចោទជាជនជាតិបរទេស) និងមន្រ្តីនគរបាលយុត្តិធម៌អមជនជាប់ចោទ។

នៅមុនពេលបើកសវនាការ ជាសាធារណៈចៅក្រមមានភារៈកិច្ច ក្នុងការរៀបចំសំណុំរឿងសម្រាប់បើក

[115] មាត្រា២៩២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

សវនាការដែលជាទូទៅ ក្នុងពេលសវនាការម្តងចៅក្រមជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌចាប់ពីបីសំណុំរឿងឡើងទាំងព្រមទាំងកំណត់ពីកាលបរិច្ឆេទសវនាការ និងកំណត់ពីសាលដែលត្រូវជំនុំជម្រះ។ ចៅក្រមត្រូវធ្វើលិខិតស្នើមកព្រះរាជអាជ្ញាដើម្បីចាត់តាំងតំណាងអយ្យការក្នុងការចូលរួមជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌ។

នៅមុនពេលចាប់ផ្តើមសវនាការក្រឡាបញ្ជីមានភារៈកិច្ចៈ

- រៀបចំបន្ទប់សវនាការដោយពិនិត្យមើលពីសណ្តាប់ធ្នាប់ក្នុងបន្ទប់សវនាការ
- រៀបចំឯកសារទាំងអស់ដែលពាក់ពន្ធ័នឹងការជំនុំជម្រះរបស់ចៅក្រម
- ត្រូវធ្វើការផ្ទៀងផ្ទាត់បញ្ជីឈ្មោះជនជាប់ចោទដែលពន្ធនាគារបញ្ជូលមក
- ក្រឡាបញ្ជីធ្វើការអានពីបទបញ្ជារផ្ទៃក្នុងរបស់សវនាការដល់សាធារណជនស្តាប់

**ខ. ការប្រកាសបើកសវនាការ**

សវនាការលើរឿងក្តីព្រហ្មទណ្ឌធ្វើឡើងជាសាធារណៈដោយបើកការអនុញ្ញាតអោយប្រជាពលរដ្ឋចូលស្តាប់ឬជ្រាបច្បាស់អំពីចំណាត់ការរបស់តុលាការ។

ក្រឡាបញ្ជី ជាដឹកនាំនីតិវិធីនៅមុនពេលបើកសវនាការដោយត្រូវអានបទបញ្ជាផ្ទៃក្នុងយ៉ាងតិច ២(ពីរ) ទៅ(បី)ដង និងប្រាប់ទៅដល់ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី សាក្សី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជាអាទិ៍អោយក្រោកឈរឡើងនឹង រក្សាភាពស្ងៀមស្ងាត់នៅពេលដែល មានវត្តមានចៅក្រមជំនុំជម្រះចូលមកដល់ក្នុងសវនាការ។

**គ.កិច្ចពិភាក្សាដេញដោលក្នុងសវនាការ**

នៅក្នុងពេលចាប់ផ្តើមសវនាការគឺក្រឡាបញ្ជីធ្វើការអញ្ជើញចៅក្រម ឬ ក្រុមប្រឹក្សាជំនុំជម្រះចូលក្នុងបន្ទប់សវនាការ។ នៅពេលចៅក្រម ឬ ក្រុមប្រឹក្សាចូលមកដល់សវនាការសាធារណជនដែលបានចូលរួមទាំងអស់ត្រូវតែងើបឈរឡើងជា សញ្ញាគោរពអង្គតុលាការ បន្ទាប់មកចៅក្រមជំនុំជម្រះ ឬ ក្រុមប្រឹក្សាជំនុំជម្រះ នឹងអនុញ្ញាតឲ្យអង្គុយដើម្បីសម្រួលឥរិយាបថ។ ក្រឡាបញ្ជីមានរយៈពេល៥នាទីក្នុងការប្រ កាសនូវវត្តមានរបស់ភាគីទាំងអស់ដូចជាមេធាវីការពារជនជាប់ចោទ មេធាវីការពារជនរងគ្រោះ ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ និងសាក្សី។ សាធារណជនដែលចូលរួមស្តាប់សវនាការទាំងអស់ជានីតិជន។

ជាគោលការណ៍នៅពេលដែលចៅក្រមជំនុំជម្រះ ឬ ក្រុមប្រឹក្សាជំនុំជម្រះធ្វើការប្រកាសបើកសវនាការដោយមានការរៀបរាប់ដូចជាៈ

- តាងនាមប្រជារាស្ត្រខ្មែរ
- ប្រកាសពីលេខសំណុំរឿង និងកាលបរិច្ឆេទ
- ឈ្មោះជនជាប់ចោទនៅក្នុងសំណុំរឿង

- កាលបរិច្ឆេទនៃថ្ងៃប្រព្រឹត្តបទល្មើស
- កាលបរិច្ឆេទនៃថ្ងៃចាប់ខ្លួន
- ទីកន្លែងដែលជនជាប់ចោទបានប្រព្រឹត្តបទល្មើស
- បទល្មើសដែលចោទប្រកាន់ជនជាប់ចោទ

ក្រោយពីចៅក្រមជំនុំជម្រះ ឬក្រុមប្រឹក្សាជំនុំជម្រះប្រកាសបើកសវនាការរួច ចៅក្រមជំនុំជម្រះ ឬ ក្រុមប្រឹក្សាជំនុំជម្រះចាប់ផ្ដើមបើកការពិភាក្សាដេញដោលដោយធ្វើការកោះហៅជនជាប់ចោទ ដើមបណ្ដឹងរដ្ឋប្បវេណី និងសាក្សីឲ្យចូលសវនាការដើម្បីសួរចម្លើយ និងស្ដាប់ចម្លើយ។

**គ.១ការសួរចម្លើយជនជាប់ចោទ**

នៅមុនពេលដែលជនជាប់ចោទបានចូលសវនាការតាមរយៈដីកាកោះហៅ គឺជនជាប់ចោទត្រូវធ្វើសម្បថតាមប្រពៃណីសាសនាដោយមានដោយ មានអមដោយមន្ត្រីនគរបាល។ ពេលដែលជនជាប់ចោទបានចូលមកដល់សវនាការរួចរាល់ហើយ ចៅក្រមប្រកាសពីសិទ្ធិរបស់ជនជាប់ចោទមានក្នុងពេលសវនាការព្រមទាំងសិទ្ធិមានមេធាវីការពារខ្លួនផងដែរ។ ចៅក្រមសួរបញ្ជាក់អំពីអត្តសញ្ញាណជនជាប់ចោទនូវឈ្មោះ ឈ្មោះហៅក្រៅ អាយុ ទីកន្លែងកំណើត លំនៅឋាន មុខរបរ ឈ្មោះសហពទ្ធ័ ចំនួនកូន ឈ្មោះឪពុកម្ដាយ បទល្មើសដែលធ្លាប់បានប្រព្រឹត្តពីមុន។ ចៅក្រមសួរទៅតំណាងអយ្យការថាតើមានការផ្លាស់ប្ដូរបទចោទប្រកាន់ដែរឬទេ? បើគ្មានការផ្លាសប្ដូរទេចៅក្រមសុំឲ្យតំណាងអយ្យការអានបទចោទប្រកាន់។ ក្រោយពីចៅក្រមស្ដាប់បទចោទប្រកាន់របស់តំណាងអយ្យការ ចៅក្រមជំនុំជម្រះចោទសួរទៅជនជាប់ចោទថា តើជនជាប់ចោទពិតជាបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់របស់តំណាងអយ្យការមែនដែរឬទេ? ជនជាប់ចោទអាចឆ្លើយទទួលស្គាល់ការចោទប្រកាន់ ឬមិនព្រមទទួលស្គាល់បទចោទប្រកាន់។ បើជនជាប់ចោទឆ្លើយទទួលស្គាល់នោះចៅក្រមបញ្ជារឲ្យជនជាប់ចោទនិយាយរៀបរាប់ពីដំណើរដើមទងទាំងអស់នៃ ការប្រព្រឹត្តបទល្មើស។ ប៉ុន្តែប្រសិនបើជនជាប់ចោទឆ្លើយមិនព្រមទទួលស្គាល់ការចោទប្រកាន់ទេ ចៅក្រមជំនុំជម្រះស្នើសុំឲ្យក្រឡាបញ្ជីអានពី របាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ឲ្យលឺៗ ដើម្បីជាភស្តុតាងដាក់បន្ទុកទៅលើជនជាប់ចោទដែលឆ្លើយបដិសេធមិនព្រមទទួលយកការចោទប្រកាន់។ បន្ទាប់ពីស្ដាប់របាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ដែល អានដោយក្រឡាបញ្ជី ចៅក្រមនឹងសួរគ្រប់សំណួរទាំងអស់ទាំងសំណួរដាក់បន្ទុកនិងសំណួរដោះបន្ទុកទៅជនជាប់ចោទដែលចៅក្រមយល់ឃើញថាមានប្រយោជន៍ដល់ការសម្ដែងឲ្យឃើញការពិត។ បន្ទាប់ពីចៅក្រមជំនុំជម្រះធ្វើការសួរចម្លើយជនជាប់ចោទរួចចៅក្រមអនុញ្ញាតឲ្យតំណាងអយ្យការ មេធាវីការពារជនរងគ្រោះ និងភាគីអាចលើកជាសំណួរសួរដល់ជនជាប់ចោទ។ រាល់សំណួរដែលចៅក្រមលើកឡើងទោះបីជាបានសាកសួរម្ដងរួចហើយក្ដីក៏

តំណាងអយ្យការ មេធាវីការពារជនជាប់ចោទ ឬភាគី គ្មានសិទ្ធិកាត់សំណួររបស់ចៅក្រមបានដែរ។ ប៉ុន្តែចៅក្រមមានសិទ្ធិក្នុងការកាត់សំណួរដែលចោទសួរដោយតំណាងអយ្យការ ឬ មេធាវី ឬ ភាគីចំពោះរាល់សំណួរណាដែលពុំមានប្រយោជន៍ក្នុងរឿងក្តី ឬរំលោភលើសិទ្ធិរបស់ជនជាប់ចោទហួសហេតុពេក។ ជនជាប់ចោទដែលជានីតិជនតុលាការធ្វើការជំនុំជម្រះជាសាធារណៈ លើកលែងតែជនជាប់ចោទជាអនីតិជនតុលាការសម្រេចធ្វើការជំនុំជម្រះជា អសាធារណៈ។ ក្នុងសវនាការ អសាធារណៈបុគ្គលដែលតុលាការអនុញ្ញាឲ្យចូលរួមស្តាប់បានលុះត្រាតែជននោះជា៖

- ភ្នាក់ងារមានសង្គមកិច្ច
- សាច់ញាតិរបស់ជនជាប់ចោទ
- សាច់ញាតិរបស់ជនរងគ្រោះ
- ដើមបណ្តឹងរដ្ឋប្បវេណី
- ជនរងគ្រោះ
- សាក្សី

**គ.២ ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ និង សាក្សី**

មុនពេលដែលចៅក្រមស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ និងសាក្សីចៅក្រមជំនុំជម្រះសួរបញ្ជាក់អំពីអត្តសញ្ញាណដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ និងសាក្សី នូវឈ្មោះ ឈ្មោះហៅក្រៅ អាយុ និងទីកន្លែងកំណើត លំនៅឋាន មុខរបរ ឈ្មោះសហពទ្ធ័ ចំនួនកូន ឈ្មោះឳពុកម្តាយ បទល្មើសដែលធ្លាប់បានប្រព្រឹត្តពីមុនដូចគ្នា នឹងជនជាប់ចោទដែរ។ ចៅក្រមជំនុំជម្រះស្តាប់ចម្លើយរបស់ ដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ និងសាក្សីតាមលំដាប់លំដោយដែលខ្លួនយល់ថាមានប្រយោជន៍។ ចៅក្រមជំនុំជម្រះក៏អាចសួរដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ និងសាក្សីគ្រប់សំណួរដើម្បីបង្ហាញឲ្យឃើញការពិត។ បន្ទាប់ពីចៅក្រមជំនុំជម្រះបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ និងសាក្សីរួចចៅក្រមជំនុំជម្រះអនុញ្ញាតឲ្យតំណាងអយ្យការ និងភាគីអាចលើកជាសំណួរសួរដល់ដើម បណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ និងសាក្សី។

ក្នុងករណីដែលជនរងគ្រោះជាអនីតិជនក៏តុលាការធ្វើការជំនុំជម្រះជាអសាធារណៈដូចជនជាប់ចោទជាអនីតិជនដែរ ហើយបុគ្គលដែលតុលាការអនុញ្ញាតឲ្យចូលរួមស្តាប់បានលុះត្រាតែជា៖

- ភ្នាក់ងារសង្គមកិច្ច
- សាច់ញាតិរបស់ជនជាប់ចោទ
- សាច់ញាតិរបស់ជនរងគ្រោះ

- ដើមបណ្តឹងរដ្ឋប្បវេណី
- ជនរងគ្រោះ
- សាក្សី

ក្នុងការសាកសួរដើម្បីស្តាប់ចម្លើយជនរងគ្រោះជាអនីតិជន គឺតុលាការបង្កើតឲ្យមានការសាកសួរជាលក្ខណៈកុមារមេត្រីដោយអោយអនីតិជននៅក្នុង បន្ទប់មួយក្រៅពីបន្ទប់សវនាការដើម្បីលួងលោម ឬលើកទឹកចិត្តអនីតិជនកុំឲ្យមានការភ័យខ្លាចក្នុងការចូលរួមសវនាការ។នៅក្នុងបន្ទប់នោះមានបំពាក់ឧបករណ៍ស្រូបសំលេង ឬកាមេរ៉ាដែលអាចឲ្យតុលាការសាកសួរ ឬស្តាប់ចម្លើយក៏ដូចជាបានឃើញពីសកម្មភាពរបស់កុមារផងដែរ។ ការសម្រេចឲ្យកុមារនៅក្នុងបន្ទប់មួយក្រៅពីបន្ទប់សវនាការនេះគឺដើម្បីជៀសវាងកុំឲ្យកុមារមានការភ័យខ្លាចតក់ស្លុតនៅពេលបានឃើញជនជាប់ចោទផ្ទាល់។

**បញ្ជាក់៖**នីតិវិធីកុមារមេត្រី សំដៅដល់ដំណើរការ និងនីតិវិធីដែលពាក់ពន្ធ័នឹងការលើកទឹកចិត្តឲ្យអនីតិជនចូលរួមក្នុងរឿងក្តី តាមរយៈការប្រើប្រាស់ភាសានិងអាកប្បកិរិយាក្នុងកម្រិតដែលអនីតិជនអាចយល់បាន និងក្នុងបរិយាកាសដែលផ្តល់ឲ្យអនីតិជននូវសុវត្តិភាព សន្តិសុខ សិទ្ធិ និងតម្រូវការជាមូលដ្ឋាន។

ភ្នាក់ងារសង្គមកិច្ច សំដៅដល់មន្ត្រីក្រសួង មន្ទីរ ការិយាល័យទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬបុគ្គលផ្សេងទៀតដែលទទួលបានការបណ្តុះបណ្តាលជំនាញ ផ្នែកកុមារនិងច្បាប់ពាក់ពន្ធ័នឹងអនីតិជន ហើយត្រូវទទួលបានការតែងតាំង ឬទទួលស្គាល់ពីរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច។

### គ.៣ កំណត់ហេតុក្នុងពេលសវនាការ

នៅក្នុងកំឡុងពេលសវនាការក្រឡាបញ្ជីសរសេរកំណត់ហេតុ សវនាការដែលមានគោលដៅ ផ្តល់មធ្យោបាយដល់ សាលាឧទ្ធរណ៍ធ្វើការត្រួតពិនិត្យនីត្យានុកូលភាពនៃនីតិវិធី និងបានយល់ដឹងអំពីការពិភាក្សាដេញដោល។ ក្រឡាបញ្ជីត្រូវខិតខំរៀបរាប់ដោយយកចិត្តទុកដាក់អំពីការប្រព្រឹត្តទៅនៃសវនាការ នឹងកត់ត្រាឲ្យបានត្រឹមត្រូវតាមសំណួរដែលសួរព្រមទាំងចម្លើយរបស់ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ សាក្សីនិងអ្នកជំនាញ។ កំណត់ហេតុសវនាការត្រូវចុះត្រូវចុះហត្ថលេខាដោយក្រឡាបញ្ជី និងចុះទិដ្ឋការក្រោយពីការផ្ទៀងផ្ទាត់ដោយប្រធានសវនាការក្នុងរយៈពេល១០ថ្ងៃ ក្រោយថ្ងៃប្រកាសសាលក្រម។

- **ពេលបញ្ចប់សវនាការ**

បន្ទាប់ពីកិច្ចពិភាក្សាដេញដោល ប្រធានសវនាការបើកឲ្យភាគីទាំងអស់ធ្វើសេចក្តីថ្លែងការណ៍ដូចតទៅ៖

- ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណីជនជាប់ចោទដើម្បីធ្វើការកត់សម្គាល់ខ្លីៗ
- មេធាវីរបស់រដ្ឋប្បវេណីធ្វើសេចក្តីសន្និដ្ឋានការពារ

- តំណាងអយ្យការធ្វើសេចក្ដីសន្និដ្ឋានស្នើសុំឲ្យតុលាការផ្ដន្ទាទោសជនជាប់ចោទ
- មេធាវីរបស់ជនជាប់ចោទធ្វើសេចក្ដីសន្និដ្ឋានការពារ។[116]

នៅក្នុងដំណាក់កាលនេះ ជនជាប់ចោទ ដើមបណ្ដឹងរដ្ឋប្បវេណី ជនរងគ្រោះ ឬ មេធាវីតំណាងដោយអាណត្តិរបស់ភាគីទាំងសងខាង អាចធ្វើសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ និងបង្ហាញភស្តុតាង ឬលិខិតស្នាមផ្សេង ៗដែលមានប្រយោជន៍សំរាបសម្ដែងឲ្យឃើញការពិត។

សេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរត្រូចុះទិដ្ឋការដោយប្រធានសវនាការ និងក្រឡាបញ្ជីហើយភ្ជាប់ទៅក្នុងសំណុំរឿង។[117]

ក្រោយពិបិទកិច្ចពិភាក្សាដេញដោល ចៅក្រមជនុំជម្រះ ឬក្រុមប្រឹក្សាជំនុំជម្រះនឹងថយខ្លួនចូលទៅក្នុងបន្ទប់ពិភាក្សាប្រមាណ ១៥ ទៅ ៣០នាទីដើម្បីធ្វើការពិភាក្សាសម្រេច។ ដំណាក់កាលនេះបណ្ដឹងស្នើសុំ ឬការបង្ហាញភស្តុតាងបន្ថែមមិនអាចដាក់ជូនតុលាការបានទៀតទេ។ តំណាងអយ្យការនឹងក្រឡាបញ្ជីមិនត្រូវបានអនុញ្ញាតឲ្យចូលក្នុងការពិភាក្សាសម្រេចឡើយ។ចំណែកសាធារណជនទាំងអស់ត្រូវនៅក្នុងបន្ទប់សវនាការដដែល ដើម្បីរង់ចាំស្ដាប់ការប្រកាសសាលក្រមរបស់តុលាការ។

ការប្រកាសសាលក្រមត្រូវប្រកាសជា សាធារណៈនៅថ្ងៃដែលពិភាក្សាដេញដោល ឬនៅក្រោយពេលសវនាការ។នៅក្នុងសេចក្ដីសម្រេចរបស់តុលាការមានបញ្ជាក់ពីការកំណត់ នូវពិរុទ្ធភាពព្រមទាំងប្រកាសអំពីទោសដែលត្រូវបានកំណត់ដោយច្បាប់។ ក្នុងករណីដែលតុលាការយល់ឃើញថាមិនមែនជាបទល្មើស ឬជនជាប់ចោទមិនមាននូវពិរុទ្ធភាពតុលាការអាច ប្រកាសសាលក្រមដោយសម្រេចឲ្យជនជាប់ចោទរួចផុតពីការចោទប្រកាន់។

ប្រសិនបើតុលាការសម្រេចថា មានទោសដោយត្រូវដាក់ពន្ធនាគារនោះតុលាការអាច ចេញដីកាបង្គាប់ឲ្យឃុំខ្លួន បើជនជាប់ចោទមានវត្តមាននៅក្នុងសវនាការ ឬចេញដីកាបង្គាប់ឲ្យចាប់ខ្លួនប្រសិនបើជនជាប់ចោទអវត្តមាននៅក្នុងពេលសវនាការ។

- **ការតាក់តែងសាលក្រម**

នៅគ្រប់សាលក្រមទាំងអស់ការតាក់តែងតម្រូវជាដាច់ខាតមានពីរផ្នែកគឺ៖

- ផ្នែកសំអាងហេតុពោលគឺទឡ្ហីករណ៍នៃអង្គហេតុនិងអង្គច្បាប់ដែលនាំឲ្យតុលាការចេញសេចក្ដីសម្រេច។
- ផ្នែកសម្រេចពោលគឺសេចក្ដីសម្រេចរបស់តុលាការ។

អង្គហេតុត្រូវតែច្បាស់លាស់ និងគ្មានការសង្ស័យ។ តុលាការត្រូវត្រួតពិនិត្យបទចោទនីមួយៗ និងទឡ្ហីករណ៍

[116] មាត្រា៣៣៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

[117] មាត្រា៣៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

ដែលបានលើកឡើងនៅ ពេលសវនាការ។នៅក្នុងសំអាងហេតុតុលាការ ត្រូវឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់គូភាគី។ ផ្នែកសេចក្តីសម្រេចត្រូវចុះនិទ្ទេសអំពីបទល្មើសដែលជនជាប់ចោទបានប្រព្រឹត្តខុសអត្ថបទច្បាប់ដែលបានអនុវត្តទោស និងទណ្ឌកម្មរដ្ឋប្បវេណី។ និទ្ទេសដែលត្រូវចុះលើសាលក្រមះ

- កាលបរិច្ឆេទនៃសវនាការ
- កាលបរិច្ឆេទនៃការប្រកាសសាលក្រម
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលជំនុំជម្រះ
- ឈ្មោះ និងឋានៈរបស់តំណាងអយ្យការ
- ឈ្មោះ និងឋានៈរបស់ក្រឡាបញ្ជី
- ឈ្មោះ ទីលំនៅ កាលបរិច្ឆេទ និងទីកន្លែងកំណើត មុខរបររបស់ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី
- ឈ្មោះរបស់មេធាវី
- ហត្ថលេខា និងត្រារបស់ចៅក្រម និងក្រឡាបញ្ជី

សាលក្រមត្រូវចុះហត្ថលេខាដោយប្រធាន និងក្រឡាបញ្ជី។ក្រោយពីបានចុះហត្ថលេខា ដោយប្រធាន និងក្រឡាបញ្ជីរួចសាលក្រមដើមត្រូវតំកល់ទុកនៅការិយាល័យក្រឡាបញ្ជីយ៉ាងយូរបំផុត៨ថ្ងៃក្រោយការប្រកាសសាលក្រម។ ការិយាល័យក្រឡាបញ្ជីត្រូវរក្សាទុកសាលក្រមដើមជានិច្ច។ ក្រឡាបញ្ជីអាចផ្តល់ច្បាប់ចម្លងនៃសាលក្រមជាអាទិ៍ ក្នុងករណីមានបណ្តឹងឧទ្ធរណ៍។[118]

- **ការប្រកាសសាលក្រម**

បន្ទាប់ពីធ្វើការពិភាក្សាសម្រេចរបស់តុលាការ យល់ឃើញថាមានភស្តុតាងគ្រប់គ្រាន់ មានពិរុទ្ធភាពអាចដាក់បន្ទុប់បានទៅលើជនជាប់ចោទហើយ នោះចៅក្រមជំនុំជម្រះចេញមក ប្រកាសសាលក្រមភ្លាមៗជាសាធារណៈ។ គ្រប់សាលក្រមត្រូវតែប្រកាសនៅពេលសវនាការសាធារណៈ។ ផ្នែកនៃសេចក្តីសម្រេចត្រូវអានដោយសម្លេងខ្លាំងៗដោយប្រធានសវនាការ។[119]ការប្រកាសសាលក្រមរបស់ តុលាការជាទូទៅគឺះ

- តាងនាមប្រជារាស្ត្រខ្មែរ
- ខ្លឹមសារនៃសេចក្តីសម្រេច

[118] មាត្រា៣៥៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[119] មាត្រា៣៥៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

- តុលាការសម្រេចប្រកាសសាលក្រមជាសាធារណៈចំពោះមុខគូភាគី ឬកំបាំងមុខគូភាគីណាម្ខាង ឬសាលក្រមចាត់ថាចំពោះមុខ
- ដើមបណ្ដឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី និងជនជាប់ចោទមានសិទ្ធិក្នុងការប្ដឹងទាស់ដែលមានរយៈពេល១៥ថ្ងៃ ឬប្ដឹងឧទ្ធរណ៍ដែលមានរយៈពេលកំណត់១ខែដោយចាប់គិតពីថ្ងៃប្រកាសសាលក្រមនេះតទៅ ផុតរយៈពេលកំណត់ខាងលើគ្មានគ្មានការប្ដឹងទាស់ ឬប្ដឹងឧទ្ធរណ៍សាលក្រមនឹងចូលជាស្ថាពរ។

ការប្រកាសសាលក្រម គឺតុលាការអាចលើកទៅប្រកាសនៅសវនាការលើក្រោយបានប្រសិនបើរឿងក្ដីមានលក្ខណៈស្មុគស្មាញ ប្រធានសវនាការជូនដំណឹងដល់គូភាគីដែលមានវត្តមាន និងអវត្តមានអំពីថ្ងៃដែលត្រូវប្រកាសសាលក្រម។ ក្រោយពីបញ្ចប់ការជំនុំជម្រះជនជាប់ចោទត្រូវផ្ដិតមេដៃលើកំណត់ ហេតុសវនាការនៅកន្លែងក្រឡាបញ្ជី។

### ឃ. ការប្រកាសថយនៅពិភាក្សា

ក្រោយពិបិទកិច្ចពិភាក្សាដេញដោល ចៅក្រមជនុំជម្រះ ឬក្រុមប្រឹក្សាជំនុំជម្រះនឹងថយខ្លួនចូលទៅក្នុងបន្ទប់ពិភាក្សាប្រមាណ ១៥ ទៅ ៣០នាទីដើម្បីធ្វើការពិភាក្សាសម្រេច។ ដំណាក់កាលនេះបណ្ដឹងស្នើសុំ ឬការបង្ហាញភស្តុតាងបន្ថែមមិនអាចដាក់ជូនតុលាការបានទៀតទេ។ តំណាងអយ្យការនឹងក្រឡាបញ្ជីមិនត្រូវបានអនុញ្ញាតឲ្យចូលក្នុងការពិភាក្សាសម្រេចឡើយ។ ចំណែកសាធារណជនទាំងអស់ត្រូវនៅក្នុងបន្ទប់សវនាការដដែល ដើម្បីរង់ចាំស្ដាប់ការប្រកាសសាលក្រមរបស់តុលាការ។

ការប្រកាសសាលក្រមត្រូវប្រកាសជាសាធារណៈនៅថ្ងៃដែលពិភាក្សាដេញដោល ឬនៅក្រោយពេលសវនាការ។ នៅក្នុងសេចក្ដីសម្រេចរបស់តុលាការមានបញ្ជាក់ពីការកំណត់នូវពិរុទ្ធភាព ព្រមទាំងប្រកាសអំពីទោសដែលត្រូវបានកំណត់ដោយច្បាប់។ ក្នុងករណីដែលតុលាការយល់ឃើញថាមិនមែនជាបទល្មើស ឬជនជាប់ចោទមិនមាននូវពិរុទ្ធភាពតុលាការអាចប្រកាសសាលក្រមដោយ សម្រេចឲ្យជនជាប់ចោទរួចផុតពីការចោទប្រកាន់។

ប្រសិនបើតុលាការសម្រេចថាមានទោសដោយត្រូវដាក់ពន្ធនាគារនោះ តុលាការអាចចេញដីកាបង្គាប់ឲ្យឃុំខ្លួនបើជនជាប់ចោទមានវត្តមាននៅក្នុងសវនាការ ឬចេញដីកាបង្គាប់ឲ្យចាប់ខ្លួនប្រសិនបើជនជាប់ចោទអវត្តមាននៅក្នុងពេលសវនាការ។

## ផ្នែកទី២ សេចក្ដីសម្រេចរបស់តុលាការជាន់ដំបូង

### កថាខណ្ឌទី១ ប្រភេទនៃសាលក្រម

#### ក.សាលក្រមចំពោះមុខ

សាលក្រមចំពោះមុខ គឺជាសាលក្រមដែលចេញនៅចំពោះវត្តមាន របស់គូភាគីនៃបណ្ដឹងទាំងអស់សាស់។

សាលក្រមចំពោះមុខនេះក្រមនីតិវិធីព្រហ្មទណ្ឌ មិនបានឲ្យនិយមន័យឲ្យបានច្បាស់លាស់នោះទេ។ ប៉ុន្តែយើងអាចកំណត់សម្គាល់ចំពោះសាលក្រមនេះបានដោយពិនិត្យលើស្ថានភាពជាក់ស្តែងដែលជាហេតុនាំឲ្យតុលាការចេញសាលក្រមចំពោះមុខ។

ប្រសិនបើជនជាប់ចោទចូលបង្ហាញខ្លួន នៅពេលសវនាការតុលាការនឹងចេញសាលក្រមចំពោះមុខជនជាប់ចោទ។ សាលក្រមចំពោះមុខជនជាប់ចោទមិនត្រូវឲ្យដំណឹងដល់ជនជាប់ចោទទេ។ សាលក្រមនៅតែជាសាលក្រមចំពោះមុខ ដែលទោះបីជាជនជាប់ចោទចាកចេញពី បន្ទប់សវនាការក៏ដោយ។ សាលក្រមចំពោះមុខអាចប្តឹងឧទ្ធរណ៍បាន។[120]

ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណី ចូលបង្ហាញខ្លួននៅក្នុងពេលសវនាការនោះតុលាការ នឹងចេញសាលក្រមចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី។ សាលក្រមចំពោះមុខមិនត្រូវជូនដំណឹងដល់ដើមបណ្តឹងរដ្ឋប្បវេណីទេ។ សាលក្រមចំពោះមុខអាចប្តឹងឧទ្ធរណ៍បាន។[121]

ប្រសិនបើអ្នកទទួលខុសត្រូវរដ្ឋប្បវេណីចូល បង្ហាញខ្លួននៅក្នុងពេលសវនាការនោះ តុលាការនឹងចេញសាលក្រមចំពោះមុខអ្នកទទួលខុសត្រូវរដ្ឋប្បវេណី។ សាលក្រមចំពោះមុខមិនត្រូវជូនដំណឹងដល់អ្នកទទួលខុសត្រូវរដ្ឋប្បវេណីទេ។ សាលក្រមចំពោះមុខអាចប្តឹងឧទ្ធរណ៍បាន។[122]

### ខ. សាលក្រមចាត់ទុកថាចំពោះមុខ

សាលក្រមចាត់ថាចំពោះមុខ គឺជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះមិនបានចូលបង្ហាញខ្លួនក្នុងសវនាការទេ ប៉ុន្តែសមីខ្លួនបានដឹងពីដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬបានដឹងពីដីកោះហៅនោះសាលក្រមដែលតុលាការប្រកាសចាត់ទុកថាជា សាលក្រមចំពោះមុខ។ ប្រសិនបើជន ជាប់ចោទមិនបានចូលបង្ហាញខ្លួននៅពេលសវនាការទេ ហើយសមីខ្លួនបានដឹងពីដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬបានដឹងអំពីការកោះហៅនោះតុលាការនឹងប្រកាសសាលក្រមចាត់ថាចំពោះមុខជនជាប់ចោទ។ សាលក្រមចាត់ថាចំពោះមុខត្រូវឲ្យដំណឹងដល់ជនជាប់ចោទ។សាលក្រមចាត់ថាចំពោះមុខនេះអាចប្តឹងឧទ្ធរណ៍បាន។[123]ប៉ុន្តែក្នុងករណីដែលជនជាប់ចោទវត្តមានដោយមានផ្តល់ ដំណឹងជាមុនដល់ តុលាការ ព្រមទាំងបង្ហាញពីមូលហេតុនៃការអវត្តមានរបស់ខ្លួន ហើយមូលហេតុនោះតុលាការអាចទទួលយកបាននោះ តុលាការអាចសម្រេចលើករឿងទៅ ជំនុំជម្រះនៅសវនាការ

[120] មាត្រា៣៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[121] មាត្រា៣៦៣ វាក្យខ័ណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[122] មាត្រា៣៦៤ វាក្យខ័ណ្ឌទី១ នៃក្រមនីតិវិធីប្រហ្មទណ្ឌ ឆ្នាំ២០០៧

[123] មាត្រា៣៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

លើកក្រោយបាន។ ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីមិនបានចូលបង្ហាញខ្លួននៅក្នុង ពេលសវនាការទេហើយ សាមីខ្លួនបានដឹងពីដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬបានដឹងអំពីការកោះហៅនោះតុលាការនឹងប្រកាសសាលក្រមចាត់ថាចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី។ សាលក្រមចាត់ថាចំពោះមុខត្រូវឲ្យដំណឹងដល់ដើមបណ្តឹងរដ្ឋប្បវេណី។ សាលក្រមចាត់ថាចំពោះមុខនេះអាចប្តឹងឧទ្ធរណ៍បាន។ ប៉ុន្តែនៅក្នុងករណីដែលដើមបណ្តឹងរដ្ឋប្បវេណីអវត្តមានដោយមានការផ្តល់ដំណឹងជា មុនដល់តុលាការព្រមទាំងមានការបង្ហាញពីមូលហេតុនៃការអវត្តមានរបស់ខ្លួន ហើយមូលហេតុនោះតុលាការអាចទទួលយកបាន នោះតុលាការអាចសម្រេចលើករឿងទៅជំនុំជម្រះនៅសវនាការលើកក្រោយបាន។

ប្រសិនបើអ្នកទទួលខុសត្រូវរដ្ឋប្បវេណីមិនបាន ចូលបង្ហាញខ្លួននៅក្នុងពេលសវនាការបើយសមីខ្លួនបានដឹងពីដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬបានដឹងអំពីការកោះហៅនោះតុលាការ នឹងប្រកាសសាលក្រមចាត់ថាចំពោះមុខអ្នកទទួលខុសត្រូវរដ្ឋប្បវេណី។ សាលក្រមចាត់ថាចំពោះមុខត្រូវឲ្យដំណឹងដល់អ្នកទទួលខុសត្រូវរដ្ឋប្បវេណី។ សាលក្រមចាត់ថាចំពោះមុខអាចប្តឹងឧទ្ធរណ៍បាន។ ប៉ុន្តែក្នុងករណីដែលអ្នកទទួលខុសត្រូវរដ្ឋប្បវេណីអវត្តមានដោយមានផ្តល់ដំណឹងជាមុនដល់តុលាការ ព្រមទាំងបង្ហាញពីមូលហេតុនៃការអវត្តមានរបស់ខ្លួនហើយមូលហេតុនោះតុលាការអាចទទួលយកបាន នោះតុលាការអាចសម្រេចលើក រឿងទៅជំនុំជម្រះនៅសវនាការ លើកក្រោយបាន។

**គ. សាលក្រមកំបាំងមុខ**

សាលក្រមកំបាំងមុខ គឺជាសាលក្រមដែលតុលាការប្រកាសកំបាំងមុខជនជាប់ចោទ ជនរងគ្រោះ ដើមបណ្តឹងរដ្ឋប្បវេណី និងបុគ្គលដែលពាក់ពន្ធ័នឹងរឿងក្តីទាំងអស់ដែលអវត្តមាននៅក្នុងពេល សវនាការ។ប្រសិនបើជនជាប់ចោទមិនបានចូលបង្ហាញខ្លួននៅក្នុងពេលសវនាការទេ ហើយប្រសិនបើគ្មានភស្តុតាងបញ្ជាក់ថាសាមីខ្លួនបានដឹងពីដីកាបញ្ជូនទៅជំនុំជម្រះ ឬបានដឹងអំពីការកោះហៅនោះទេ តុលាការនឹងប្រកាសសាលក្រមកំបាំងមុខជនជាប់ចោទ។ សាលក្រមកំបាំងត្រូវឲ្យដំណឹងដល់ជនជាប់ចោទ។ សាលក្រមកំបាំងមុខនេះអាចប្តឹងទាស់បាន។[124]

ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីមិនបានចូលបង្ហាញខ្លួននៅក្នុងពេលសវនាការទេ នឹងគ្មានអ្នកតំណាងត្រឹមត្រូវទេ នោះតុលាការនឹងចេញសាលក្រមកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី។ សាលក្រមកំបាំងមុខត្រូវជូនដំណឹងដល់ដើមបណ្តឹងរដ្ឋប្បវេណី។ សាលក្រមកំបាំងមុខអាចប្តឹងទាស់បាន។[125]

[124] មាត្រា ៣៦៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[125] មាត្រា៣៦៣ វាក្យខ័ណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ប្រសិនបើអ្នកទទួលខុសត្រូវរដ្ឋប្បវេណីមិនបានចូលបង្ហាញខ្លួននៅក្នុងពេលសវនាការទេ ហើយគ្មានអ្នកតំណាងត្រឹមត្រូវទេនោះតុលាការ នឹងចេញសាលក្រមកំបាំងមុខអ្នកទទួលខុសត្រូវរដ្ឋប្បវេណី។ សាលក្រមកំបាំងមុខត្រូវជូនដំណឹងដល់ អ្នកទទួលខុសត្រូវរដ្ឋប្បវេណី។ សាលក្រមកំបាំងមុខនេះអាចប្តឹងទាស់បាន។[126]

### គ.១ បណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ

ការប្តឹងទាស់ទៅសាលក្រមកំបាំងមុខ គឺជាការបណ្តឹងមិនសុខចិត្តនឹងប្រឆាំងនឹងសេចក្តីសម្រេច(សាលក្រម)ដែលតុលាការបានសម្រេចដោយកំបាំងមុខជនណាម្នាក់។

### គ.២ បុគ្គលដែលមានសិទ្ធិធ្វើបណ្តឹងទាស់

បុគ្គលដែលមានសិទ្ធីប្តឹងទាស់ចំពោះសាលក្រមកំបាំងរបស់តុលាការមានដូចជាៈ

- **ពិរុទ្ធជន**

ពិរុទ្ធជនមានសិទ្ធិធ្វើការប្តឹងទាស់សាលក្រមកំបាំងមុខទាំងស្រុង ឬដែលធ្វើដោយផ្នែកដែលខ្លួនយល់ថាមិនសុខចិត្តទៅលើសេចក្តីសម្រេចនោះ។

- **ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី**

ដើមបណ្តឹងរដ្ឋបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណីអាចប្តឹងទាស់និងសាលក្រមកំបាំងមុខខ្លួនបានតាមមាត្រា៣៧២នៃក្រមនីតិវីធីព្រហ្មទណ្ឌ។បណ្តឹងទាស់នេះត្រូវ ធ្វើទៅលើផ្នែករដ្ឋប្បវេណីនៃសាលក្រមនេះតែប៉ុណ្ណោះ។

### គ.៣ ទម្រង់

បណ្តឹងទាស់ត្រូវធ្វើដោយពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរៈ

- នៅការិយាល័យក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម
- នៅចំពោះមុខព្រះរាជអាជ្ញា អង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ ឬ នៅចំពោះមុខប្រធាន ពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន។

ពិរុទ្ធជនអាចត្រូវបានតំណាងដោយមេធាវី។ មេធាវីត្រូវតែមានលិខិតអនុញ្ញាតអោយធ្វើបណ្តឹងទាស់។ ប៉ុន្តែ ពិរុទ្ធជនជាអនីតិជនអាចត្រូវតំណាងដោយឪពុក ម្តាយ ឬ អ្នកអាណាព្យាបាល។ ក្នុងករណីនេះអ្នកតំណាងមិនចាំបាច់មានលិខិតប្រគល់សិទ្ធិទេ។ កាលណាបានទទួលពាក្យប្តឹងទាស់ ព្រះរាជអាជ្ញា អង្គភាពនគរបាល និងកងរាជអាវុធហត្ថព្រមទាំងប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន បញ្ជូនបណ្តឹងទាស់នោះភ្លាមទៅក្រឡាបញ្ជីតុលាការដែលបានប្រកាសសាលក្រម។កាលណាអ្នកប្តឹងទាស់មិនចេះចុះហត្ថលេខាទេអ្នកប្តឹងទាស់នេះត្រូវផ្តិតម្រាមដៃ។

[126] មាត្រា ៣៦៤ វាក្យខ័ណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

**គ.៤ រយៈពេលធ្វើបណ្តឹងទាស់**

បុគ្គលដែលមានសិទ្ធិបណ្តឹងទាស់ត្រូវធ្វើពាក្យបណ្តឹងនៅក្នុង រយៈពេល១៥(ដប់ប្រាំ)ថ្ងៃចាប់ផ្តើមគិតពីថ្ងៃ:

- ពីថ្ងៃជូនដំណឹងអំពីសាលក្រមកំបាំងមុខ កាលណាសាលក្រមត្រូវបានប្រគល់អោយបុគ្គលដែល មាន សិទ្ធិបណ្តឹងទាស់ផ្ទាល់ដៃ។
- ពីថ្ងៃដែលបុគ្គលដែលមាន សិទ្ធិប្តឹងទាស់នេះបានដឹង យ៉ាងពិតប្រាកដអំពីសាលក្រមកាលណា សាលក្រមនេះ មិនបានប្រគល់អោយដល់ពិរុទ្ធជនដោយផ្ទាល់ដៃទេ។

**គ.៥ អានុភាព**

កាលណាបណ្តឹងទាស់ធ្វើប្រឆាំងទៅលើ សាលក្រមទាំងមូលសាលក្រមនេះត្រូវទុកជាអសារបង់។ចំណែក ការអនុវត្តទៅលើសាលក្រមត្រូវព្យួរ។ ប៉ុន្តែដីកាបង្គាប់អោយចាប់ខ្លួននៅតែមានអនុភាព។ តុលាការនៅតែមាន សមត្ថកិច្ចដើម្បីសម្រេចអំពី ការដោះលែងជនជាប់ចោទអោយមានសេរីភាពវិញ។ កាលណាបណ្តឹងទាស់ធ្វើប្រ ឆាំងទៅលើ សេចក្តីសម្រេចផ្នែករដ្ឋប្បវេណីមានតែ សេចក្តីសម្រេចផ្នែកនេះប៉ុណ្ណោះ ដែលទុកជាអសារបង់។ ការ អនុវត្តសេចក្តីសម្រេចផ្នែក រដ្ឋប្បវេណីនេះត្រូវព្យួរ។ បណ្តឹងទាស់ដែលទាក់ទងទៅនឹងសំណុំរឿងត្រូវបានលើក យកមកជំនុំជម្រះនៅ មុខតុលាការដដែល។ ភាគីទាំងអស់ត្រូវបានកោះហៅតាមគំនិតផ្តើម របស់ព្រះរាជអាជ្ញា។ ក្រោយពីបានពិនិត្យមើលភាពអាចទទួលបាននៃបណ្តឹងទាស់នេះតុលាការសម្រេចលើអង្គសេចក្តីជាថ្មីម្តងទៀត។

ប្រសិនបើអ្នកប្តឹងទាស់ដែលកោះហៅដោយត្រឹមត្រូវហើយមិនចូលបង្ហាញខ្លួននៅពេលសវនាការទេតុលាការ ប្រកាសថាបណ្តឹងទាស់ទុកជាឯកសារឥតបានការ។ សាលក្រមដែលគេប្តឹងទាស់ មិនអាចត្រូវកែប្រែទេ។ សាល ក្រមនេះមានអានុភាពទាំងស្រុងចំពោះភាគីទាំងអស់។

**ឃ. សាលក្រមចាត់របៀប**

សាលក្រមចាត់របៀប គឺជាសាលក្រមដែលតុលាការអោយប្រធានសវនាការ ចៅក្រមមួយរូបនៃក្រុមប្រឹក្សាជំនុំ ជម្រះ ឬចៅក្រមដទៃទៀតនៃតុលាការជាន់ដំបូងធ្វើការស៊ើបសួរបន្ថែម ប្រសិនបើយល់ឃើញថាការស្រាវជ្រាវថ្មីចំបា ច់។ចៅក្រមដែលទទួលបន្ទុកស៊ើបសួរបន្ថែមនេះ អាចប្រើសិទ្ធិអំណាចដូចចៅក្រមស៊ើបសួរដែរ។ សាលក្រម របៀបមិនអាចប្តឹងឧទ្ធរណ៍តែឯងបានទេ មានន័យថាសាលក្រមរបៀបអាចដាក់ជូនសាលាឧទ្ធរណ៍ពិនិត្យបាន លុះត្រាតែធ្វើព្រមគ្នាជាមួយនឹងសាលក្រមលើអង្គសេចក្តី។ ប៉ុន្តែសាលក្រមចាត់របៀបដែលបញ្ចប់នីតិវិធីអាចប្តឹង ឧទ្ធរណ៍បាន(មាត្រា៣៨៥)។

- **ដីការឲ្យដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការ**

ដីកាឲ្យដំណឹង គឺជាលិខិតឲ្យដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការដែលបញ្ញត្តិច្បាប់តម្រូវឲ្យជូនដំណឹង

ដល់ភាគីដែលពាក់ពន្ធ័ដើម្បីឲ្យភាគីដែលពាក់ពន្ធ័ទួលបានដំណឹងអំពីសេចក្តីសម្រេចនោះ។[127]ដីកាឲ្យដំណឹងចេញដោយព្រះរាជអាជ្ញា ឬ អគ្គព្រះរាជអាជ្ញា។ ដីកាឲ្យដំណឹងមានចុះនិទ្ទេសដូចជា៖

- ប្រភេទ និងការយោងសេចក្តីសម្រេចដែលត្រូវជូនដំណឹង
- អត្តសញ្ញាណ និងលំនៅឋាននៃភាគីដែលត្រូវទទួលដំណឹងអំពីសេចក្តីសម្រេច
- កាលបរិច្ឆេទ និងហត្ថលេខារបស់អ្នកដែលត្រូវជូនដំណឹង។

ដីកានេះត្រូវបញ្ជាក់ប្រាប់អំពីផ្លូវតវ៉ាដែលអាចធ្វើបាន ដើម្បីប្រឆាំងទៅនឹងសេចក្តីសម្រេចដែលត្រូវបានជូនដំណឹង។ លិខិតចម្លងនៃសេចក្តីសម្រេចជូនដំណឹងត្រូវភ្ជាប់ជាមួយនឹងដីកាឲ្យដំណឹងអំពីសេចក្តីសម្រេរបស់តុលាការ។[128]

- **ការជូនដំណឹងដល់ជនជាប់ចោទ**

ការជូនដំណឹងអាចប្រគល់ឲ្យជនជាប់ចោទដោយផ្ទាល់ដៃរបស់ព្រះរាជអាជ្ញា។ ករណីនេះព្រះរាជអាជ្ញាប្រគល់លិខិតចម្លងនៃសេចក្តីសម្រេចរបស់តុលាការដល់ជនជាប់ចោទ ដោយចុះនិទ្ទេសលើសេចក្តីសម្រេចដើមអំពីកាលបរិច្ឆេទ និងទីកន្លែងនៃការប្រគល់លិខិតចម្លង ហើយជនជាប់ចោទត្រូវចុះហត្ថលេខានៅលើសេចក្តីសម្រេចដើមនោះ។[129]លិខិតចម្លងនៃសេចក្តីសម្រេចអាចប្រគល់ដោយអាជ្ញាសាលាទៅដល់លំនៅដ្ឋានរបស់ជនជាប់ចោទដែលកំពុងស្នាក់នៅ ឬ នៅកន្លែងផ្សេងទៀតដែលអាជ្ញាសាលាបានជួបប្រទះជនជាប់ចោទ។ អាជ្ញាសាលាចារនៅលើសេចក្តីសម្រេដើមថា លិខិតចតចម្លងត្រូវបានប្រគល់ដល់ជនជាប់ចោទដោយផ្ទាល់ដៃ។ អាជ្ញាសាលាចុះនិទ្ទេសអំពីកាលបរិច្ឆេទ និងទីកន្លែងដែលបានប្រគល់លិខិតចម្លង។ ជនជាប់ចោទត្រូវចុះហត្ថលេខានៅលើសេចក្តីសម្រេចដើម។ សេចក្តីសម្រេចដើមត្រូវបង្វិលជូនមកព្រះរាជអាជ្ញាវិញជាបន្ទាន់។[130]ករណីដែលជនជាប់ចោទ អវត្តមានពីលំនៅឋាន អាជ្ញាសាលាអាចប្រគល់លិខិតចម្លងនៃសេចក្តីសម្រេច ទៅដល់បុគ្គលណាដែលជានីតិជនមានវត្តមាននៅក្នុងលំនៅឋាន។ អាជ្ញាសាលាចុះនិទ្ទេសអំពីអត្តសញ្ញាណនៃបុគ្គលនេះ និងអំពីកាលបរិច្ឆេទនៃការប្រគល់លិខិតចម្លងនៃសេចក្តីសម្រេច។ បុគ្គលដែលទទួលចុងដីកាកោះត្រូវចុះហត្ថលេខានៅលើសេចក្តីសម្រេចដើម។ សេចក្តីសម្រេចដើមត្រូវបង្វិលជូនមកព្រះរាជអាជ្ញាវិញភ្លាម។ បុគ្គលដែលទទួលលិខិតចតចម្លងនៃសេចក្តីសម្រេច ត្រូវសន្យាថានឹងប្រគល់ដីកានេះ ដល់ជនជាប់ចោទក្នុងរយៈពេលដ៏ខ្លី

[127] មាត្រា ៤៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[128] មាត្រា ៤៨៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[129] មាត្រា ៤៨៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[130] មាត្រា៤៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

បំផុត[131]អាជ្ញាសាលាអាចប្រគល់លិខិតចតចម្លងនៃសេចក្ដីសម្រេចឲ្យមេឃុំ ឬចៅសង្កាត់ ឬ ជំទប់ ឬចៅសង្កាត់រងក្នុងករណី៖

- ជនជាប់ចោទមិនព្រមទទួលសេចក្ដីសម្រេច
- គ្មានបុគ្គលណាម្នាក់មានវត្តមាននៅក្នុងលំនៅឋានរបស់ជនជាប់ចោទ
- គ្មានបុគ្គលណាម្នាក់មានវត្តមាននៅក្នុងលំនៅដ្ឋានរបស់ជនជាប់ចោទ យល់ព្រមទទួលសេចក្ដីសម្រេច។

អាជ្ញាសាលាចុះនិទ្ទេសនៅលើសេចក្ដីសម្រេចដើម អំពីអត្តសញ្ញាណ និងឋានៈបុគ្គលដែលបានទទួលលិខិតចម្លងនៃសេចក្ដីសម្រេចព្រមទាំអកាលបរិច្ឆេទ នៃការប្រគល់។ បុគ្គលដែលទទួលលិខិតចម្លង ត្រូវចុះហត្ថលេខានៅលើសេចក្ដីសម្រេចដើម។ សេចក្ដីសម្រេចដើមត្រូវបង្វិលត្រឡប់ជូនព្រះរាជអាជ្ញាវិញភ្លាម។ បុគ្គលដែលបានទទួលលិខិតចតចម្លងនៃសេចក្ដីសម្រេចត្រូវសន្យានិងប្រគល់ដីកានេះក្នុងរយៈពេលដ៏ខ្លីបំផុតឲ្យជនជាប់ចោទ។[132]ការជូនដំណឹងក៏អាចប្រគល់តាមរយៈ៖

- ក្រឡាបញ្ជី
- អាជ្ញាធររដ្ឋបាល
- ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ប្រសិនបើជនជាប់ចោទត្រូវជាប់ឃុំខ្លួនពីបទផ្សេងទៀត
- អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ

ក្រឡាបញ្ជី អាជ្ញាធររដ្ឋបាល ប្រធានពន្ធនាគារ មន្ត្រីនគរបាលជាតិ ឬកងរាជអាវុធហត្ថត្រូវគោរពតាមបញ្ជាររបស់ព្រះរាជអាជ្ញា ក្នុងការប្រគល់លិខិតជូនដំណឹងស្ដីពីសេចក្ដីសម្រេចរបស់តុលាការ។[133]

- **ការជូនដំណឹងដល់ជនរងគ្រោះ**

ការជូនដំណឹងអាចប្រគល់ឲ្យជនរងគ្រោះ ដោយផ្ទាល់ដៃរបស់ព្រះរាជអាជ្ញា។ ករណីនេះព្រះរាជអាជ្ញាប្រគល់លិខិតចម្លងនៃសេចក្ដីសម្រេចរបស់តុលាការដល់ ដើមបណ្ដឹងរដ្ឋប្បវេណី ដោយចុះនិទ្ទេសលើសេចក្ដីសម្រេចដើមអំពីកាលបរិច្ឆេទ និងទីកន្លែងនៃការប្រគល់លិខិតចតចម្លង ហើយដើមបណ្ដឹងរដ្ឋប្បវេណីត្រូវចុះហត្ថលេខានៅលើសេចក្ដីសម្រេចដើមនោះ។[134]

លិខិតចម្លងនៃសេចក្ដីសម្រេចអាច ប្រគល់ដោយអាជ្ញាសាលាទៅដល់លំនៅដ្ឋានរបស់ដើមបណ្ដឹងរដ្ឋប្បវេណី

[131] មាត្រា៤៨៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[132] មាត្រា៤៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[133] មាត្រា៤៨៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[134] មាត្រា ៤៨៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ដែលកំពុងស្នាក់នៅឬ នៅកន្លែងផ្សេងទៀតដែលអាជ្ញាសាលាបានជួបប្រទះដើមបណ្តឹងរដ្ឋប្បវេណី។ អាជ្ញាសាលាចារនៅលើសេចក្តីសម្រេដើមថា លិខិតថតចម្លងត្រូវបានប្រគល់ដល់ដើមបណ្តឹងរដ្ឋប្បវេណីដោយផ្ទាល់ដៃ។

## កថាខណ្ឌទី២ ការបណ្តឹងទៅសាលាឧទ្ធរណ៍

នៅក្រោយពីប្រកាសសាលក្រម ហើយភាគីណាម្នាក់ដែលមិនសុខចិត្តទៅសេចក្តីសម្រេចរបស់តុលាការ ឬយល់ឃើញថាសាលក្រមនេះធ្វើអោយបាត់បង់ផលប្រយោជន៍របស់បុគ្គលនោះអាចធ្វើពាក្យបណ្តឹងរបស់ខ្លួនមកសាលាឧទ្ធរណ៍បាន។ ការធ្វើពាក្យបណ្តឹងត្រូវធ្វើនៅការិយាល័យក្រឡាបញ្ជសាមីដែលចេញសាលក្រមនេះ។អ្នកដែលមានសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍បានមានដូចខាងក្រោមៈ

- អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍
- ព្រះរាជអាជ្ញាសាលាដំបូង
- ពិរុទ្ធជន
- ដើមបណ្តឹងរដ្ឋប្បវេណី
- អ្នកទទួលខុសត្រូវរដ្ឋប្បវេណី។

ការធ្វើពាក្យបណ្តឹងត្រូវធ្វើនៅការិយាល័យក្រឡាបញ្ជីសាមីដែលចេញសាលក្រមនេះ។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដាក់ពាក្យបណ្តឹងនៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍(មាត្រា៣៧៩)។ ការដាក់ពាក្យបណ្តឹងឧទ្ធរណ៍ក្នុងរឿងព្រហ្មទណ្ឌ សាលាឧទ្ធរណ៍នឹងបញ្ជូនរឿងនេះ ទៅសភាព្រហ្មទណ្ឌដើម្បីធ្វើចំណាត់ការទៅលើបណ្តឹងឧទ្ធរណ៍ចំពោះសាលក្រម។ រយៈពេលបណ្តឹងឧទ្ធរណ៍ ចំពោះបុគ្គលដែមានសិទ្ធមានដូចខាងក្រោមៈ

- អគ្គព្រះរាជអាជ្ញាត្រូវក្នុងរយៈពេល៣(បី)ខែ
- ព្រះរាជអាជ្ញា ក្នុងរយៈពេល១(មួយ)ខែ
- ពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណីមានរយៈពេល១(មួយ)ខែ។

សាលក្រមដែលអាចប្តឹងឧទ្ធរណ៍បានគឺសាលក្រមចំពោះមុខ នឹងសាលក្រមចាត់ទុកជាចំពោះមុខ។ ប្រសិនបើផុតរយៈពេលដូចខាងលើសាលក្រមនេះ នឹងជាសាលក្រមស្ថាពរ។ គ្រប់សាលក្រមទាំងអស់ដែលចូលជាស្ថាពរមិនអាចប្តឹងតវ៉ាបានទៀតទេ។

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការបកស្រាយនូវ ចំណោទបញ្ហាដែលបានកើតឡើងខាងលើ រួចមកហើយ។ យើងពិនិត្យឃើញថានៅពេលដែលមានការដាក់ពាក្យបណ្តឹងទៅលើរឿងក្តីព្រហ្មទណ្ឌណាមួយគេត្រូវធ្វើ ចំណាត់លើរឿងក្តីព្រហ្មទណ្ឌនោះភ្លាមដើម្បីពិនិត្យអោយដឹងថាពាក្យបណ្តឹងនោះជាបទល្មើសដែលឬទេ។ នៅក្នុងការធ្វើចំណាត់ការក្នុងរឿងព្រហ្មទណ្ឌគេបែងចែងជា៤ ដំណាក់ការដោយដំណាក់ការដំណាក់ការស៊ើបអង្កេត ដំណាក់ការចោទប្រកាន់ ដំណាក់ការស៊ើបសួរ និងចុងក្រោយដំណាក់ការជំនុំជម្រះ។នៅពេលដែលជនរងគ្រោះទទួលរងគ្រោះដោយអំពើរបស់ជនល្មើស ជនរគ្រោះអាចធ្វើពាក្យបណ្តឹងទៅ មន្ត្រីនគរបាលយុត្តិធម៌ ឬបណ្តឹងទៅតុលាការ។ បន្ទាប់ពីការបិទការស៊ើបអង្កេតហើយមន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនជននោះ និងភស្តុតាងទៅព្រះរាជអាជ្ញាដើម្បីធ្វើការចោទប្រកាន់។ ព្រះរាជអាជ្ញាបន្ទាប់ពីចោទហើយត្រូវបញ្ជូនជននោះទៅចៅក្រមស៊ើបសួរតាមដីកាសន្និបញ្ជូនរឿងអោយស៊ើបសួរ។ បន្ទាប់ពីការបិទការស៊ើបសួរចៅក្រមស៊ើបសួរត្រូវបញ្ជូនជននោះទៅជំនុំជម្រះ។ បណ្តឹងដែលតុលាការទទួលមកជំនុំជម្រះអាចតាមរយៈព្រះរាជអាជ្ញា ឬតាមរយៈចៅក្រមស៊ើបសួរ។ បើយើងក្រលេកមើលចំណាត់ការក្នុងដំណាក់ការនីមួយៗដែលអនុវត្តលើពាក្យបណ្តឹងវាមានភាពលម្អិតខ្លាំងណាស់មុននឹងចេញសេចក្តីសម្រេចដែលអាចប៉ះពាល់ដល់សិទ្ធិ នឹងការបាត់បង់សេរីភាពទៅលើបុគ្គលណាម្នាក់ដែលតុលាការបានចេញសេចក្តីសម្រេច ហើយសេចក្តីសម្រេចនោះអាចជាការដាក់ពន្ធនាគារ និងការពិន័យជាប្រាក់។ដូចនេះហើយបានជាមុនចេញសាលក្រមចៅក្រមជំនុំជម្រះត្រូវសិក្សាទៅសំណុំរឿង និងភស្តុតាងដែលបញ្ជូនមកអោយខ្លួន។

សរុបសេចក្តីមក ចំពោះសារណាមួយនេះ គឺបានចង្អុលបង្ហាញយ៉ាងច្បាស់អំពីដំណើរការនៃពាក្យបណ្តឹងក្នុងរឿងព្រហ្មទណ្ឌ ដែលបង្ហាញអោយឃើញថាចំណាត់ការក្នុងប្រព័ន្ធតុលាការពិតជាសុក្រឹត្យ យុត្តិធម៌ខ្លាំងណាស់ក្នុងការស្វែងរកយុត្តិធម៌ជូនប្រជាជន ដោយប្រើដំណាក់ការជាច្រើនដើម្បីធ្វើអោយការសម្រេចសេចក្តី(ហៅថាសាលក្រម)មានតម្លាភាព និងយុត្តិធម៌ត្រឹមត្រូវ ។

# អនុសាសន៍

ជាចុងបញ្ចប់ ក្រោយពីបានសិក្សាស្រាវជ្រាវលើប្រធានបទនេះ យើងខ្ញុំក៏បានសង្កេតឃើញថា នៅកម្ពុជានាពេលបច្ចុប្បន្ន បញ្ហានៃការគោរព និងការអនុវត្តច្បាប់នៅមានកម្រិតនៅឡើយ ហើយក៏ជាមូលហេតុដែលធ្វើឲ្យស្ថាប័ននីមួយៗកាន់តែធ្លាក់ចុះ និងគ្មានប្រសិទ្ធភាព។ ការអនុវត្តគ្មានប្រសិទ្ធភាពនេះហើយដែលធ្វើឲ្យប៉ះពាល់ដល់ជំនឿ និងសេចក្តីទុកចិត្តពីមជ្ឈដ្ឋានមកលើស្ថាប័នរដ្ឋផងដែរ ថាតើមូលហេតុទាំងនោះមកពីមូលហេតុអ្វី?មកពីគ្មានការគោរពច្បាប់ឬមួយក៏យ៉ាងណា?តើយើងត្រូវធ្វើយ៉ាងណាដើម្បីឲ្យមានការគោរពច្បាប់ និងអនុវត្តច្បាប់ឲ្យមានប្រសិទ្ធិភាព ព្រមទាំងការរក្សាឲ្យបាននូវភាពស្មើគ្នា និងមិនលំអៀងនៃអណាច?

បើយើងពិនិត្យមើលស្ថានភាពនាពេលបច្ចុប្បន្ន យើងសង្កេតឃើញថា គឺមានមូលហេតុមួយចំនួនដែលនាំឲ្យច្បាប់ និងស្ថាប័នគ្មានប្រសិទ្ធភាព និង មានប្រសិទ្ធភាពបានតិចតួចក្នុងការអនុវត្តដោយ **បក្សពួកនិយម** គឺច្បាប់មិនមានប្រសិទ្ធភាពទៅលើជនជនគ្រប់រូប និងគ្រប់ឋានៈនោះទេ ពោលគឺចំពោះអ្នកមានអំណាច ឬអ្នកកាន់ការងារស្រុកទេសធំៗ ដែលបានល្មើសច្បាប់គឺតែងតែគេចផុតពីការទទួលខុសត្រូវចំពោះមុខច្បាប់ជានិច្ច ប៉ុន្តែបែរជាមានប្រសិទ្ធភាពខ្លាំងទៅវិញចំពោះអ្នកដែលទន់ខ្សោយ ឬ អ្នកគ្មានអំណាច ឬចំពោះអ្នកដែលគ្មានខ្សែរស្រឡាយធំៗ។**អំពើពុករលួយ** **គឺ**ជាជំងឺមួយដែលធ្វើឲ្យប្រជាពលរដ្ឋមួយចំនួនបំភ្លេចអស់រលីងនូវផលប្រយោជរួមហើយបែរជាមកគិតតែពីផលប្រយោជន៍ផ្ទាល់ខ្លួន និងក្រុមគ្រួសារខ្លួនវិញ ដោយមិនគិតពីអ្នកដ៏ទៃដែលរស់នៅក្នុងទឹកដីតែមួយ។ ម្យ៉ាងទៀត អំពើនេះនឹងធ្វើឲ្យមនុស្សហ៊ានធ្វើអ្វីៗគ្រប់បែបយ៉ាងដើម្បីតែផលប្រយោជន៍របស់ខ្លួន ដោយបំភ្លេចនូលផលប្រយោជន៍ជាតិជាធំ។

ថ្វីត្បិតតែកម្ពុជាមានស្ថាប័នប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ និងប្រពន្ធ័ច្បាប់ហើយក៏ដោយតែហាក់បីដូចជាការអនុវត្តនៅមានកម្រិតនៅឡើយ។ ប៉ុន្តែ ឯករាជភាពនៃស្ថាប័ន អព្យាក្រឹត្យនៃមន្ត្រីអនុវត្ត មានការលើកស្ទួយ និងការគាំទ្រពីរដ្ឋាភិបាល មន្ត្រីអនុវត្តត្រូវមានឆន្ទៈ និងការទទួលខុសត្រូវ ការបង្កើតតុលាការដោយឡែកឲ្យទទួលខុសត្រូ វលើរឿងក្តីពុករលួយ មន្ត្រីអនុវត្តត្រូវតែមានចំណេះជំនាញនិងទទួលបានការបណ្តុះបណ្តាលច្បាស់លាស់ និងមិនមែនជាមន្ត្រីចូលធ្វើការតាមរយៈខ្សែរឡាយឡើយ។ វិធានការមួយចំនួនខាងលើនេះជួយបំពេញបន្ថែមឲ្យសកម្មភាពប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយឲ្យកាន់តែមានប្រសិទ្ធិភាពឡើង។**ភាពគ្មានការទទួលខុសត្រូវរបស់មន្ត្រីរាជការ** ការប្រកាន់ឥរិយាបថជាម្ចាស់នៃអ្នកដ៏ទៃ ដោយខ្លួនស្ថិតក្នុងឋានៈ និងតួនាទីជាអ្នកបំរើនៃប្រជាពលរដ្ឋជានិច្ច នោះវាមិនមែនជាសិលធម៌ និងជាសុជីវធម៌ល្អប្រសើរនោះទេ តែវាជាសញ្ញាណមួយដែលធ្វើឲ្យប្រសិទ្ធភាពនៃសេវាសាធារណៈកាន់តែធ្លាក់ចុះ ព្រមទាំងធ្វើឲ្យមន្ត្រីមួយចំនួនភ្លេចអស់រលីងនូងករណីកិច្ច និងការទំនួលខុសត្រូវរបស់ខ្លួនចំពោះប្រជាពលរដ្ឋ។ ប៉ុន្តែការបង្កើតច្បាប់រដ្ឋបាល ការដាក់ទោសឲ្យធ្ងន់ធ្ងរទៅ

លើជនណាដែលបានល្មើស ផ្សព្វផ្សាយពីច្បាប់ដែលពាក់ពន្ធ័ស្ដីពីក្រមសិលធម៌ និងច្បាប់កំណត់ពីបទល្មើស បង្កើតឲ្យមានតុលាការរដ្ឋបាលដើម្បីត្រួតពិនិត្យលិខិតស្នាមសេចក្ដីសម្រេចរបស់អង្គការរដ្ឋបាលសាធារណៈ និងការបំពេញមុខងារ និងការងាររបស់មន្ត្រីសាធារណៈ។

ដោយមូលហេតុការយល់ដឹងអំពីវិស័យច្បាប់ និងសង្គមនៅមានកម្រិតនៅឡើយ ព្រមយោងតាមអត្ថបទដ៏ខ្លីខាងលើ យើងខ្ញុំសង្ឃឹមថា និងបានរួចចំណែកក្នុងការធ្វើកំណែរទម្រង់ខាងវិសយ័យុត្តិធម៌ និងអនុវត្តច្បាប់ ព្រមទាំងអភិវឌ្ឍន៍លើវិស័យផ្សេងៗទៀត ដើម្បីឆ្លើយតបផងដែរចំពោះតម្រូវការសង្គមបច្ចុប្បន្នផងដែរ។

# ឯកសារយោង


- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឲ្យប្រើកាលពីថ្ងៃទី២១ កញ្ញា ឆ្នាំ ១៩៩៣
- ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ប្រកាសឲ្យប្រើកាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧
- ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ប្រកាសឲ្យប្រើកាលពីថ្ងៃទី១៦ ខែ កក្កដា ឆ្នាំ ២០១៤
- ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និង ព្រះរាអាជ្ញា ប្រកាសឲ្យប្រើកាលពីថ្ងៃទី១៦ ខែ កក្កដា ឆ្នាំ២០១៤
- សាស្រ្តាចារ្យ មីន សំអុល សៀវភៅ នីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០១៧ - ២០១៩
- លោកមេធាវី កែ វិសាល សេហ សុខឃី និង លោមេធាវី ហេងពួន របាយការណ៍ស្រាវជ្រាវនីតិវិធីការអនុវត្តជាក់ស្តែងក្នុងរឿងក្តីព្រហ្មទណ្ឌ ឆ្នាំ២០១៤ -២០១៥
- សាស្រ្តចារ្យ រុន ពណ្ណារិទ្ធ និង លោកស្រីសាស្រ្តចារ្យ ចាំងស៊ុ ណាត សៀវភៅនីតីវីធីព្រហ្មទណ្ឌ ឆ្នាំ ២០១៣-២០១៤
- វរសេនីយ៍ទោ អាន សុរីដា សៀវភៅដំណើរការរឿងក្តីព្រហ្មទណ្ឌនៅកម្ពុជាបច្ចុប្បន្ន ឆ្នាំ២០១៤

## តារាងឧបសម្ពន្ធ័

១. កំណត់ហេតុ

២. ដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ

៣. ដីកាតម្កល់រឿងទុកឥតចាត់ការ

៤. ដីកាសន្និដ្ឋានសុំអោយឃុំខ្លួនបណ្តោះអាសន្ន

៥. ដីកាបញ្ជូនរឿងអោយស៊ើបសួរទៅជំនុំជំម្រះ

៦. ដីកាកោះហៅ

៧. ដីកាចាត់អោយស៊ើបសួរជំនួស

៨. ដីកាបង្គាប់អោយចូលខ្លួន

៩. ដីកាបង្គាប់អោយនាំខ្លួន

១០. ដីកាបង្គាប់អោយឃុំខ្លួន

១១. ដីកាបង្គាប់អោយចាប់ខ្លួន

១២. ដីកាសម្រេចដាក់ជនត្រូវចោទស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ